ISSN 1560-7615 / ISBN 978-99950-52-06-5


# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៤ លេខ៣ | កក្កដា - កញ្ញា ឆ្នាំ២០១០ | តម្លៃ ១.៥០០៛


20 ខួបលើកទី CDRI 1990-2010

# សិក្សាពីកត្តាកំណត់លើជោគជ័យនៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រដោយកសិករ៖ ករណីសិក្សា នៅខេត្តកំពង់ស្ពឺ[1]

*អ្នកដឹកនាំសហគមន៍ម្នាក់នៅខេត្តកំពង់ស្ពឺ និយាយថា "ក្នុងនាមជាអ្នកដឹកនាំ យើងមិនអាចសម្រេចចិត្តធ្វើការងារដោយមិនបានពិភាក្សាជាមួយកសិករឡើយ បើមិនដូច្នោះទេ យើងនឹងត្រូវធ្វើការនោះតែម្នាក់ឯង" ។*



*ទឹកស្រោចស្រពគ្រប់គ្រាន់ ដំណាំលូតលាស់ល្អ កសិករសប្បាយចិត្ត ខេត្តកំពង់ស្ពឺ*

## សេចក្តីផ្តើម

និន្នាការសាកលលើការអភិរក្សធនធានធម្មជាតិនាពេលបច្ចុប្បន្ន បានកំណត់យកតួនាទីរបស់អ្នកប្រើប្រាស់ថាជាដំណោះស្រាយ ជាជាងបញ្ហាចោទ ។ ចំណុចនេះបានត្រួសត្រាយផ្លូវសំរាប់វិធីសាស្ត្រថ្មីនៃការបែងចែកឡើងវិញនូវសិទ្ធិអំណាចគ្រប់គ្រងជាលក្ខណៈមជ្ឈការ ទៅឲ្យក្រុមប្រជាជនក្នុងសហគមន៍ ដើម្បីឲ្យមានការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព (Gibson etal.2000) ។វិធីសាស្ត្របែបនេះក៏ឃើញមានជាក់ស្តែងនៅកម្ពុជាដែរ ។ នៅក្រោមកំណែទម្រង់វិមជ្ឈការ បន្ទាប់ពីការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់លើកទី១ ក្នុងឆ្នាំ២០០២មក រដ្ឋាភិបាលបានផ្ទេរសិទ្ធិអំណាចមួយភាគ ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រពីក្រសួងធនធានទឹក និងឧតុនិយម (MoWRAM) ឲ្យទៅសហគមន៍កសិករប្រើប្រាស់ទឹក (FWUCs) ។ FWUCs ទទួលខុសត្រូវលើការងារគ្រប់គ្រង និងថែទាំ ប្រព័ន្ធធារាសាស្ត្រក្នុងតំបន់របស់ខ្លួន ដោយឡែកការថែទាំទ្រង់ទ្រាយធំ គឺនៅតែស្ថិតក្រោមការទទួលខុសត្រូវរបស់រដ្ឋាភិបាលដដែល ។

ដំណើរការ FWUCs ត្រូវប្រឈមនឹងបញ្ហាចោទជាច្រើន ជាពិសេសក្នុងបរិបទនៃ ប្រទេសដែលមានអត្រាភាពក្រីក្រខ្ពស់ ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រទ្រុឌទ្រោម ដែលបន្សល់ពីជំនាន់ប៉ុល ពត (Perera 2006) សង្គមស៊ីវិលទន់ខ្សោយ និងវិមជ្ឈការកំពុងដំណើរការ (Kim & Öjendal 2007) ។ ករណីសិក្សាពី FWUC មួយក្នុងខេត្តកំពង់ឆ្នាំង រកឃើញថា សហគមន៍ពុំសូវដំណើរការល្អ ដោយសារខ្វះការចូលរួមពីកសិករ ភាពជាម្ចាស់កម្មសិទ្ធិលើប្រព័ន្ធធារាសាស្ត្រ និងសិទ្ធិអំណាចគ្រប់គ្រង (Chea

[1] អត្ថបទនេះ រៀបរៀងដោយ រស់ បណ្តែត អ្នកស្រាវជ្រាវ នៃវិទ្យាស្ថាន CDRI ។ អត្ថបទនេះ ផ្អែកលើសារណាបញ្ចប់ថ្នាក់អនុបណ្ឌិត (MApplSc) ឆ្នាំ២០១០ របស់អ្នកនិពន្ធស្តីពី "ការគ្រប់គ្រងការស្រោចស្រពដោយមានការចូលរួម និងកត្តាជះឥទ្ធិពលលើជោគជ័យនៃសហគមន៍កសិករប្រើប្រាស់ទឹក៖ ករណីសិក្សានៅប្រទេសកម្ពុជា" ។

## មាតិកា


សិក្សាពីកត្តាជះឥទ្ធិពលលើជោគជ័យនៃប្រព័ន្ធស្រោចស្រពគ្រប់គ្រងដោយកសិករ៖ ករណីសិក្សានៅកំពង់ស្ពឺ ........១
ការវាយតម្លៃឆាប់រហ័សពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចមកលើក្រុមគ្រួសារកម្ពុជា និងពលករងាយរងគ្រោះ ...៦
មនុស្សវ័យចំណាស់គាំទ្រកម្មវិធីព្យាបាលដោយឱសថប្រឆាំងវីរុសអេដស៍ នៅខេត្តបន្ទាយមានជ័យ...........១០
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស................១៥
– ស្ថានភាពក្នុងប្រទេស ................ ១៧
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI ......................................២៤

រូបភាព ១៖ កត្តានាំទៅរកភាពជោគជ័យនៃសហគមន៍កសិករប្រើប្រាស់ទឹក អូរត្រែង




forthcoming) ។ នៅខេត្តតាកែវ បរាជ័យនៃ FWUCs ទំនងផុសចេញពី កង្វះធនធានហិរញ្ញវត្ថុ ភាពអន់ខ្សោយក្នុងការដឹកនាំ និងកង្វះការលើកទឹកចិត្ត និង អន្តរាគមន៍ពីក្រុមប្រឹក្សាឃុំ (Thun 2008) ។

បើទោះជាយ៉ាងនេះក្ដី មាន FWUCs ខ្លះ ដែលទទួលបានជោគជ័យក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ។[២] ការសិក្សានេះ ជួយបំពេញបន្ថែមលើការសិក្សាពីមុនៗ ដោយពិនិត្យពីកត្តានានាដែលជះឥទ្ធិពលដល់ជោគជ័យរបស់ FWUCs ដើម្បីព្យាយាមកែលំអ និងលើកកំពស់ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រមួយចំនួនដែលមិនសូវជោគជ័យ ។ ការសិក្សានេះបានជ្រើសយកសហគមន៍កសិករប្រើប្រាស់ទឹកអូរត្រែង ដែល MoWRAM បានចាត់ទុកថា មានជោគជ័យខ្លាំងជាងគេ នៅឆ្នាំ២០០៨ មកសិក្សា ។ សហគមន៍នេះស្ថិតក្នុង ឃុំជង្រុក និងឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដែលកន្លងមកសហគមន៍បានជួយកែលំអជីវភាពប្រជាកសិករ និងដំណើរការដោយខ្លួនឯងក្នុងការងារគ្រប់គ្រង និងថែទាំប្រព័ន្ធធារាសាស្ត្រ ប្រចាំថ្ងៃរបស់ខ្លួន ។

## លទ្ធផលការស្រាវជ្រាវ

មានកត្តាផ្ទៃក្នុង ៥ និងកត្តាខាងក្រៅ ២ ដែលនាំឲ្យសហគមន៍អូរត្រែង ទទួលបានជោគជ័យ ។ កត្តាផ្ទៃក្នុង រួមមាន៖ (១) ការចូលរួមរបស់កសិករ (២) ការគ្រប់គ្រង និងអភិបាលកិច្ចនៅមូលដ្ឋាន (៣) ផលប្រយោជន៍ពីប្រព័ន្ធ (៤) គុណភាពហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ និង (៥) ចរិតលក្ខណៈ និងស្ថានភាពរស់នៅជាក្រុម របស់កសិករជាសមាជិក ។ កត្តាខាងក្រៅ គឺមានជំនួយគាំទ្រពីខាងក្រៅ និងទីផ្សារ ។ ក្រាហ្វិក ១ បង្ហាញពី ទំនាក់ទំនងទៅមករវាងកត្តាទាំងប្រាំពីរ ។

**ការចូលរួមរបស់កសិករ៖** កសិករបានចូលរួមសកម្មក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ដែលរួមមាន ការចូលរួមវិភាគទានជាប្រាក់កាស កំលាំងពលកម្ម និងធនធានដទៃទៀត ព្រមទាំងការចូលរួមធ្វើសេចក្ដីសម្រេចចិត្ត ។ ការចូលរួមមាន ៤ ប្រភេទគឺ៖ ការបង់ថ្លៃសេវាប្រើប្រាស់ទឹក ការងារចែកចាយទឹក ការថែទាំប្រព័ន្ធប្រឡាយ និងទំនប់ និងការជួបប្រជុំសហគមន៍ ។

ការចូលរួមរបស់កសិករសំខាន់ណាស់ ព្រោះជះឥទ្ធិពលទៅលើគុណភាពនៃប្រព័ន្ធធារាសាស្ត្រ អភិបាលកិច្ច និងការគ្រប់គ្រងរបស់គណៈកម្មការ ។ ការបង់ថ្លៃសេវាប្រើប្រាស់ទឹក ធានាធនធានហិរញ្ញវត្ថុសំរាប់ដំណើរការប្រព័ន្ធ ដែលធ្វើឲ្យសហគមន៍មិនសូវពឹងផ្អែកលើជំនួយគាំទ្រពីខាងក្រៅ ។ ការចូលរួមក្នុងការងារចែកចាយទឹក ធានាដល់ការផ្គត់ផ្គង់ទឹកឲ្យកសិករបានគ្រប់គ្រាន់ និងទាន់ពេល និងជួយកាត់បន្ថយបន្ទុកការងាររបស់គណៈកម្មការ ដែលធ្វើឲ្យពួកគាត់បន្តការងារនៅក្នុងសហគមន៍ ។ ម្យ៉ាងទៀត កាលណាកសិករចូលរួមក្នុងការងារចែកចាយទឹក នោះសហគមន៍ទំនងជាមិនសូវជួបប្រទះ បញ្ហាទឹកជន់លិចដំណាំ

២ សម្ភាសន៍ជាមួយបុគ្គលិក នៃ MoWRAM កាលពីថ្ងៃទី ៣ តុលា ២០០៨ ។

ទឹកហៀរចោល ឬការខ្វះខាតទឹកសហគមន៍ជាដើម ។ ការចូលរួមពីប្រជាជនមូលដ្ឋានក្នុងការងារថែទាំ ដូចជា រាយការណ៍ពីការខូចខាត និងចូលរួមវិភាគទានជាកំលាំងពលកម្ម និង/ឬ ប្រាក់កាសក៏អាចជួយកាត់បន្ថយបន្ទុកការងាររបស់គណៈកម្មការ ក្នុងការត្រួតពិនិត្យ និងដើរល្បាត និងជួយកែលំអគុណភាពហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រផងដែរ ។ ការចូលរួមប្រជុំក្នុងសហគមន៍ ជួយបង្កើនការយល់ដឹងពីសារៈសំខាន់ នៃការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ បង្កើនភាពជាម្ចាស់លើការសម្រេចចិត្ត តម្លាភាព និងទំនុកចិត្តរវាងគណៈកម្មការ និងកសិករ ហើយទាំងអស់នេះនាំឲ្យមានការចូលរួមកាន់តែច្រើនពីសំណាក់កសិករ ក្នុងការងារគ្រប់គ្រង និងអភិបាលកិច្ចធារាសាស្ត្រ ។

**ការគ្រប់គ្រង និងអភិបាលកិច្ចមូលដ្ឋាន៖** កត្តានេះក៏សំខាន់ណាស់ដែរ ព្រោះធានាឲ្យមានការចូលរួមពីកសិករ បង្កើនផលប្រយោជន៍ពីធារាសាស្ត្រ លើកកំពស់គុណភាពហេដ្ឋារចនាសម្ព័ន្ធ និងបង្កើនជំនួយគាំទ្រពីខាងក្រៅ ។ សមាសធាតុនៃការគ្រប់គ្រង និងអភិបាលកិច្ចមូលដ្ឋាន រួមមាន រចនាសម្ព័ន្ធសហគមន៍ សមត្ថភាពដឹកនាំរបស់គណៈកម្មការ របៀបនៃការបង្កើតសហគមន៍ និងការអនុវត្ត ការពង្រឹង និងកែសម្រួលលក្ខន្តិកៈរបស់គណៈកម្មការ ។

ក. រចនាសម្ព័ន្ធសហគមន៍ មានបីថ្នាក់៖ គណៈកម្មការ ក្រុម និងអនុក្រុម ។ រចនាសម្ព័ន្ធនេះដំណើរការបានល្អ ព្រោះវាធ្វើឲ្យភូមិនីមួយៗ ទទួលខុសត្រូវលើការងារគ្រប់គ្រង និងថែទាំហេដ្ឋារចនាសម្ព័ន្ធដែលផ្គត់ផ្គង់ទឹកដល់ពួកគេ ។ រចនាសម្ព័ន្ធនេះ ក៏ជួយសម្រួលឲ្យអនុក្រុមនីមួយៗមាន សមាជិកភាពតិចនាក់ ដែលធ្វើឲ្យគណៈកម្មការងាយស្រួលធ្វើការពង្រឹងលក្ខន្តិកៈរបស់សហគមន៍ ។

ខ. សមត្ថភាពដឹកនាំចែកជា៖ (១) ឥរិយាបថ (២) ចំណេះដឹង និងជំនាញ និង(៣) សិទ្ធិអំណាច ។ ឥរិយាបថដែលកសិករសំគាល់ថាជាអ្នកដឹកនាំល្អ រួមមាន សីលធម៌ការងារល្អ ការប្តេជ្ញាចិត្តខិតខំធ្វើការងារ ភាពស្មោះត្រង់ តម្លាភាព និងឆន្ទៈគិតគូរពីផលប្រយោជន៍សហគមន៍ជាធំ ការធ្វើការងារទន្ទឹមគ្នានឹងកសិករ ភាពទំនួលខុសត្រូវ និងការបន្តរៀនសូត្របន្ថែមលើការងារគ្រប់គ្រងធារាសាស្ត្រ ។ កសិករក៏បានកំណត់ដែរថា ចំណេះដឹង និងជំនាញសំខាន់ៗរបស់គណៈកម្មការរួមមាន ការយល់ដឹងពីរបៀបគ្រប់គ្រងប្រព័ន្ធ ការចេះលើកទឹកចិត្ត និងសមត្ថភាពដោះស្រាយបញ្ហាប្រកបដោយភាពច្នៃប្រឌិត ។ គណៈកម្មការក៏គួរមានជំនាញក្នុងការងារបង្រួបបង្រួម ការបែងចែកតួនាទី និងការទំនាក់ទំនងផងដែរ ។ ដោយឡែកសិទ្ធិអំណាចរបស់គណៈកម្មការ សំដៅលើការទទួលខុសត្រូវ និងអំណាចក្នុងការកៀងគរកសិករ និងការគ្រប់គ្រងសហគមន៍ ។

សមត្ថភាពដឹកនាំរបស់គណៈកម្មការដែលផ្អែកលើ តម្លាភាព និងភាពស្មោះត្រង់ រួមចំណែកដល់ជោគជ័យរបស់សហគមន៍ ដោយធានាឲ្យកសិករមានទំនុកចិត្តលើគណៈកម្មការ ។ ដោយសារសីលធម៌ការងារល្អរបស់ខ្លួន គណៈកម្មការទទួលបានការគោរពរាប់អានពីកសិករ ។ ទំនុកចិត្ត និងការគោរពនេះ ធ្វើឲ្យគណៈកម្មការមានប្រជាប្រិយភាពក្នុងចំណោមកសិករ ដែលកាន់តែធ្វើអោយកសិករពេញចិត្តចូលរួមក្នុងសកម្មភាពសហគមន៍ថែមទៀត ។

ចំណេះដឹង និងជំនាញក្នុងការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រក៏ធ្វើឲ្យកសិករមានទំនុកចិត្ត និងចូលរួមសកម្មដែរ ។ ថ្នាក់ដឹកនាំដែលមានជំនាញទំនាក់ទំនង ក៏អាចស្នើសុំ ជំនួយទ្រទ្រង់ពីខាងក្រៅ ។ លើសពីនេះ ដោយសារគណៈកម្មការមានសិទ្ធិសម្រេចលើការងារគ្រប់គ្រងធារាសាស្ត្រ ដោយពុំសូវមានការជ្រៀតជ្រែកពី MoWRAM ឬអាជ្ញាធរមូលដ្ឋាន ដូច្នេះពួកគាត់អាចធ្វើការថែទាំ និងឆ្លើយតបតាមសំណើសុំរបស់កសិករបានទាន់ពេលវេលា ។ សិទ្ធិអំណាចនេះក៏អាចឲ្យគណៈកម្មការធ្វើការពង្រឹងលក្ខន្តិកៈ និងធ្វើឲ្យគណៈកម្មការ និងកសិករមានភាពជាម្ចាស់លើការសម្រេចចិត្តផងដែរ ។

គ. សហគមន៍ ត្រូវបានរៀបចំឡើងតាមគោលការណ៍ប្រជាធិបតេយ្យ ដោយកសិករអាចបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំដែលខ្លួនពេញចិត្ត និងរៀបចំបង្កើតលក្ខន្តិកៈសំរាប់គ្រប់គ្រងប្រព័ន្ធដោយខ្លួនឯង ។ ចំណុចនេះ ធ្វើឲ្យកសិករពេញចិត្តអនុវត្តតាមលក្ខន្តិកៈ ហើយសហគមន៍ក៏អាចជ្រើសរើសគណៈកម្មការដែលមានសមត្ថភាពដឹកនាំខ្ពស់ ព្រោះកសិករនឹងបោះឆ្នោតឲ្យថ្នាក់ដឹកនាំណាដែលពួកគេគិតថា អាចត្រួតត្រា និងគ្រប់គ្រងសហគមន៍ប្រកបដោយប្រសិទ្ធភាព ។

ឃ. សហគមន៍អនុវត្តលក្ខន្តិកៈលើ វិធាន ៤ចំនុចសំខាន់ៗ៖ (១) ការបែងចែកទឹក (២) ការថែទាំប្រព័ន្ធធារាសាស្ត្រ (៣) ការប្រមូលថ្លៃសេវាប្រើប្រាស់ទឹក និង (៤) ការគ្រប់គ្រងហិរញ្ញវត្ថុ ។ ការធ្វើសេចក្តីសម្រេចចិត្តលើការអនុវត្តលក្ខន្តិកៈនេះផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួន ៦ គឺ៖ ការស្រុះស្រួលគ្នា ការបញ្ចូលគំនិតយោបល់គ្នា ការឆ្លើយតប ប្រសិទ្ធភាព តម្លាភាព និងភាពយុត្តិធម៌ ។ ចំណុចទាំងនេះធានាឲ្យទំនាស់ថយចុះ កសិករមានភាពជាម្ចាស់លើសេចក្តីសម្រេចចិត្ត កសិករគោរពលក្ខន្តិកៈ សហគមន៍ទទួលបានធនធានហិរញ្ញវត្ថុសំរាប់ដំណើរការប្រព័ន្ធ ការផ្គត់ផ្គង់ទឹកប្រកបដោយប្រសិទ្ធភាព និងសំខាន់បំផុតធានាឲ្យកសិករមានទំនុកចិត្តលើគណៈកម្មការ ។

ង. ការពង្រឹងលក្ខន្តិកៈ ពោលគឺ ការពិន័យជនដែលប្រព្រឹត្តិខុសតែងបានធ្វើឡើងជារឿយៗ ក្នុងការងារបែងចែកទឹករបស់សហគមន៍ ។ មានតែកសិករដែលបានដាក់សំណើ និងទទួលការយល់ព្រមពីគណៈកម្មការប៉ុណ្ណោះ ដែលអាចទទួលបានទឹកស្រោចស្រព រីឯអ្នកមិនបានអនុវត្តតាមវិធាននេះមិនអាចទទួលបានទឹកឡើយ ។ ការពង្រឹងលក្ខន្តិកៈយ៉ាងទៀងទាត់ជួយកាត់បន្ថយករណីលួចទឹក ធានាឲ្យមានយុត្តិធម៌ក្នុងចំណោមសមាជិក និងជំរុញការចូលរួមកាន់តែច្រើន ។

ច. លក្ខន្តិកៈត្រូវបានកែសម្រួលនៅពេលៈ (១) កសិករជួបប្រទះការខូចខាតផលដំណាំ (២) គណៈកម្មការមានបន្ទុកការងារច្រើន (៣) កសិករមានភាពរវល់នឹងការងារ (៤) បរិមាណទឹកប្រើប្រាស់ក្នុងប្រព័ន្ធមិនគ្រប់គ្រាន់ និង (៥) កំរិតនៃលទ្ធភាពទទួលបានទឹករបស់កសិករមានតិច ។ គណៈកម្មការបានកែសម្រួលលក្ខន្តិកៈលើ៤ចំណុច គឺៈ (១) ការប្រមូលថ្លៃសេវាប្រើប្រាស់ទឹក (២) ទំនួលខុសត្រូវរបស់គណៈកម្មការ (៣) វត្តមានកសិករក្នុងការប្រជុំសហគមន៍ និងការងារថែទាំ និង (៤) ការបែងចែកទឹក ។ ការកែសម្រួលបែបនេះជួយបង្កើនភាពយុត្តិធម៌ក្នុងចំណោមកសិករ ទំនុកចិត្តរបស់កសិករលើគណៈកម្មការ និងការចូលរួម ។

**ផលប្រយោជន៍ពីប្រព័ន្ធៈ** នេះជាកត្តាលើកទឹកចិត្តចំបងបំផុតដែលជំរុញដល់ការចូលរួមរបស់កសិករ ។ ប្រព័ន្ធធារាសាស្ត្រអូរត្រែង ផ្តល់ផលប្រយោជន៍ ២ បែបគឺៈ បង្កើនសន្តិសុខស្បៀង និងចំណូលបន្ថែមជូនកសិករ ។ កសិករពឹងផ្អែកលើទឹកភ្លៀងដើម្បីដាំស្រូវនៅរដូវវស្សា ។ ដោយសារជារឿយៗភ្លៀងធ្លាក់មិនបានគ្រប់គ្រាន់ ដូច្នេះទឹកពីប្រព័ន្ធជួយបំពេញបន្ថែមទឹកភ្លៀងដែលជួយធានាឲ្យស្រូវវស្សាទទួលបានទិន្នផលខ្ពស់ ។ នៅឆ្នាំខ្លះកសិករប្រើប្រាស់ទឹកពីប្រព័ន្ធ ដើម្បីធ្វើការសាបព្រួស និងដកស្ទូង ហើយនៅឆ្នាំខ្លះទៀត ពួកគេត្រូវប្រើទឹកពីប្រព័ន្ធ រហូតដល់ពេលប្រមូលផលស្រូវតែម្តង ។

កសិករភាគច្រើន យល់ថាកំណើនទិន្នផលស្រូវវស្សាគឺជាផលប្រយោជន៍ដ៏ចំបងមួយរបស់ពួកគេ ពីព្រោះប្រជាជនក្នុងសហគមន៍តែងធ្វើស្រូវវស្សាសម្រាប់ការហូបចុកផ្ទាល់ខ្លួន ។ ស្រូវវស្សាជាកត្តាធានាសន្តិសុខស្បៀងដល់ប្រជាជន ។ គ្រួសារខ្លះដែលពុំមានប្រភពចំណូលអ្វីផ្សេង បានលក់ស្រូវវស្សារបស់ខ្លួនមួយភាគ ដើម្បីដោះស្រាយការចំណាយផ្សេងៗ ។

ផលប្រយោជន៍មួយទៀត គឺចំណូលបានពីការលក់ផលដំណាំនៅរដូវប្រាំង ដូចជា ឪឡឹក ត្រឡាច ល្ពៅ ។ ដោយសារនៅរដូវប្រាំងមានភ្លៀងធ្លាក់តិចតួច ដូច្នេះកសិករត្រូវពឹងផ្អែកស្ទើរទាំងស្រុងលើទឹកពីប្រព័ន្ធ ។ មួយវិញទៀតគឺ ចំណូលបានពីផលដំណាំទាំងនេះ មានចំនួនស្មើនឹង ២ ទៅ ៤ដង នៃថ្លៃដើមគិតបញ្ចូលទាំងថ្លៃសេវាប្រើប្រាស់ទឹកស្រោចស្រពផង (តារាង ១) ។ ដូច្នេះផលដំណាំនៅរដូវប្រាំង ជាប្រភពចំណូលដ៏សំខាន់មួយរបស់កសិករ ។

ចំណូលខាងលើសំខាន់សំរាប់កសិករ ព្រោះនៅរដូវប្រាំងកសិករពុំសូវមានការងារធ្វើ ហើយកសិករក៏ខ្វះខាតជំនាញធ្វើការងារផ្សេងដែរ ។ បើទោះជាមានកសិករមួយចំនួននិយាយថា ពួកគាត់អាចរកការងារធ្វើបាននៅរដូវប្រាំង ការងារទាំងនោះមិនផ្តល់ចំណូលច្រើនដូចការដាំដំណាំទេ ។

**គុណភាពនៃហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ** ជាកត្តាសំខាន់មួយ ។ ប្រព័ន្ធអូរត្រែងមានអាងស្តុកទឹកដ៏ធំ (២.៥៦៣.៧៥០ ម៉ែត្រគូប) សំរាប់រក្សាទឹកភ្លៀង ដែលបានសាងសង់ឡើងយ៉ាងល្អ ហើយពុំសូវមានការជ្រាបបាត់បង់ទឹកឡើយ ។ លក្ខណៈនេះ ធ្វើឲ្យប្រព័ន្ធអាចស្តុកទឹកបានគ្រប់គ្រាន់ សំរាប់ស្រោចស្រពនៅរដូវវស្សា និងសំរាប់ដំណាំនៅរដូវប្រាំង ។

ប្រព័ន្ធធារាសាស្ត្រនៅអូរត្រែងក៏មានប្រឡាយនិងទ្វារទឹកយ៉ាងច្រើនដែលកសាងបានយ៉ាងល្អ ។ កត្តានេះ ជួយឲ្យការចែកចាយទឹកមានប្រសិទ្ធភាពខ្ពស់ ។ ដោយសារប្រព័ន្ធអាចផ្គត់ផ្គង់ទឹកបានគ្រប់គ្រាន់ និងទាន់ពេលវេលា ដូច្នេះកសិករក៏ពេញចិត្តបង់ថ្លៃសេវាស្រោចស្រព ។

**ចរិតលក្ខណៈ និងស្ថានភាពរស់នៅជាក្រុមរបស់កសិករជាសមាជិកៈ** (១) ទំហំសមាជិក (២) ភាពស្រដៀងគ្នាក្នុងការរស់នៅ (៣) ភាពពឹងផ្អែកលើការដាំដុះ និង (៤) ប្រពៃណីសហការគ្នាក្នុងការគ្រប់គ្រងធារាសាស្ត្រ ។ ដោយសារក្រុម និងអនុក្រុមកសិករ

តារាង ១ៈ ឧទាហរណ៍ នៃចំណាយ និងចំណូល នៃផលិតកម្មដំណាំនៅរដូវប្រាំង ឆ្នាំ២០០៨

| ទំហំដី (ហិកតា) | ដំណាំ | ចំណាយសរុប (ដុល្លារ) (គិតទាំងថ្លៃទឹកស្រោចស្រព) | ចំណូលសរុប (ដុល្លារ) | ចំណូលសរុប (គិតជា % នៃចំណាយ) |
|---|---|---|---|---|
| 1.00 | ឪឡឹក | 75 | 500 | 769 |
| 0.30 | ឪឡឹក | 43 | 160 | 400 |
| 0.10 | ឪឡឹក | 64 | 125 | 198 |
| 0.35 | ត្រឡាច | 104 | 250 | 250 |
| 0.20 | ត្រឡាច | 152 | 300 | 200 |
| 0.15 | ត្រឡាច | 62 | 150 | 250 |
| 0.30 | ល្ពៅ | 43 | 150 | 375 |

មានទំហំសមាជិកតូច ដូច្នេះគណៈកម្មការអាចអនុវត្ត និងពង្រឹងលក្ខន្តិកៈសហគមន៍បានយ៉ាងស្រួល ។ ទំហំសមាជិកតូចក៏ជួយឲ្យកសិករមានទំនាក់ទំនងគ្នាជាញឹកញាប់ និងអនុញ្ញាតឲ្យពួកគេអាចពិនិត្យតាមដានគ្នាចុះឡើងលើការងារបែងចែកទឹក និងការងារថែទាំប្រព័ន្ធ ។

កសិករក្នុងសហគមន៍ មានភាពស្រដៀងគ្នាគួរសមលើវប្បធម៌ ជាតិសាសន៍ តម្រូវការ របៀបធ្វើស្រែចំការ និងកំរិតជីវភាព ។ ជំនឿ ទស្សនៈ និងតម្រូវការ ប្រហាក់ប្រហែលគ្នា បានជួយសម្រួលដល់ កិច្ចសហប្រតិបត្តិការរបស់កសិករក្នុងការងារគ្រប់គ្រងប្រព័ន្ធ ។

ភាពពឹងផ្អែកខ្លាំងលើការដាំដុះ ធ្វើឲ្យកសិករយល់ថាប្រព័ន្ធធារាសាស្ត្រ មានសារៈសំខាន់សម្រាប់ជីវភាពរស់នៅរបស់ពួកគេ ដូច្នេះពួកគេចង់ចូលរួមថែទាំយ៉ាងសកម្ម ។ កសិករក៏មានប្រពៃណីសហការគ្នា ក្នុងការគ្រប់គ្រងធារាសាស្ត្រដោយខ្លួនឯង និងក្រោយមក ក៏ត្រូវបានរៀបចំជាលក្ខណៈក្រៅផ្លូវការពីឆ្នាំ ១៩៩៥ ដល់ ២០០០ ។ ប្រពៃណីសហការគ្នានេះ បានជួយឲ្យសហគមន៍សម្រេចជោគជ័យតាម ៣ របៀបគឺៈ ទីមួយ សហគមន៍មានថ្នាក់ដឹកនាំដែលមានសមត្ថភាពស្រាប់ ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ។ ទីពីរ កសិករមូលដ្ឋាន មានបទពិសោធន៍ក្នុងការបង្កើតលក្ខន្តិកៈសមស្របសម្រាប់សហគមន៍ ។ ទីបី កសិករយល់ដឹងពីសារៈសំខាន់នៃការចូលរួមរបស់ខ្លួន ។

**ជំនួយគាំទ្រពីខាងក្រៅៈ** FWUC អូរត្រែង ទទួលបានជំនួយទ្រទ្រង់ជាច្រើនពីក្រសួងធនធានទឹក អាជ្ញាធរឃុំ និងស្រុក និងកម្មវិធីស្បៀងអាហារពិភពលោក មានជាអាទិ៍ ការស្តារជួសជុល និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ ជំនួយគាំទ្រដល់ការបង្កើតសហគមន៍ ការបណ្តុះបណ្តាល ធនធានហិរញ្ញវត្ថុសម្រាប់ជួយរ៉ាប់រងចំណាយក្នុងរយៈពេល២ឆ្នាំដំបូង ការពិគ្រោះយោបល់ការពង្រឹង លក្ខន្តិកៈ និងការដោះស្រាយទំនាស់ ។

ជំនួយពីខាងក្រៅ បានជួយកែលំអគុណភាពហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រតាមរយៈការស្តារជួសជុល និងបានជួយពង្រឹងចំណេះដឹង និងជំនាញរបស់កសិករ និងគណៈកម្មការតាមរយៈការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ដែលធ្វើឲ្យអភិបាលកិច្ច និងការគ្រប់គ្រងនៅមូលដ្ឋានអាចដំណើរការល្អ ។ ម្យ៉ាងទៀត រដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន បន្តផ្តល់ជំនួយទ្រទ្រង់ជាបន្តបន្ទាប់ ដោយមិនធ្វើឲ្យប៉ះពាល់ដល់ស្វ័យភាពរបស់សហគមន៍ក្នុងការសម្រេចចិត្តនោះឡើយ ។

**ទីផ្សារៈ** ដោយសារកសិករមានទីផ្សារសម្រាប់ផលិតផលរបស់ខ្លួន ពួកគេទទួលបានប្រាក់ចំណូលច្រើនដែលអាចយកទៅបង់ថ្លៃសេវាប្រើប្រាស់ទឹក និងលើកកំពស់ជីវភាពរស់នៅ ។

កសិករអាចលក់ផលិតផលរបស់ខ្លួនទៅឯទីផ្សារ ឬលក់ទៅឲ្យឈ្មួញកណ្តាលដែលមកទិញដល់ចម្ការ ។ ជាទូទៅតំលៃលក់ដោយផ្ទាល់នៅទីផ្សារ ខ្ពស់ជាង ២ដង តំលៃលក់ទៅឲ្យឈ្មួញនៅចម្ការ ។ ប៉ុន្តែទោះយ៉ាងនេះក្តី កសិករចូលចិត្តលក់ផលិតផលទៅឲ្យឈ្មួញកណ្តាលដែលមកទិញដល់ចម្ការ ព្រោះពួកគេអាចលក់ផលិតផលបានទាំងអស់ភ្លាមៗ ។ វិធីនេះល្អសម្រាប់លំហូរសាច់ប្រាក់របស់កសិករ ហើយកសិករមិនបាច់បារម្ភពីការរក្សាទុកផលិតផល ឬការខាតបង់អ្វីទេ ។ ឈ្មួញកណ្តាលក៏សុខចិត្តបង់ថ្លៃឲ្យកសិករមុនពេលប្រមូលផលដែរ ដើម្បីជួយដោះស្រាយតម្រូវការចាយវាយរបស់កសិកររហូតដល់ពេលប្រមូលផល ។ ចំណុចល្អមួយទៀតនោះគឺឈ្មួញកណ្តាលក៏ព្រមទទួលធ្វើការប្រមូលផល និងដឹកជញ្ជូនផលិតផលទៅទីផ្សារដោយខ្លួនឯង ។ កសិករដែលទៅលក់ផលិតផលដោយផ្ទាល់នៅទីផ្សារ ត្រូវមានទំនាក់ទំនងជាប្រចាំជាមួយអ្នកលក់រាយ ដូច្នេះពួកគេត្រូវចំណាយទាំងពេលវេលា និងលុយកាក់ ហើយកសិករភាគច្រើនមិនជ្រើសយកជំរើសនេះទេ ។

ឈ្មួញកណ្តាលភាគច្រើនជាអ្នកមកពីក្រៅ ប៉ុន្តែមានខ្លះជាកសិករនៅមូលដ្ឋាន ។ ឈ្មួញកណ្តាល មកទិញផលិតផលនៅសហគមន៍នេះ ពីព្រោះវានៅជិតទីផ្សារមូលដ្ឋាន និងរាជធានីភ្នំពេញ ហើយមានផ្លូវល្អ ។ ម្យ៉ាងទៀត សហគមន៍នេះជាកន្លែងមួយនៃស្រុកគងពិសី ដែលមានដំឡូងឡើក និងត្រឡាចច្រើនជាងគេនៅរដូវប្រាំង ។

## សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា ដើម្បីអនុវត្ត FWUC ឲ្យបានជោគជ័យ ត្រូវយកចិត្តទុកដាក់លើកត្តាចំនួន ៧ និងទំនាក់ទំនងរវាងកត្តាទាំងនោះ ។ ទំនាក់ទំនងទាំងនេះបង្កើតឲ្យមានជាកត្តាចាំបាច់ផ្សេងទៀត ដូចជា ទំនុកចិត្ត ភាពយុត្តិធម៌ ភាពជាម្ចាស់កម្មសិទ្ធិ និងការគោរពតាមលក្ខន្តិកៈសហគមន៍របស់កសិករ ដែលទាំងអស់នេះសំខាន់បំផុតសំរាប់ជួយឲ្យ FWUC ដំណើរការ ។

ជោគជ័យរបស់ FWUC ទាមទារការចូលរួមពីកសិករដែលកើតឡើង នៅពេលកសិករទទួលបានផលប្រយោជន៍ច្រើនពីប្រព័ន្ធ ដូចជា សន្តិសុខស្បៀង ឬចំណូលពីការលក់ផលដំណាំជាដើម ។ បើសិនគ្មានផលប្រយោជន៍ទាំងនេះទេ កសិករក៏មិនសូវមានទឹកចិត្តចូលរួមថែទាំប្រព័ន្ធធារាសាស្ត្រដែរ ។ ទីផ្សារក៏ជាកត្តាដ៏សំខាន់ ដើម្បីឲ្យកសិករទទួលបានផលប្រយោជន៍ច្រើនពីប្រព័ន្ធ ។ ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រមានគុណភាពល្អ ក៏ជាកត្តាសំខាន់ធានាឲ្យមានការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ និងទាន់ពេល ។ កត្តាសំខាន់មួយទៀត គឺអភិបាលកិច្ចមូលដ្ឋាន ពិសេសសមត្ថភាពដឹកនាំ និងការធ្វើសេចក្តីសម្រេចចិត្តរបស់គណៈកម្មការ ។

ជោគជ័យរបស់ FWUC ក៏ទាមទារជំនួយគាំទ្រពីខាងក្រៅ ក្នុងកម្រិតណាមួយពីសំណាក់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងក្រុមប្រឹក្សាឃុំ និងស្រុក ។ ចរិតលក្ខណៈ និងស្ថានភាពរស់នៅជាក្រុមរបស់កសិករ ក៏សំខាន់ណាស់ដែរ ។ ជោគជ័យរបស់សហគមន៍នឹងកាន់តែបានល្អថែមទៀត ប្រសិនសហគមន៍ធ្លាប់មានប្រពៃណីសហការគ្នា ក្នុងការងារគ្រប់គ្រងធារាសាស្ត្រដោយខ្លួនឯង កសិករមានភាពស្រដៀងគ្នាក្នុងការរស់នៅ និងពឹងផ្អែកលើការដាំដុះដើម្បីទ្រទ្រង់ជីវភាព ។

## ឯកសារយោង

សូមមើលក្នុងឯកសារជាភាសាអង់គ្លេស ។

# ការវាយតម្លៃឆាប់រហ័សពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច មកលើក្រុមគ្រួសារកម្ពុជា និងពលករងាយរងគ្រោះ[១]

## សេចក្តីផ្តើម និងវិធីសាស្ត្រ

ចាប់តាំងពីវិបត្តិហិរញ្ញវត្ថុសាកល បានលេចរូបរាងច្បាស់នៅខែកញ្ញា ២០០៨ មក វាបានប៉ះពាល់ខ្លាំងបំផុតដល់វិស័យជំរុញកំណើនចំបងៗរបស់កម្ពុជា ពោលគឺ វិស័យកាត់ដេរ ទេសចរណ៍ និងសេវាកម្ម និងសំណង់ ។ ការរួមចុះក្នុងវិស័យទាំងនេះ បានធ្វើឲ្យការងាររាប់ម៉ឺនត្រូវបាត់បង់ ប្រាក់សន្សំនិងប្រាក់ផ្ញើទៅផ្ទះបានធ្លាក់ចុះ ហើយប្រជាជនក្រីក្រនិងជនងាយរងគ្រោះជាទូទៅត្រូវជួបនឹងហានិភ័យ ។ សំពាធបានកើនឡើងដោយជៀសមិនផុតលើសេដ្ឋកិច្ចជនបទ (ជាពិសេស កសិកម្ម) ដែលកំពុងតឹងតែងស្រាប់ហើយដោយសារ កង្វះវិនិយោគ ភាពអន់ថយ និងការពឹងផ្អែកខ្លាំងលើលក្ខខណ្ឌធម្មជាតិ ។ សេដ្ឋកិច្ចជនបទដែលមិនសូវរស់រវើក និងមានមូលដ្ឋានតូចចង្អៀត បានធ្វើឲ្យប្រជាជនជនបទមួយភាគធំ មានមធ្យោបាយនិងជំរើសការងារតិចតួច ដើម្បីទប់ទល់នឹងការប៉ះទង្គិចលើប្រាក់ចំណូល និងចំណាយប្រើប្រាស់ ដោយសារវិបត្តិសេដ្ឋកិច្ចសាកល ។ កម្ពុជាមិនបានគេចផុតពីវិបត្តិសេដ្ឋកិច្ចសាកលទេ ទោះបីរដ្ឋាភិបាល បានប្រើគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចល្អត្រឹមត្រូវក៏ដោយ ។ យុទ្ធសាស្ត្រដោះស្រាយរបស់ជនក្រីក្រ និងងាយរងគ្រោះ នៅមុន និងនៅក្រោយពេលមានវិបត្តិ វាមានប្រសិទ្ធភាពតិចតួច បើធៀបនឹងផលប៉ះពាល់នានា ។ ចំលើយតបខាងគោលនយោបាយជាក់លាក់ផ្សេងៗរបស់កម្ពុជា ទៅនឹងវិបត្តិហិរញ្ញវត្ថុសាកល ទំនងមានដំណើរការយឺត ហើយការវិវត្តមិនទៀងទាត់នៃវិស័យជំរុញកំណើនរបស់កម្ពុជា នឹងបន្តប៉ះពាល់ដល់ជីវភាពប្រជាជននៅថ្ងៃខាងមុខទៀត ។

ការវាយតម្លៃនេះ ព្យាយាមពិនិត្យពី៖ (១) លក្ខណៈដើមហេតុ និងទំហំបំលាស់ប្តូរក្នុងស្ថានភាពរបស់បុគ្គល និងគ្រួសារនៅពេលសេដ្ឋកិច្ចកម្ពុជាកំពុងចាប់ផ្តើមរើបចេញពីវិបត្តិនេះ (២) ការប្រែប្រួលក្នុងយុទ្ធសាស្ត្រដោះទ័ល របស់ក្រុមជនងាយរងគ្រោះផ្សេងៗ និង (៣) ប្រសិទ្ធភាព និងការគ្របដណ្តប់នៃប្រព័ន្ធសុវត្ថិភាពសង្គម ។

ការវាយតម្លៃនេះជាជុំទីបួន និងជាជុំចុងក្រោយ នៃការសិក្សាមួយអនុវត្តដោយ CDRI ក្នុងខែកុម្ភៈ ២០១០ ក្រោមហិរញ្ញប្បទានពីធនាគារពិភពលោក ។ ការវាយតម្លៃបីជុំមុន ធ្វើឡើងក្នុងខែឧសភា សីហា និង វិច្ឆិកា ២០០៩ ដែលជាការសិក្សាជាក្រុមមានរយៈពេល ៣ខែ នៅខេត្តសៀមរាប បាត់ដំបង ព្រៃវែង កំពត កណ្តាល កំពង់ស្ពឺ និងក្រុងភ្នំពេញ ។ ការវាយតម្លៃជុំទីបួននេះជាការសិក្សាបែបគុណភាព ដែលរួមមាន ១៧ ការពិភាក្សាតាមក្រុមស្នូល (FGDs) ជាមួយនឹងគ្រួសារនៅជនបទ ក្នុង ៦ ភូមិខុសៗគ្នា និង ១១ ក្រុមពលករងាយរងគ្រោះក្នុង ៣ វិស័យជំរុញកំណើន គឺវិស័យកាត់ដេរ ទេសចរណ៍និងសេវាកម្ម និងសំណង់ ។ ដោយសារទំហំគំរូតាងតូច ដូច្នេះលទ្ធផលរកឃើញ និងការបកស្រាយ មិនអាចយកទៅប្រើសំរាប់ពលករក្រីក្រ និងងាយរងគ្រោះទាំងអស់នៅកម្ពុជាទេ ប៉ុន្តែអាចជួយបំភ្លឺ និងផ្តល់គំនិតមួយចំនួនពីបែបបទដែលការប៉ះទង្គិចលើសេដ្ឋកិច្ចនាពេលថ្មីៗ បានប៉ះពាល់ដល់ពលករងាយរងគ្រោះ និងគ្រួសារក្រីក្រនានា ។

## លទ្ធផលរកឃើញសំខាន់ៗ

### បំលាស់ប្តូរចំបងៗក្នុងជីវភាពរស់នៅ និងផលប៉ះពាល់ផ្សេងៗ

FGDs រាយការណ៍ពីបំលាស់ប្តូរជាវិជ្ជមាន និងអវិជ្ជមាន ក្នុងរយៈពេល ៣ខែកន្លងទៅ ដែលទំនងកើតចេញពីប្រភពចំបងៗ ៣គឺ៖ (១) ការវិវត្តសេដ្ឋកិច្ចក្នុងពេលថ្មីៗ និងចំណាយរស់នៅខ្ពស់ (២) លក្ខខណ្ឌធម្មជាតិ និង (៣) បំលាស់ប្តូរជីវភាពរស់នៅតាមរដូវ ។

ការរើបឡើងនៃវិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ ផុសឡើងស្របគ្នានឹង ការរើបឡើងវិញនៃសេដ្ឋកិច្ចសាកល ។ FGDs បានរាយការណ៍ពីបំលាស់ប្តូរជាវិជ្ជមាននៃ ចំនួនការងារសំរាប់កម្មករកាត់ដេរ ក្នុងរោងចក្រចំនួន ៣ ដែលយើងបានចុះពិនិត្យ លើកលែងកម្មករធ្វើការក្នុងរោងចក្រកាត់ដេរ មិថុនា[២] ដែលបានប្រាប់ថា ពុំមានការងារថែមម៉ោងសំរាប់ធ្វើទេ ។[៣] កំណើនភ្ញៀវទេសចរមកដល់ខេត្តសៀមរាប បង្ហាញពីកំណើនចំនួនការងារអាចរកបាន និងចំណូលសំរាប់ អ្នកធ្វើការក្នុងវិស័យសេវាកម្ម (លើកលែង បុគ្គលិកភោជនីយដ្ឋាននៅទីក្រុងភ្នំពេញ) អ្នករត់ទុកទុក និងអ្នកលក់ដូរតូចតាច ។[៤] ការងារសំរាប់កម្មករសំណង់មានជំនាញបានកើនឡើងបន្តិចដែរ ដោយសារកំណើនគម្រោងសាងសង់តូចៗ និងសកម្មភាពនៅតាមការដ្ឋានសំណង់ចំបងៗមួយចំនួន ។ ប៉ុន្តែស្ថានភាពកម្មករគ្មានជំនាញវិញ ពុំមានរបាយការណ៍ថាបានល្អប្រសើរឡើងទេ ហើយមានខ្លះថែមទាំងប្រាប់ថា វាកាន់តែយ៉ាប់យ៉ឺនថែមទៀត ។ គ្រប់ក្រុមអ្នកឆ្លើយសម្ភាសន៍ និង

---

១ អត្ថបទនេះរៀបរៀងដោយ គីម សុធន ជាអ្នកស្រាវជ្រាវ ថេង វុទ្ធី ជាអ្នកសម្របសម្រួលកម្មវិធី និង ឈឹម ឈន់ ជាជំនួយការស្រាវជ្រាវនៃកម្មវិធី ភាពក្រីក្រ កសិកម្ម និងការអភិវឌ្ឍន៍ជនបទ របស់វិទ្យាស្ថាន CDRI ។ អ្នកនិពន្ធ សូមសំដែងការអរគុណដល់លោកស្រី ខៀវ ភិរម្យ កញ្ញា ផាន់ ដាលីស និង លោក យៀង សុធី សំរាប់ការជួយចូលរួមចំណែកក្នុងការសិក្សានេះ ។

២ មានទីតាំងនៅក្នុងសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

៣ ការនាំចេញសំលៀកបំពាក់សរុប នៅខែវិច្ឆិកា ២០០៩ មានជិតដល់ ២៥០លានដុល្លារ ធៀបនឹង ៦០លានដុល្លារ នៅខែកញ្ញា ២០០៩ (ស្ថិតិសេដ្ឋកិច្ច និងរូបិយវត្ថុ នៃ NBC) ។ ការរួមចុះសេដ្ឋកិច្ចកំពុងកើតមាននៅសហរដ្ឋអាមេរិក បានប៉ះពាល់ខ្លាំងណាស់ ដល់វិស័យកាត់ដេរកម្ពុជា (CDRI ខែវិច្ឆិកា ២០០៩) ។

៤ ចំនួនភ្ញៀវមកដល់កម្ពុជា នៅខែធ្នូ ២០០៩ មានប្រហែល ២០០.០០០នាក់ (CDRI ខែធ្នូ ២០០៩) ។

គ្រួសាររបស់ពួកគេ បន្តទ្រាំទ្រនឹងចំណាយរស់នៅខ្ពស់ និងការឡើងថ្លៃម្ហូបអាហារ ហើយបញ្ហានេះប៉ះពាល់ខ្លាំងលើ អ្នកជាក់ស៊ីក្លូ និងកម្មករសំណង់គ្មានជំនាញ ។

ទិន្នផលស្រូវខ្ពស់ គេទទួលបាននៅភូមិកំពង់ត្នោត បាបោង និងក្រសាំង ដោយសារមានភ្លៀងធ្លាក់គ្រប់គ្រាន់ ។[៥] ផលស្រូវល្អបានបង្កើនប្រាក់ចំណូលពីកសិកម្ម ដែលជួយឲ្យកសិករអាចសងបំណុលគេខ្លះ និងបង្កើនចំណាយប្រើប្រាស់របស់ខ្លួន ។ នៅភូមិទាំងបីនេះ ការសិក្សារកឃើញដូចគ្នាថា មូលធនកើតចេញពីប្រាក់ចំណូលបានពីកសិកម្ម ជួយកសិករធ្វើពិពិធកម្មសកម្មភាពចិញ្ចឹមជីវិតរបស់ខ្លួន ។ ប៉ុន្តែមិនមែនគ្រប់ភូមិសុទ្ធតែមានសំណាងដូចគ្នាទេ ។ លក្ខខណ្ឌធម្មជាតិមិនអំណោយផល ដូចជាភ្លៀងធ្លាក់ច្រើនពេកនៅរដូវច្រូតកាត់ និងការកើតសត្វចង្រៃបំផ្លិចបំផ្លាញ ធ្វើឲ្យផលស្រូវខូចខាតធ្ងន់ធ្ងរ ។ នៅភូមិត្រពាំងប្រីយ៍[៦] ការខូចខាតដំណាំស្រូវដោយសារកណ្ដុរ មាន ៣០% ធៀបនឹងទិន្នផលក្នុងឆ្នាំ២០០៨ ។ ទិន្នផលស្រូវ និងចំណូលពីស្រែចំការទាប នាំឲ្យគ្រួសារកសិករជួបការលំបាកកាន់តែខ្លាំងជៀសមិនផុត និងទំនងជាត្រូវខ្ចីបុលគេយ៉ាងច្រើន ។ ការងារក្រៅកសិដ្ឋាន និងប្រាក់ផ្ញើមកផ្ទះពីសមាជិកគ្រួសារធ្វើការក្នុងវិស័យកាត់ដេរ ឬសំណង់ ឬក្នុងប្រទេសថៃ គឺជាប្រភពចំណូលមួយទៀតសំរាប់គ្រួសារ ។

> *"អ្នកមានកូនប្រុស ឬកូនស្រី ឬសមាជិកគ្រួសារធ្វើការនៅទីក្រុង មានសំណាងជាងពួកខ្ញុំឆ្ងាយ ។ យ៉ាងហោចណាស់ ពួកគេមានអ្នកផ្ញើលុយមកឲ្យទិញម្ហូបអាហារ និងចាយវាយផ្សេងៗក្នុងគ្រួសារ ដូច្នេះមិនសូវភ័យថាអត់អីហូបនោះទេ ទោះបីធ្វើស្រូវមិនបានគ្រប់គ្គី ។" (ស្ត្រីៗក្នុង FGD នៅភូមិត្រពាំងប្រីយ៍)*

ប្រជាជនក្នុងភូមិសិក្សានានា ភាគច្រើនធ្វើការងារក្រៅកសិដ្ឋានតាមរដូវនៅមូលដ្ឋាន នៅក្នុង ឬនៅក្បែរភូមិរបស់ខ្លួន បន្ទាប់ពីច្រូតកាត់រួច ។ ការងារទាំងនេះភាគច្រើនជារបៀបប្រពៃណីក្នុងភូមិ និងមិនសូវប៉ះពាល់ខ្លាំងពីវិបត្តិសេដ្ឋកិច្ចទេ ។ តួយ៉ាងប្រជាជននៅភូមិកំពង់ត្នោត អាចនេសាទត្រីសមុទ្របានច្រើន ដោយសារមិនមានខ្យល់ខ្លាំង ហើយខ្លះទៀតធ្វើការក្នុងផលិតកម្មអំបិលនៅរដូវប្រាំង (ខែវិច្ឆិកា ២០០៩-កុម្ភៈ ២០១០)។ នៅភូមិបាបោង និងត្រពាំងប្រីយ៍ ប្រជាជនលក់ពលកម្មលីបាវស្រូវ អង្ករ លើកដី និងក្នុងផលិតកម្មស្ករត្នោតជាដើម ។

រៀងរាល់រដូវប្រាំង មានចលនាផ្លាស់ទីយ៉ាងធំមួយនៃកម្មករសំណង់មាន និងគ្មានជំនាញ ពីជនបទ ទៅទីក្រុង ហើយខ្លះទៀតធ្វើចំណាកស្រុកទៅធ្វើការតាមកសិដ្ឋាននៅប្រទេសថៃ ។ មានលក្ខខណ្ឌ២យ៉ាងដែលទំនងប៉ះពាល់លើក្រុមចំណាកស្រុក។ ទីមួយ កាលណាមានមនុស្សកាន់តែច្រើនឡើងមកទីក្រុងរកការងារធ្វើ ការប្រកួតប្រជែងផ្នែកការងារក៏កើនឡើងដែរជាពិសេសក្នុងចំណោមអ្នកជាក់ស៊ីក្លូ និងកម្មករសំណង់មាន និងគ្មានជំនាញ ។ កត្តានេះបានបន្ទាប ប្រាក់កម្រៃដែលថយចុះស្រាប់ហើយដោយសារវិបត្តិសេដ្ឋកិច្ច។ទីពីរ ពលករចំណាកស្រុកនៅភូមិអណ្ដូងត្រាច (ក្នុងឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង) និងភូមិក្រសាំង និយាយថា កំណើនការប្រើប្រាស់គ្រឿងចក្រកសិកម្មនៅតាមកសិដ្ឋាននៅប្រទេសថៃ បានគំរាមកំហែងដល់ការងាររបស់ខ្លួន ។ វិបត្តិសេដ្ឋកិច្ចសាកល ក៏បានកាត់បន្ថយតម្រូវការ និងថ្លៃផលិតផលកសិកម្មផងដែរ ។ បញ្ហានេះបណ្ដាលឲ្យកសិករថៃបោះបង់ដំណាំរបស់ខ្លួន ហើយកាត់បន្ថយតម្រូវការជួលពលករកម្ពុជាមកធ្វើការក្នុងកសិដ្ឋាន ។ ព្រឹត្តិការណ៍ទាំងនេះ ប៉ះពាល់ទាំងពលករចំណាកស្រុក និងគ្រួសាររបស់ពួកគេ ។

**បំលាស់ប្ដូរការងារ ចំណូល និងប្រាក់សន្សំ**

*ការងារអាចរកបាន*

ក្នុងអំឡុងពេលសិក្សាស្រាវជ្រាវ ការរើបសេដ្ឋកិច្ចទោះបីមិនទាន់ខ្លាំងក្ដី ក៏បានជះឥទ្ធិពលដោយផ្ទាល់កាន់តែច្រើនទៅលើវិស័យកាត់ដេរ ទេសចរណ៍ និងផ្នែកខ្លះនៃវិស័យសំណង់ ។ ពលករក្នុងវិស័យសេវាកម្ម និងកាត់ដេរ បញ្ជាក់ថា ស្ថានភាពការងារដែលអាចរកបាន សឹងតែគ្មានអ្វីប្រែប្រួល បើធៀបនឹងការសិក្សានៅជុំមុនៗ។ ការដ្ឋានសាងសង់ចំបងៗមួយចំនួននៅក្រុងភ្នំពេញ ដែលចាប់ដំណើរការឡើងវិញ បានជួយដល់កម្មករសំណង់មានជំនាញ ។ ផ្ទុយទៅវិញ តម្រូវការទាបនូវកម្មករសំណង់គ្មានជំនាញ បានបន្តដដែលនៅខែកុម្ភៈ ស្របពេលចំនួនកម្មករបានកើនឡើង ។ កម្មករភាគច្រើន រកការងារធ្វើបានតិចជាង ១០ថ្ងៃ/ខែ ។ ចំនួនថ្ងៃធ្វើការសំរាប់អ្នកជាក់ស៊ីក្លូ និងកម្មករភោជនីយដ្ឋាននៅក្រុងភ្នំពេញ គ្មានប្រែប្រួលទេ ប៉ុន្តែពួកគេប្រាប់ថា អតិថិជនបានថយចុះចំនួន ។

*ប្រាក់កំរៃ*

ធៀបនឹងការសិក្សានៅជុំទី៣ អ្នកជាក់ស៊ីក្លូ និងកម្មករភោជនីយដ្ឋាន រកចំណូលប្រចាំថ្ងៃបានដូចមុន ប្រសិនបើពួកគេធ្វើការលើសមុន ២ម៉ោង រាល់ថ្ងៃ ។ កម្មករសំណង់គ្មានជំនាញទទួលបានប្រាក់កំរៃតិចជាងមុន ត្រឹម ១៣.០០០រៀល/ថ្ងៃ ឬ ១០% ទាបជាងការវាយតម្លៃកាលពី ៣ខែមុន ។ ស្រដៀងគ្នាដែរ ពលករចំណាកស្រុកពីភូមិអណ្ដូងត្រាច និងភូមិក្រសាំង ដែលទៅធ្វើការតាមកសិដ្ឋាននៅប្រទេសថៃ ទទួលបានកំរៃ ៤០% តិចជាងការវាយតម្លៃនៅជុំទី៣ ។ អ្នករត់ទុកទុក និងអ្នកលក់ដូរតូចតាចនៅខេត្តសៀមរាប បានឆ្លើយសម្ភាសន៍ប្រាប់ថា រកចំណូលបាន ៥ដុល្លារ និង ៣ដុល្លាររៀងគ្នា ដោយសារកំណើនភ្ញៀវទេសចរ ។ កម្មករភោជនីយដ្ឋាន និងសណ្ឋាគារនៅសៀមរាប ប្រាប់ថា ពួកគេទទួលបានបៀវត្សរ៍ និងប្រាក់ទឹកតែច្រើនជាងមុនបន្តិច ។

*ប្រាក់សន្សំ និងប្រាក់ផ្ញើមកផ្ទះ*

ការរើបសេដ្ឋកិច្ចនាពេលថ្មីៗ ទំនងជះឥទ្ធិពលខ្លាំងទៅលើការងារដែលអាចរកបាន និងចំណូលសំរាប់កម្មករកាត់ដេរ និងកម្មករខាងសេវាកម្មនិងទេសចរណ៍ ។ កម្មករកាត់ដេរ អាចផ្ញើប្រាក់ពី ៣០-៦០ដុល្លារ ទៅឲ្យក្រុមគ្រួសារជារៀងរាល់ខែ ។ ប៉ុន្តែប្រាក់សន្សំ និងប្រាក់ផ្ញើទៅផ្ទះ បន្តធ្លាក់ចុះ សំរាប់អ្នកជាក់ស៊ីក្លូ កម្មករសំណង់

---

៥ ភូមិកំពង់ត្នោត ស្ថិតក្នុង ឃុំកូនសត្វ ស្រុកកំពត ខេត្តកំពត ។ ភូមិបាបោង ស្ថិតក្នុង ឃុំបាបោង ស្រុកពាមរ ខេត្តព្រៃវែង ។ ភូមិក្រសាំង ស្ថិតក្នុង ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង ។

៦ ភូមិត្រពាំងប្រីយ៍ ស្ថិតក្នុង ឃុំក្សេមក្សាន្ត ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

គ្មានជំនាញ និងពលករចំណាកស្រុក ព្រោះពួកគេរកការងារធ្វើបានតិចជាងមុន និងទទួលបានកំរៃទាបជាងមុន ។ FGDs ក្នុងភូមិចំនួន ៦ បង្ហាញពីកំណើនចំណូលតាមរដូវសម្រាប់គ្រួសារជាទូទៅ បើធៀបនឹងការសិក្សានៅជុំទី៣ ដោយសារមានការងារក្រៅកសិដ្ឋានធ្វើច្រើន ។ ប៉ុន្ដែការប្រែប្រួលនេះមិនសូវធំដុំទេ បើធៀបនឹងអំឡុងពេលដូចគ្នាកាលពីឆ្នាំមុន ។ តួយ៉ាងអ្នកភូមិកំពង់ត្នោតរកចំណូលបាន ១៤០.០០០រៀល/ខែ ពីការងារក្នុងផលិតកម្មអំបិលហើយអ្នកភូមិបាបោងរកបានពី២០.០០០-៣០.០០០រៀល ពីការធ្វើនំលក់ ដែលការងារទាំងនេះ មិនមានធ្វើទេកាលពីការសិក្សានៅជុំទី៣ ។ ថ្លៃអាហារខ្ពស់ និងចំណាយរស់នៅខ្ពស់បណ្ដាលជាចំបងពីការធ្លាក់ចុះប្រាក់សន្សំ និងប្រាក់ផ្ញើមកផ្ទះ ។

### ការបែងចែកកំលាំងពលកម្មក្នុងក្រុមគ្រួសារ

ការងារអាចរកបានតាមរដូវកាល និងការរើបសេដ្ឋកិច្ចនាពេលថ្មីៗហាក់ដូចបានកំណត់នូវការបែងចែកកំលាំងពលកម្មក្នុងគ្រួសារ ។ ដូចក្នុងការសិក្សាស្រាវជ្រាវជុំមុនដែរ សមាជិកពេញវ័យក្នុងគ្រួសារជាពិសេសឪពុកម្ដាយ ធ្វើទាំងការងារនៅកសិដ្ឋាន និងការងារក្រៅកសិដ្ឋានយកប្រាក់កម្រៃ ។ ឱកាសការងារនៅតាមជនបទទាំងនេះប្រែប្រួលតាមស្ថានភាពសេដ្ឋកិច្ច និងរដូវកាល ។ ការសិក្សាស្រាវជ្រាវជុំនេះ មិនបានរកឃើញសញ្ញាអ្វីថា ការធ្លាក់ចុះសេដ្ឋកិច្ច ធ្វើឲ្យប្រជាជននៅជនបទធ្វើការលំបាកជាងពីមុនទេ ប៉ុន្ដែ FGDs បង្ហាញថា ការស្វែងរកការងារតឹងតែងជាងមុន ។ នៅតាមភូមិស្ដ្រីនៅតែបន្ដធ្វើការងារក្នុងផ្ទះភាគច្រើន ដោយមានជំនួយខ្លះៗពីកុមារជាកូនៗរបស់ខ្លួន ដូចជា ការបេះប្រមូលផលពីធនធានទ្រព្យរួមជាដើម (ឧ. របស់ហូបរកពីវាលស្រែ) ។

នៅភូមិកំពង់ត្នោតមានករណីដែលឪពុកម្ដាយបានបញ្ឈប់ការសិក្សាកូនៗ ដើម្បីឲ្យជួយការងារផ្ទះ ឬឲ្យធ្វើការក្នុងផលិតកម្មអំបិល (ក្រសួងការងារបានឲ្យដឹងថា ការងារនេះស្ថិតក្នុងចំណោមទំរង់អាក្រក់ៗបំផុតនៃពលកម្មកុមារ) ។ យុវជនឬកុមារស្ថិតក្នុងវ័យកំពុងលូតលាស់ធំ ភាគច្រើនធ្វើការងារប្រភេទខ្លះដើម្បីរកកំរៃក្នុងរោងចក្រកាត់ដេរ ការដ្ឋានសំណង់ កសិដ្ឋានក្នុងប្រទេសថៃ ឬផ្នែកនេសាទ ។ ពួកគេស្ថិតក្នុងចំណោមអ្នករកចំណូលសំខាន់ៗសំរាប់គ្រួសារ ។ ម៉ោងធ្វើការផ្អែកលើការងារអាចរកបានដែលប្រែប្រួលទៅតាមស្ថានភាពសេដ្ឋកិច្ច ។ កម្មករសំណង់មាន និងគ្មានជំនាញ អះអាងថាបានខំស្វែងរកការងារធ្វើណាស់ រីឯអ្នកធាក់ស៊ីក្លូទទួលធ្វើការងារផ្សេងទៀតដូចជា លីសែងទំនិញជាដើម ។

### យុទ្ធសាស្ត្រដោះស្រាយ

សកម្មភាពនានាដើម្បីទប់ទល់នឹងការប៉ះទង្គិចពីលក្ខខណ្ឌធម្មជាតិមិនអំណោយផល ឬវិបត្តិសេដ្ឋកិច្ច គឺប្រហែលគ្នានឹងការរកឃើញក្នុងការសិក្សាជុំមុនដែរ ប៉ុន្ដែមានលំនាំខុសគ្នាបន្ដិច ។

*បម្រែបម្រួលលំនាំចំណាយ*

ការកាត់បន្ថយចំណាយប្រើប្រាស់មិនមែនអាហារ នៅតែជាយុទ្ធសាស្ត្រសំខាន់សម្រាប់ទប់ទល់នឹង ទំនិញឡើងថ្លៃ ចំណាយរស់នៅខ្ពស់ និងការប៉ះទង្គិចផ្សេងៗទៀត ។ ធៀបនឹងការសិក្សានៅជុំទី៣ ក្នុងពេលចាប់ផ្ដើមឆ្នាំសិក្សាថ្មី យើងឃើញមានបម្រែបម្រួលក្នុងចំណាយប្រើប្រាស់មិនមែនអាហារ ដូចជា ចំណាយព្យាបាលសុខភាពបន្ទាន់ និងចំណាយលើការសិក្សារបស់កូនៗ ជាដើម ។

ការសិក្សាជុំនេះ មិនសូវឃើញមាន យុទ្ធសាស្ត្រដោះស្រាយដោយកាត់បន្ថយចំណាយលើអាហារទៀតទេ ពីព្រោះទើបប្រមូលផលបានថ្មីៗ ហើយសេដ្ឋកិច្ចក៏រើបឡើងវិញ ។ ដូច្នេះពលករ និងក្រុមគ្រួសារនៅជនបទ អាចរក្សារបបអាហារគ្រប់គ្រាន់បាន ទោះបីអាហារនោះមានគុណភាពទាបជាងមុនក្ដី ។ ការសិក្សារកឃើញ កំណើនចំណាយលើអាហារបន្ដិច ក្នុងគ្រប់ក្រុមឆ្លើយសម្ភាសន៍ ដោយសារអាហារឡើងថ្លៃ មិនមែនដោយសារគុណភាពអាហាររបស់ពួកគេល្អជាងមុននោះទេ ។ អ្នកធាក់ស៊ីក្លូ ត្រូវចំណាយលើសមុន ៥០០-១០០០រៀល ក្នុងអាហារមួយពេល បើធៀបនឹងលទ្ធផលនៃការសិក្សាក្នុងជុំទី៣ ។ ប៉ុន្ដែក្នុងការសិក្សាលើកនេះ គុណភាព និងបរិមាណអាហាររបស់កម្មករសំណង់គ្មានជំនាញ មិនមានផ្លាស់ប្ដូរទេ ។ យុទ្ធសាស្ត្រដោះស្រាយផ្សេងៗទៀតលើកឡើងដោយកម្មករកាត់ដេរ ដើម្បីទប់ទល់នឹងការឡើងថ្លៃអាហារ រួមមាន ការហូបរួម (ទិញ ចំអិន និងហូបអាហាររួមគ្នាមួយក្រុម) និងការសុំឲ្យឪពុកម្ដាយផ្ញើអង្ករពីផ្ទះ ជាដើម ។

> *"ការហូបអាហារមានគុណភាពទាប មិនល្អសំរាប់យើងទេ ព្រោះការងារយើងត្រូវប្រើកំលាំងកាយ... ពីមុនយើងតែងហូបនំចំណីផ្សេងៗ ថែមលើអាហារហូបទៀងពេល ប៉ុន្ដែឥឡូវនេះ យើងមានអារម្មណ៍អស់កំលាំងជាងមុន បន្ទាប់ពីធ្វើការរួច" (FDG ជាមួយកម្មករសំណង់មានជំនាញ)។*

*ការទប់ទល់នឹងការប៉ះទង្គិចពីទីផ្សារពលកម្ម និងតម្រូវការការងារទាប*

កម្មករសំណង់មាន និងគ្មានជំនាញ កម្មករកាត់ដេរ អ្នកធាក់ស៊ីក្លូ អ្នករត់ទុកទុក អ្នកលក់ដូរតូចតាច កម្មករភោជនីយដ្ឋាន និងពលករចំណាកស្រុក បានប្រើយុទ្ធសាស្ត្រខុសៗគ្នា ដើម្បីទប់ទល់នឹងការប៉ះទង្គិចពី ទីផ្សារពលកម្ម និងតម្រូវការការងារទាប ។ ក្រៅពីព្រមទទួលយកប្រាក់កំរៃទាប ដោយសារមានការប្រកួតប្រជែងកាន់តែតឹងតែង កម្មករសំណង់គ្មានជំនាញជារឿយៗត្រូវទៅតាម និងរក្សាទំនាក់ទំនងល្អជាមួយមេការ ដើម្បីទទួលបានការងារធ្វើ ។ កម្មករសំណង់មានជំនាញជាច្រើនប្រាប់ថា ធ្លាប់បានទៅស្វែងរកការងារនៅការដ្ឋានផ្សេងទៀត ដែលផ្ដល់កំរៃច្រើនជាងដែរ ។ កម្មករកាត់ដេរច្រើនប្ដូរកន្លែងពីរោងចក្រតូចទៅរោងចក្រធំ ដើម្បីទទួលបានការងារល្អជាងមុន ។ ក្រៅពីព្រមបញ្ចុះថ្លៃឈ្នួល អ្នកធាក់ស៊ីក្លូត្រូវធ្វើដំណើរចុះឡើង ដើម្បីស្វែងរកអតិថិជន និងត្រូវធ្វើការលើសមុន ២ម៉ោង ក្នុងមួយថ្ងៃ បើធៀបនឹងឆ្នាំមុន ។ អ្នកលក់ដូរតូចតាច និងអ្នករត់ទុកទុក ត្រូវប្រកួតប្រជែងទាញយកអតិថិជន ដោយបញ្ចុះទាបបំផុតនូវថ្លៃទំនិញ និងថ្លៃសេវាដឹកអ្នកដំណើរ ។ អ្នកលក់ដូរតូចតាច បានបង្កើនចំនួនមុខផលិតផល ដើម្បីទាក់ទាញអតិថិជន ។

កម្មករតាមភោជនីយដ្ឋាននៅទីក្រុងភ្នំពេញ និយាយថាដោយសារអតិថិជនថយចុះ ភោជនីយដ្ឋានកន្លែងខ្លួនធ្វើការ បានបង្កើតការផ្សាយទាក់ទាញ ដូចជា ផ្ដល់អាហារបន្ថែមដោយឥត

គិតថ្លៃបញ្ចុះថ្លៃអាហារ យកចិត្តទុកដាក់ខ្លាំងលើបញ្ហាអនាម័យ និងគ្រប់គ្រងតឹងរឹងលើ ពេលម៉ោងធ្វើការ ម៉ោងសម្រាកហូបបាយ និងម៉ោងចេញពីធ្វើការរបស់បុគ្គលិកជាដើម ។ ពលករចំណាកស្រុក ហាក់ដូចគ្មានយន្តការអ្វីសម្រាប់ទប់ទល់នឹង ការថយចុះតម្រូវការជួលពលករនៅតាមកសិដ្ឋានក្នុងប្រទេសថៃទេ ។ អ្នកខ្លះនៅទំនេរក្នុងភូមិរង់ចាំការងារ អ្នកខ្លះរកបានការងារនៅតំបន់ផ្សេង ។ រឿងរ៉ាវជាក់ស្តែងមួយចំនួនបង្ហាញថា នៅភូមិអណ្តូងត្រាចជីវភាពរបស់ប្រជាជន ពឹងពាក់តិចជាងមុនទៅលើ ធនធាននៃបឹងទន្លេសាប ។

*ការខ្ចីបុល និងការលក់ទ្រព្យសម្បត្តិ*

ការខ្ចីបុល នៅតែជាយុទ្ធសាស្ត្រដ៏សំខាន់មួយសំរាប់ដោះស្រាយការលំបាកក្នុងជីវភាព ។ ចំនួនការងារថយចុះ បានបង្ខំឲ្យពលករចំណាកស្រុកខ្ចីប្រាក់កាន់តែច្រើន ពីស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) សំរាប់ចំណាយលើថ្លៃរស់នៅ ឬថ្លៃធ្វើចំណាកស្រុកទៅស្វែងរកការងារ ។ កម្មករសំណង់គ្មានជំនាញ និងកម្មករភោជនីយដ្ឋានត្រូវទៅរកខ្ចីប្រាក់ពីមិត្តភក្តិ សាច់ញាតិ អ្នកចងការប្រាក់ ឬមេការសម្រាប់ចំណាយលើថ្លៃរស់នៅ ។ អ្នកជាក់ស៊ីក្លូខ្លះ ទៅខ្ចីប្រាក់ពីអ្នកចងការប្រាក់ ឬ MFI ដោយដាក់ដីធ្លីខ្លួនជាបរបស់ធានា ដើម្បីយកប្រាក់ទៅទិញម៉ូតូ មកប្រកបរបរជាអ្នករត់ម៉ូតូឌុបវិញ ។ គ្រួសារជាច្រើននៅជនបទ បានជាប់បំណុលកាន់តែច្រើន ដោយសារព្រឹត្តិការណ៍ក្នុងគ្រួសារ ដូចជា ការរៀបការកូនចៅជាដើម ។ ការទិញធាតុចូលកសិកម្មដោយប្រើ ឥណទានមានការប្រាក់ខ្ពស់ធ្វើឲ្យកសិករត្រូវសងប្រាក់យ៉ាងច្រើន ទៅឲ្យពាណិជ្ជករជាម្ចាស់បំណុល ។ ទិន្នផលស្រូវទាបនៅតាមភូមិដែលរងការខូចខាតផលដំណាំដោយសារ ការបំផ្លិចបំផ្លាញដោយសត្វចង្រៃ និងភ្លៀងធ្លាក់ខ្លាំងជាដើម ក៏នឹងបង្កកំណើនបំណុលស្ទើរជៀសមិនផុត ចំពោះគ្រួសារនៅតាមភូមិទាំងនោះ នៅឆ្នាំខាងមុខ ។ គ្រួសារនានាដែលមិនអាចសងបំណុលទៅឲ្យ MFI ឬ ធនាគារបាន ត្រូវទៅរកខ្ចីប្រាក់ពីប្រភពដទៃទៀត ដូចជា អ្នកចងការប្រាក់ក្នុងភូមិជាដើម ទោះបីមានការប្រាក់ខ្ពស់ក៏ដោយ ដើម្បីយកទៅសងបំណុល ព្រោះខ្លាចបាត់បង់ផ្ទះ ឬដីដែលខ្លួនដាក់ធានា ។ ការសងកំចីដោយប្រើកំចីមួយទៀត វាបង្កការលំបាកមួយជាន់ថែមទៀត ។

ករណីលក់ទ្រព្យសម្បត្តិ ឃើញមានរាយការណ៍តិចតួចបំផុតនៅក្នុង FGDs ដែលអាចមកពីមូលហេតុពីរយ៉ាងគឺៈ ទីមួយ គ្រួសារប្រហែលគ្មានទ្រព្យអ្វីសំរាប់លក់ទៀត ដូចជា នៅភូមិដូនវង្សក្នុងស្រុកកណ្តាលស្ទឹងខេត្តកណ្តាលនិងភូមិអណ្តូងត្រាចជាដើម។ ទីពីរ កំណើនការងារឡើងវិញក្នុងវិស័យកាត់ដេរ អាចជួយដល់គ្រួសារនៅតាមជនបទ តាមរយៈប្រាក់ផ្ញើមកផ្ទះ និងប្រាក់ចំណូលពីការងារក្រៅកសិដ្ឋាន ដែលពួកគេរកបានក្នុងអំឡុងពេលធ្វើការសិក្សានេះ ។ ការលក់សត្វចិញ្ចឹម នៅពេលត្រូវការប្រាក់ ជារបៀបអនុវត្តទូទៅមួយ បើតាមសំដីរបស់អ្នកភូមិជាច្រើន ។

**ជំនួយសង្គម និងទំនាក់ទំនងសង្គម**

ដូចការសិក្សានៅជុំមុនៗដែរ យើងមិនឃើញមានជំនួយសង្គមជាផ្លូវការអ្វីថ្មីពីរដ្ឋាភិបាល ឬទីភ្នាក់ងារអភិវឌ្ឍន៍ សម្រាប់ជួយប្រជាជនទប់ទល់នឹងវិបត្តិ ក្នុងអំឡុងពេលសិក្សានេះទេ (ខែធ្នូ ២០០៩-កុម្ភៈ ២០១០) ។ សេវាសង្គមដែលមានស្រាប់ រួមមាន ការចាក់ថ្នាំបង្ការ និងការបែងចែកអាហារូបត្ថម្ភសំរាប់កុមារ និងស្ត្រីមានគភ៌ ។ នៅភូមិត្រពាំងប្រីយ៍ អ្នកស្រុកទទួលបានអត្ថប្រយោជន៍ពីកម្មវិធីអភិវឌ្ឍន៍ជនបទគ្រប់ជ្រុងជ្រោយមួយ របស់អង្គការទស្សនៈពិភពលោកអន្តរជាតិ ដែលមានដូចជា ការផ្តល់សត្វចិញ្ចឹម និងអនាម័យក្នុងសហគមន៍ជាដើម ។ សំរាប់កម្មករកាត់ដេរ សមាជិកភាពក្នុងសហជីពកម្មករ បានផ្តល់ជំនួយទ្រទ្រង់ឲ្យពួកគេក្នុងការចរចាជាមួយម្ចាស់រោងចក្រ ។ ចំណុចនេះឆ្លុះបញ្ចាំងពីកង្វះខាតកម្មវិធីការពារសង្គម សំរាប់ជនក្រីក្រ និងងាយរងគ្រោះ ប៉ុន្តែមានបណ្តាញសន្តិសុខសង្គមក្រៅផ្លូវការផ្សេងៗ បានមកជំនួស ឬជួយបំពេញដល់បណ្តាញជាផ្លូវការ ។ អ្នកផ្តល់ព័ត៌មានគ្រប់គ្នាក្នុង FGDs ប្រាប់ថា ការជួយគ្នាទៅវិញទៅមក ចំណងសាច់ញាតិ និងសាមគ្គីភាពក្នុងក្រុម គឺជាបណ្តាញសន្តិសុខសង្គមដែលអាចពឹងពាក់បានក្នុងគ្រាលំបាក ឬនៅពេលមានតម្រូវការជំនួយបន្ទាន់ ។

## សេចក្តីសន្និដ្ឋាន

ការវាយតម្លៃជុំទីបួននេះ បានបញ្ជាក់នូវកំណើនដ៏ទៀងទាត់នៃវិស័យកាត់ដេរនិងទេសចរណ៍ព្រមទាំងការរើបនៃវិស័យសំណង់។ ការស្ទុះឡើងវិញនៃវិស័យដែលរងការប៉ះទង្គិចខ្លាំងទាំងនេះ បានជួយកែលំអខ្លះៗ ដល់ជីវភាពរស់នៅរបស់កម្មករងាយរងគ្រោះជាច្រើន និងក្រុមគ្រួសាររបស់ពួកគេ ។ ទោះជាវិបត្តិសេដ្ឋកិច្ចបានធូរស្រាលមកវិញក្តី ប៉ុន្តែផលប៉ះពាល់អវិជ្ជមានរបស់វា នៅតែបន្តកើតមានលើ កម្មករសំណង់គ្មានជំនាញ អ្នកជាក់ស៊ីក្លូ កម្មករភោជនីយដ្ឋាន និងពលករចំណាកស្រុក ក្នុងទម្រង់ជាការថយចំនួនប្រាក់ចំណូល និងការងារអាចរកបាន ។ គេមិនឃើញមានបំលាស់ប្តូរអ្វីគួរកត់សំគាល់ ទាក់ទងនឹងចំណាយលើអាហារ និងទំនិញមិនមែនអាហារ របស់ក្រុមពលករទាំងនេះទេ ។

យន្តការផ្សេងៗសម្រាប់ទប់ទល់នឹងវិបត្តិ រួមមានៈ (១) ការកាត់បន្ថយចំណាយប្រើប្រាស់មិនមែនអាហារ និងគុណភាពអាហារ (២) ការបន្តស្វែងរកការងារ ការធ្វើការខ្លាំងជាងមុន និងការកែតម្រូវយុទ្ធសាស្ត្រធ្វើអាជីវកម្ម (៣) ការខ្ចីបុល និងលក់ទ្រព្យសម្បត្តិ ។ ប្រជាជនបន្តទទួលបានការទ្រទ្រង់ពីបណ្តាញសន្តិសុខសង្គមក្រៅផ្លូវការ ក្នុងគ្រាជួបការលំបាកខ្លាំង ។ សេវាសង្គមតិចតួចដែលអាចរកបាន មិនអាចឆ្លើយតបគ្រប់គ្រាន់ទៅនឹងវិបត្តិសេដ្ឋកិច្ចទេ ។ ចំណុចនេះបង្ហាញថា គួរពង្រីកវិសាលភាពនៃប្រព័ន្ធសន្តិសុខសង្គមផ្លូវការ ។ ការរើបយឺតនៃវិស័យជំរុញកំណើននានា ធ្វើឲ្យប្រជាជនដែលពឹងពាក់លើវិស័យទាំងនោះជួបការលំបាក ។ ដូច្នេះត្រូវធ្វើពិពិធកម្មវិស័យជំរុញកំណើន ដើម្បីធានាឲ្យកំណើនកាន់តែមានចីរភាព ។ ការធានាឲ្យអត្ថប្រយោជន៍នៃកំណើនបានទៅដល់ប្រជាជនក្រីក្រមួយភាគធំ ដែលច្រើនរស់នៅទីជនបទ និងការជំរុញវិស័យអភិវឌ្ឍន៍តិចជាងគេ ដូចជាកសិកម្មជាដើម គួរយកមកគិតគូរខ្លាំងជាងគេ ៕

## ឯកសារយោង

សូមមើលក្នុងឯកសារជាភាសាអង់គ្លេស ។

# មនុស្សវ័យចំណាស់គាំទ្រកម្មវិធីព្យាបាលដោយឱសថប្រឆាំងវីរុសអេដស៍ នៅខេត្តបន្ទាយមានជ័យ[១]

## សេចក្តីផ្តើម

នៅកម្ពុជា លទ្ធភាពទទួលបាន ការព្យាបាលដោយឱសថប្រឆាំងវីរុសអេដស៍ (ART) កើនឡើងយ៉ាងលឿននៅទសវត្សរ៍ចុងក្រោយនេះហើយបានធ្វើឲ្យប្រែប្រួលដល់ស្ថានភាពនិងបទពិសោធន៍របស់បុគ្គលទាំងឡាយ ដែលធ្វើការជិតស្និទ្ធនឹងការរីករាលដាលជម្ងឺអេដស៍ ។ រហូតមកដល់ពេលថ្មីៗនេះ នៅកម្ពុជា អ្នកផ្ទុកវីរុសអេដស៍ដែលបានឆ្លងជម្ងឺឱកាសនិយម (opportunistic infections) សុទ្ធតែត្រូវទ្រាំទ្រនឹងជម្ងឺដែលធ្វើឱ្យចុះខ្សោយ រហូតដល់ស្លាប់ដោយជៀសមិនផុត ។ ក្រៅពីអ្នកផ្ទុកវីរុសអេដស៍ ជម្ងឺឆ្លងនេះក៏ប៉ះពាល់ដល់សមាជិកគ្រួសារ ជាពិសេសឪពុកម្តាយដែលត្រូវទទួលរងផលវិបាកខាងផ្លូវចិត្ត សេដ្ឋកិច្ច និងសង្គម ក្នុងការមើលថែទាំ និងការស្លាប់កូនមុនអាយុបែបនេះ ។ ART ដែលកាន់តែសម្បូរ បានផ្លាស់ប្តូរទាំងស្រុងនូវស្ថានភាពពួកអ្នកដែលត្រូវប៉ះពាល់ដោយជម្ងឺនេះ ។ សព្វថ្ងៃដោយសារមាន ART ការឆ្លងជម្ងឺដោយសារតែអេដស៍ គឺអាចព្យាបាលបានយ៉ាងសក្តិសិទ្ធិ ហើយសុខភាពអ្នកជម្ងឺក៏បានល្អប្រសើរឡើងវិញ ។ ក្នុងពេលជាមួយគ្នាកំណើនការពិនិត្យឈាមរកវីរុសអេដស៍ ធ្វើឱ្យការព្យាបាលដោយ ARTអាចចាប់ផ្តើមនៅមុនពេលដែលជម្ងឺឱកាសនិយមដូចជារបេងជាដើម ចេញជារោគសញ្ញា និងបណ្តាលឱ្យអ្នកជម្ងឺចុះខ្សោយ ។ នៅពេលអ្នករស់នៅជាមួយវីរុសអេដស៍ និងជម្ងឺអេដស៍ (PLHA) មានសុខភាពប្រសើរឡើងវិញ ដោយសារ ART សមាជិកគ្រួសារអ្នកជម្ងឺក៏ទទួលបានអត្ថប្រយោជន៍ស្រដៀងគ្នា ពីព្រោះផលប៉ះពាល់អវិជ្ជមាននៃជម្ងឺបានថយចុះ ឬយ៉ាងហោចណាស់ក៏អាចពន្យារពេលបានយូរដែរ (សូមមើល ADI 2010) ។

ART បានប្រើសាកល្បងនៅកម្ពុជាក្នុងឆ្នាំ២០០១ ដោយអង្គការមិនមែនរដ្ឋាភិបាល Medecins Sans Frontieres, Medecins du Monde និង Centre for Hope ។ ទោះបីពីដំបូងរដ្ឋាភិបាល និងម្ចាស់ជំនួយ បានរារែកក្នុងការគាំទ្រដល់ ART ក្តីក៏លទ្ធផលបឋមបានធ្វើឱ្យក្រសួងសុខាភិបាលជឿជាក់ថា កម្មវិធី ART គឺអាចអនុវត្តបាន ។ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែកនិងកាមរោគ (NCHADS) បានទទួលគ្រប់គ្រងលើកម្មវិធីដែលបានរីកចម្រើនយ៉ាងលឿន ដោយមានការគាំទ្រដ៏សប្បុរសពីម្ចាស់ជំនួយ ។ ចំនួន PLHA ដែលប្រើប្រាស់ ART បានកើនពី ៧១នាក់ ក្នុងឆ្នាំ២០០១ ដល់ ១២.៣៥៥នាក់ ក្នុងឆ្នាំ២០០៥ និង ៣៧.៣១៥នាក់ ក្នុងឆ្នាំ២០០៩ (ក្រាហ្វិក ១) ។ យោងតាម

ក្រាហ្វិក ១៖ ចំនួន PLHA អ្នកប្រើ ART នៅកម្ពុជា នៅឆ្នាំ២០០១-០៩




ប្រភព៖ NCHADS (2009) ការថែទាំព្យាបាលសម្រាប់ PLHA នៅក្នុងពិភពលោក និងនៅកម្ពុជា និង NCHADS (2010) របាយការណ៍ស្តីពីការព្យាបាលដោយ ART សម្រាប់គ្រប់តំបន់នៅឆ្នាំ ២០០៩ ។

នាយកនៃ NCHADS តួលេខឆ្នាំ២០០៩ នេះ តំណាងឲ្យ ៩៥% នៃ PLHA ដែលត្រូវការ ART (Mean Chi Vun 2009) ។ ក្នុងពេលដែលប្រទេសកម្ពុជា កំពុងស្ថិតក្នុងដំណើរការកសាងប្រព័ន្ធសុខភាពសាធារណៈមួយដែលអាចរស់រានបាន លទ្ធផលនេះពិតជាជោគជ័យមួយគួរឱ្យកោតសរសើរ ។

## គោលបំណងនៃការស្រាវជ្រាវ

មនុស្សវ័យចំណាស់ភាគច្រើនត្រូវគេបំភ្លេចចោល ក្នុងការពិភាក្សាពីការឆ្លងរាលដាលវីរុសអេដស៍ ទោះបីតាមការពិត ពួកគាត់ជាប់ទាក់ទងខ្លាំងនឹងរឿងនេះក្តី ។ អត្ថបទនេះផ្តោតលើជំនួយទ្រទ្រង់របស់មនុស្សវ័យចំណាស់ ដល់សាច់ញាតិ និងកូនៗដែលផ្ទុកវីរុសអេដស៍ ក្នុងការប្រើប្រាស់ ART នៅខេត្តបន្ទាយមានជ័យ ។ ការសិក្សានេះព្យាយាម ពិនិត្យជាពិសេសពីតួនាទីនិងការចូលរួមរបស់មនុស្សចាស់ក្នុងការមើលថែទាំ និងជួយជំរុញការគោរពតាមវិធីព្យាបាល ធ្វើការវាយតម្លៃពីផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ និងសុខភាព ទៅលើមនុស្សចាស់ដែលផ្តល់ការថែទាំ ធ្វើការកំណត់ពីផលប៉ះពាល់នៃការប្រើប្រាស់ ART ចំពោះមនុស្សចាស់ និងកូនចៅសាច់ញាតិរបស់គាត់ និងស្វែងយល់ពីវត្តមាននិងសារៈសំខាន់នៃការបណ្តុះបណ្តាល ដែលផ្តល់ជូនពួកអ្នកមើលថែទាំមានវ័យចំណាស់ ។

## វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវបានអនុវត្តនូវវិធីសាស្ត្របែបគុណភាព និងបរិមាណ ។ នៅខែឧសភា ២០០៨ បញ្ជីសំណួរប្រវែងមួយទំព័របានយកមកប្រើប្រាស់ដើម្បីប្រមូលព័ត៌មានពីអ្នកទទួលARTចំនួន ៣៨២នាក់ ក្នុងឃុំជ្រើសរើសចំនួន ៦ នៅខេត្តបន្ទាយមានជ័យ ។ អង្កេតអ្នកទទួល ART នេះ បានជួយធ្វើឲ្យអង្កេតលើមនុស្សចាស់ផ្តល់លទ្ធផលកាន់តែសព្វគ្រប់ និងសមស្របតាមបរិបទ ។

---

១ អត្ថបទនេះរៀបរៀងដោយ ហាក់-សុចន្ទី ឃឿន-ចាន់ដូរ៉េ សូ-ដាណេ និង John McAndrew ជាសមាជិកក្រុមអនុវត្តនៃគម្រោងវិភាគបញ្ហាអភិវឌ្ឍន៍ (Analysing Development Issues - ADI) នៃគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ។ អ្នកស្រាវជ្រាវបានទទួលការណែនាំ និងការគាំទ្រពីបណ្ឌិត John Knodel, នៃមជ្ឈមណ្ឌលសិក្សាប្រជាសាស្ត្រ (Population Studies Center), សាកលវិទ្យាល័យ Michigan ។

នៅខែឧសភា ២០០៨ នៅក្នុងបណ្តាឃុំដដែល អ្នកឆ្លើយសម្ភាសន៍សរុប ១០៨ នាក់ មានវ័យ ៥០ឆ្នាំ ឬលើសពីនេះ និងមានកូនទទួល ART រស់នៅក្នុងគ្រួសារជាមួយគ្នា ឬរស់នៅបែកគ្នា ឬមានសាច់ញាតិនៃអ្នកទទួល ART រស់នៅក្នុងគ្រួសារជាមួយគ្នា ត្រូវបានជ្រើសរើស ដោយមានគោលដៅ ដើម្បីធ្វើអង្កេតពីបទពិសោធន៍របស់គាត់ក្នុងការមើលថែទាំ ។ នៅខែកក្កដា ២០០៨ អ្នកឆ្លើយសម្ភាសន៍ចំនួន ១០នាក់ នៅក្នុង ១០៨នាក់ ខាងលើ ត្រូវបានជ្រើសរើសមកធ្វើសម្ភាសន៍ស៊ីជម្រៅបែបគុណភាព ។ នៅរាជធានីភ្នំពេញ និងខេត្តបន្ទាយមានជ័យ ក្រុមសិក្សាក៏បានសម្ភាសមន្ត្រីរដ្ឋាភិបាលដែលចូលរួមក្នុងការផ្តល់ ART ហើយនិងអង្គការមិនមែនរដ្ឋាភិបាលដែលចូលរួមផ្តល់ការគាំទ្រដល់ការមើលថែទាំតាមផ្ទះ ។

## អ្នកទទួល ART រាយការណ៍អំពីការជួយថែទាំរបស់ឪពុកម្តាយ

អង្កេតអ្នកទទួល ART បង្ហាញថា ប្រមាណ ៦០% នៃអ្នកឆ្លើយសម្ភាសន៍ ៣៨២នាក់ នេះ យ៉ាងហោចណាស់មានឪពុកឬម្តាយនៅរស់ម្នាក់មើលថែទាំនិងជិត៧៥%នៃអ្នកដែលមានឪពុកនិង/ឬម្តាយនៅរស់ បានរស់នៅក្នុងគ្រួសារជាមួយ ឬនៅក្នុងតំបន់តែមួយជាមួយឪពុកម្តាយនោះ ។ លក្ខណៈនេះធ្វើឱ្យឪពុកម្តាយមានស្ថានភាពល្អក្នុងការពិនិត្យតាមដាន និងគាំទ្រដល់ការប្រើប្រាស់ ART ។ ជាង ៤០% នៃឪពុកម្តាយអ្នកទទួល ART និង ជិតពីរភាគបី នៃឪពុកម្តាយដែលរស់នៅជាមួយអ្នកទទួល ART តែងជួយរំឭកកូនគាត់ជារឿយៗ ឬជារៀងរាល់ថ្ងៃ ឱ្យលេបថ្នាំ ART ។ ឪពុកម្តាយមិនសូវចាស់ ជាពិសេសឪពុកម្តាយមិនសូវចាស់ដែលរស់នៅជាមួយអ្នកទទួលការព្យាបាល ART បានរំឭកកូនៗគាត់ឱ្យប្រើប្រាស់ ART ច្រើនជាងឪពុកម្តាយវ័យចំណាស់ (ក្រាហ្វិក ២) ។ លើសពីនេះទៀត ក្នុងចំណោមអ្នកទទួល ART ដែលមានឪពុកឬម្តាយនៅរស់ មានជាង ៦០% បានទទួលការរំឭកពីឪពុកឬម្តាយខ្លួនឱ្យទៅបើកថ្នាំពីមន្ទីរពេទ្យ ឬមណ្ឌលសុខភាព ហើយជិត ៣៣% មានឪពុកឬម្តាយម្នាក់ បានដឹកនាំ ឬជូនពួកគេទៅបើកថ្នាំ ។

## ឆន្ទៈរបស់មនុស្សចាស់ក្នុងការមើលថែទាំ

អង្កេតលើមនុស្សវ័យចំណាស់ បង្ហាញថា ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍វ័យចំណាស់ មកពី ១០៨គ្រួសារ មានអ្នកឆ្លើយសម្ភាសន៍ និង/ឬ ប្តីឬប្រពន្ធរបស់គាត់ មកពី ១០១គ្រួសារ (ឬ ៩៤%) ដែលបានមើលថែទាំកូនៗ និងសាច់ញាតិមានផ្ទុកវីរុសអេដស៍ ។ ម្យ៉ាងវិញទៀត ក្នុងចំណោមគ្រួសារទាំងនេះ ស្ត្រីវ័យចំណាស់តំណាងឲ្យ ៨២% នៃអ្នកមើលថែទាំបឋម ហើយគិតជារួម ស្ត្រីដែលជួយមើលថែទាំ មានចំនួនច្រើនជាងបុរស ។ ក្នុងចំណោមស្ត្រី ១០៧នាក់ មាន ៩៧នាក់ (៩១%) ហើយក្នុងចំណោមបុរស ៥២នាក់ មាន ៣៥នាក់ (៦៧%) ដែលបានផ្តល់ការថែទាំដល់កូនៗ ឬសាច់ញាតិមានផ្ទុកវីរុសអេដស៍ (ក្រាហ្វិក ៣) ។ មនុស្សចាស់ក្នុងអង្កេត ដែលមិនបានមើលថែទាំ បានផ្តល់មូលហេតុថាមកពីប្តីឬប្រពន្ធរបស់គាត់ឬប្តីឬប្រពន្ធរបស់អ្នកទទួល ART ឬ កូនៗរបស់ពួកគេ បានមើលថែទាំហើយ ។

តួនាទីធំក្នុងការមើលថែទាំរបស់ស្ត្រីវ័យចំណាស់ជារឿងគួរភ្ញាក់ផ្អើល បើពិចារណាទៅលើលក្ខណៈខាងប្រជាសាស្ត្រ និងសង្គមរបស់គាត់ ។ ស្ត្រីវ័យចំណាស់ភាគច្រើនបានលែងលះ ឬនៅមេម៉ាយ ឬចែកផ្លូវគ្នា ដោយគ្មានដៃគូជាទីពឹងឡើយ ។ ម្យ៉ាងទៀតប្រហែល ៥០% មិនធ្លាប់បានចូលរៀនទេ ៦៦% នៅធ្វើការងារចិញ្ចឹមក្រុមគ្រួសារ ហើយ ៥០% មានអាយុ ៦០ឆ្នាំ ឬលើសពីនេះ។ទោះមានការលំបាកយ៉ាងនេះក្តីក៏ស្ត្រីវ័យចំណាស់ជាទូទៅបានទទួលខុសត្រូវចំបងក្នុងការមើលថែទាំសាច់ញាតិ និងកូនៗដែលមានផ្ទុកវីរុសអេដស៍ ។

ក្រាហ្វិក ២៖ ភាគរយនៃអ្នកទទួល ART ដែលមានឪពុកម្តាយរំឭកជារឿយៗ ឬជារៀងរាល់ថ្ងៃ ឱ្យលេបថ្នាំ (គិតតាមអាយុនៃឪពុកម្តាយមិនសូវចាស់ នៅខេត្តបន្ទាយមានជ័យ ខែឧសភា ២០០៨)




ប្រភព៖ អង្កេតអ្នកទទួល ART ចំនួន ៣៨២នាក់

ក្រាហ្វិក ៣៖ អ្នកឆ្លើយសម្ភាសន៍វ័យចំណាស់ និង ប្តីឬប្រពន្ធរបស់គាត់ ដែលចូលរួមក្នុងផ្នែកទាំងបួននៃការមើលថែទាំ (ខេត្តបន្ទាយមានជ័យ ខែវិច្ឆិកា ២០០៨)




ប្រភព៖ អង្កេតមនុស្សវ័យចំណាស់

ការតស៊ូរបស់មនុស្សវ័យចំណាស់ ជាពិសេសស្ត្រី ក្នុងការមើលថែទាំសាច់ញាតិ និងកូនៗ មានផ្ទុកវីរុសអេដស៍ អាចមើលឃើញច្បាស់ក្នុងការស្រាវជ្រាវ ប៉ុន្តែកិច្ចការនេះបង្កបន្ទុកចំណាយដល់ពួកគាត់ ។ ជាង ៩០% នៃអ្នកឆ្លើយសម្ភាសន៍វ័យចំណាស់ត្រូវចំណាយប្រាក់មួយចំនួនក្នុងការមើលថែទាំ និងព្យាបាលសាច់ញាតិ និងកូនៗមានផ្ទុកវីរុសអេដស៍ ហើយរឿងនេះទំនងកើតមានតាំងពីមុនពេលទទួលបាន ART ដោយឥតគិតថ្លៃទៅទៀត ។ ក្នុងចំណោមមនុស្សវ័យចំណាស់ដែលបានចំណាយ មាន ៧១% បានចាយអស់ប្រាក់សន្សំ ៦២% បានខ្ចីលុយគេ ៣២% បានលក់ដី និង ៤៣% បានលក់មាសឬគ្រឿងអលង្ការ ។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ ៤១នាក់ ដែលមានសមាជិកគ្រួសារបានស្លាប់ដោយជម្ងឺអេដស៍ មាន ២៨នាក់ បានចំណាយប្រាក់មួយចំនួនទៅលើថ្លៃព្យាបាល និង ២៥នាក់បានចំណាយប្រាក់មួយចំនួនទៅលើថ្លៃបុណ្យសព ។ ទោះបីមានអ្នកឆ្លើយសម្ភាសន៍វ័យចំណាស់ជាង ៤០% បានត្អូញត្អែរអំពីសុខភាពទន់ខ្សោយ ឬទ្រុឌទ្រោមខ្លាំង ប៉ុន្តែពួកគាត់ ជាទូទៅមិនបានផ្សារភ្ជាប់បញ្ហាសុខភាពជាក់លាក់ទៅនឹងផលវិបាកនៃការមើលថែទាំឡើយ ។

## **លទ្ធផលនៃការប្រើប្រាស់** ART

"ART គឺជាថ្នាំទិព្វដែលទេវតាប្រទាន" ។ នេះជាសំដីរបស់ជីដូនម្នាក់អាយុ ៨១ឆ្នាំ ដែលបង្ហាញពីអារម្មណ៍របស់មនុស្សវ័យចំណាស់ជាច្រើនក្នុងចំណោម ១០៨នាក់ ដែលបានឆ្លើយសម្ភាសន៍ ។ មនុស្សវ័យចំណាស់ជាច្រើនដែលធ្លាប់មានកូន និងសាច់ញាតិ ឈឺជិតស្លាប់នៅនឹងភ្នែក ឥឡូវនេះបានឃើញច្បាស់ពីការធូរស្រាលដ៏អស្ចារ្យនៅពេលអ្នកជម្ងឺចាប់ទទួល ART ។

*កូនស្រីរបស់ខ្ញុំ បានទទួលការព្យាបាលជម្ងឺរបេងអស់ ៨ខែរួចហើយ មុនពេលទទួល ART ។ នាងស្រកទម្ងន់យ៉ាងច្រើនពី ៤៨គីឡូ មកនៅត្រឹម ៣០គីឡូ គឺនៅសល់តែស្បែកដណ្តប់ឆ្អឹងប៉ុណ្ណោះ ។ នាងកំពុងតែសម្រាកពេទ្យនៅពេលគេប្រាប់ខ្ញុំថា នាងកាន់តែធ្ងន់ធ្ងរឡើង ។ ខ្ញុំធ្វើដំណើរទៅមន្ទីរពេទ្យភ្លាម ហើយឃើញនាងដេកស្ងៀមនៅលើគ្រែ ប្រៀបដូចមនុស្សស្លាប់ ។ ខ្ញុំបានបន់ស្រន់កុំឱ្យនាងស្លាប់ ។ លោកគ្រូពេទ្យបានព្យួរសេរ៉ូមឱ្យនាង ។ ខ្ញុំបានអង្វរពេទ្យឱ្យជួយនាងផង ។ ឥឡូវនេះ បន្ទាប់ពីបានទទួល ART យូរខែមក នាងក៏បានធូរស្រាលឡើង ។ នាងចាប់ធ្វើការឡើងវិញហើយ ដោយធ្វើការណាស្រាលៗ ។ (ម្តាយមេម៉ាយម្នាក់អាយុ ៥៧ឆ្នាំ ដែលមានកូនស្រីទទួល ART នៅឃុំកំពង់ស្វាយ ខេត្តបន្ទាយមានជ័យ) ។*

*កាលពីឆ្នាំមុន កូនស្រីខ្ញុំដែលមានផ្ទុកវីរុសអេដស៍ បានចុះខ្សោយខ្លាំងណាស់ ។ នាងមិនអាចមើលថែទាំកូននាងបានទេ ។ ខ្ញុំបានជួយនាង ។ នាងបានទៅមន្ទីរពេទ្យ ហើយបានទទួល ART ។ មួយខែក្រោយបន្ទាប់ពីបានប្រើថ្នាំ នាងបានធូរស្រាលច្រើន និងមិនល្ហិតល្ហៃដូចមុនទេ ។ នាងអាចដើរចុះឡើង លាងចានឆ្នាំង និងមើលថែទាំកូននាង ។ សព្វថ្ងៃនាងស្រស់បស់ឡើងវិញ ហើយអាចធ្វើការបានដូចគេឯង ។ នាងពាក់គ្រឿងអលង្ការ និងសំលៀកបំពាក់ល្អៗ ។ ខ្ញុំសូមអរគុណដល់អ្នកដែលបានធ្វើថ្នាំសម្រាប់ព្យាបាលជម្ងឺនេះ ។ (ស្ត្រីមេម៉ាយម្នាក់អាយុ ៦៨ឆ្នាំ ដែលមានកូនស្រីទទួល ART នៅឃុំទឹកថ្លា ខេត្តបន្ទាយមានជ័យ) ។*

*ការប្រើ ART បានជួយជីវិតកូនប្រុសខ្ញុំ ។ កូនខ្ញុំបានឡើងទម្ងន់ គេងបាន និងមានកម្លាំងជាងមុន ។ វាលេបថ្នាំពីរដងក្នុងមួយថ្ងៃ ។ វាចងចាំពេលលេបថ្នាំ និងទៅមន្ទីរពេទ្យជាទៀងទាត់ដើម្បីសុំថ្នាំថែម ។ ក្រោយចេញពីពេទ្យ វាបានចាប់ផ្តើមទៅបង្រៀននៅសាលាវិញភ្លាម ។ កាលពីឆ្នាំមុន វាបានរៀបការជាថ្មី ។ ប្រពន្ធវាជាស្ត្រីមេម៉ាយមានកូនបី ។ ខ្ញុំមិនបានដឹងថាពួកវាស្រឡាញ់គ្នាទេ ។ នាង*

ក្រាហ្វិក ៤៖ ចំនួនពេលចំណាយគិតជាភាគរយ ក្នុងការមើលថែទាំ នៅមុន និងនៅក្រោយពេលទទួល ART ( ១០១គ្រួសារ ខេត្តបន្ទាយមានជ័យ ខែតុលា ២០០៨ )




ប្រភព ៖ អង្កេតមនុស្សវ័យចំណាស់

*និយាយថា នាងអាណិតកូនខ្ញុំណាស់ ហើយមិនប្រកាន់ថាវាកើតអេដស៍ទេ ។ ពេលមានគ្នីគ្នា ជីវិតកូនខ្ញុំកាន់តែប្រសើរឡើងទៀត ។ (ស្ត្រីជាម្ដាយអាយុ ៦៣ឆ្នាំ ដែលមានកូនប្រុសកំពុងទទួល ART នៅឃុំកំពង់ស្វាយ ខេត្តបន្ទាយមានជ័យ) ។*

ការប្រើប្រាស់ ART ធ្វើឱ្យសុខភាពរបស់សាច់ញាតិ ឬកូនៗ របស់មនុស្សវ័យចំណាស់បានប្រសើរឡើងស្ទើរគ្រប់គ្នា ហើយជួយឱ្យពួកគេអាចមើលថែទាំខ្លួនឯងបាន ។ អ្នកឆ្លើយសម្ភាសន៍វ័យចំណាស់ប្រមាណ ៧៥% រាយការណ៍ថា អ្នកទទួល ART អាចវិលទៅធ្វើការវិញ និង ៥០% មានសាច់ញាតិ និងកូនជាអ្នកទទួល ART បានចូលរួមចំណែករកចំណូលផ្គត់ផ្គង់គ្រួសារ ។ ទោះបីពេលវេលាដែលមនុស្សចាស់ចំណាយ ក្នុងការមើលថែទាំបានថយចុះច្រើនក្រោយការប្រើប្រាស់ ART ក្ដី (ក្រាហ្វិក ៤) ក៏អ្នកឆ្លើយសម្ភាសន៍វ័យចំណាស់ នៅតែចូលរួមយ៉ាងសកម្មក្នុងការក្រើនរំឭកអ្នកទទួល ART ឱ្យលេបថ្នាំយ៉ាងទៀងទាត់ដែរ ។

## អ្នកមើលថែទាំវ័យចំណាស់ និងការបណ្ដុះបណ្ដាល

មនុស្សចាស់ បានចូលរួមយ៉ាងសកម្មក្នុងការមើលថែទាំក៏ពិតមែន ប៉ុន្តែគេមិនបានជ្រើសរើសពួកគាត់ជាពិសេស ឱ្យទទួលការណែនាំ ឬបណ្ដុះបណ្ដាលពីរបៀបថែទាំ PLHA ទេ ។ ជាក់ស្ដែងមានអ្នកឆ្លើយសម្ភាសន៍ និង/ឬ ប្ដីប្រពន្ធគាត់ តែក្នុង ៦៦គ្រួសារ (៦១%) ក្នុងចំណោម ១០៨គ្រួសារប៉ុណ្ណោះ ដែលបានទទួលការណែនាំ ឬបណ្ដុះបណ្ដាលពីការងារដ៏សំខាន់នេះ ។ អ្នកមើលថែទាំក្នុង ៦៦គ្រួសារនេះ បានទទួលការបណ្ដុះបណ្ដាលភាគច្រើនពីមន្ត្រីសុខាភិបាលរដ្ឋ និងក្រុមមើលថែទាំតាមផ្ទះរបស់អង្គការមិនមែនរដ្ឋាភិបាល និងមួយចំនួនតូចពីក្រុមមើលថែទាំតាមផ្ទះជាលក្ខណៈស្ម័គ្រចិត្ត ។ ប៉ុន្តែមានមនុស្សចាស់ច្រើននាក់ជាង ដែលបានទទួលការបណ្ដុះបណ្ដាលពីរបៀបថែទាំអ្នកទទួល ART ។ អ្នកឆ្លើយសម្ភាសន៍ និង/ឬ ប្ដីប្រពន្ធគាត់ មកពី ៧៦គ្រួសារ (៧០%) ក្នុងចំណោម ១០៨គ្រួសារ ទទួលបានការណែនាំពីរបៀបប្រើប្រាស់ ART ។ អ្នកមើលថែទាំក្នុង ៧៦គ្រួសារនេះ បានទទួលការណែនាំភាគច្រើនពីមន្ត្រីសុខាភិបាលរដ្ឋ និងតិចតួចជាងពីក្រុមមើលថែទាំតាមផ្ទះរបស់អង្គការមិនមែនរដ្ឋាភិបាល និងក្រុមមើលថែទាំតាមផ្ទះស្ម័គ្រចិត្ត (ក្រាហ្វិក ៥) ។

ដើម្បីជួយឲ្យមានការគោរពត្រឹមត្រូវតាមវិធីព្យាបាលដោយ ART មនុស្សចាស់ត្រូវមានចំណេះដឹងគ្រប់គ្រាន់អំពីរបៀបរបបព្យាបាល ។ ការសិក្សាបានពិនិត្យទៅលើទំនាក់ទំនងនៃចំណេះដឹងអំពីART ជាមួយនឹងកម្រិតដែលមនុស្សចាស់ទទួលបានការណែនាំពីកម្មវិធីព្យាបាលដោយ ART ។ លទ្ធផលបានបង្ហាញពីទំនាក់ទំនងជិតស្និទ្ធរវាងការណែនាំដែលទទួលបាន និងចំណេះដឹងអំពី ART ។ រឿងនេះបង្ហាញថា ការទទួលបានការណែនាំពីប្រភពនៃកម្មវិធី វាជួយបង្កើនច្រើនណាស់នូវចំណេះដឹងរបស់មនុស្សវ័យចំណាស់ ព្រមទាំងគុណភាព និងប្រសិទ្ធភាពនៃជំនួយទ្រទ្រង់របស់ពួកគាត់ ( សូមមើល Knodel et al. 2010 )

## លទ្ធផលសម្រាប់គោលនយោបាយ

ការឆ្លើយតបរបស់កម្ពុជា ចំពោះការរីករាលដាលជម្ងឺអេដស៍ មានប្រសិទ្ធភាពគួរឱ្យកត់សម្គាល់ ទោះបីត្រូវពឹងផ្អែកជាខ្លាំងទៅលើការផ្ដល់ហិរញ្ញប្បទានពីម្ចាស់ជំនួយក្ដី ។ ការគោរពតាមមួយជីវិត

ក្រាហ្វិក ៨៖ ភាគរយនៃគ្រួសារបានរាយការណ៍ពី ប្រភពផ្ដល់ការណែនាំអំពីការមើលថែទាំអ្នកផ្ទុក ឬមានជម្ងឺអេដស៍ និងការប្រើប្រាស់ ART ខេត្តបន្ទាយមានជ័យ ខែវិច្ឆិកា ២០០៨




ប្រភព៖ អង្កេតមនុស្សវ័យចំណាស់

នូវរបៀបរបបព្យាបាលដ៏តឹងរ៉ឹងដោយ ART មានសារៈសំខាន់បំផុតក្នុងការរក្សាសុខភាពដែលទទួលបានមកវិញ និងកាត់បន្ថយភាពស៊ាំនឹងឱសថ ដែលអាចនាំឲ្យការព្យាបាលបរាជ័យ ។ ជោគជ័យជាបន្តបន្ទាប់នៃការឆ្លើយតបរបស់កម្ពុជា ទៅនឹងជម្ងឺនេះ អាស្រ័យលើការកសាងវិធីសាស្ត្រប្រើប្រាស់ ART ដោយខ្ជាប់ខ្ជួនក្នុងរយៈពេលវែង ដែលសមស្របតាមវប្បធម៌ អនុវត្តកើត និងមានប្រសិទ្ធភាពចំណាយ ។ រឿងនេះមិនគ្រាន់តែត្រូវមានការផ្ដល់ឱសថជាបន្ត និងបុគ្គលិកសុខាភិបាលសម្រាប់បើកផ្ដល់វាប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានទាំងបុគ្គលិកសម្រាប់ផ្ដល់ការគាំទ្រផ្នែកសង្គម និងផ្លូវចិត្តថែមទៀត ។ ការកកើតក្រុមគាំទ្រ PLHA និងក្រុមមើលថែទាំតាមផ្ទះ ដើម្បីបង្កើនការគោរពតាមវិធីព្យាបាល គឺជាយុទ្ធសាស្ត្រចំបងមួយ សម្រាប់ដោះស្រាយបញ្ហានេះ ។ លទ្ធផលនៃការសិក្សា ដែលបានចងក្រងជាឯកសារនូវការរួមចំណែករបស់មនុស្សចាស់ ក្នុងការឆ្លើយតបទៅនឹងជម្ងឺអេដស៍ បានបង្ហាញឲ្យឃើញពីឱកាសល្អ សម្រាប់ពង្រីកយុទ្ធសាស្ត្រនេះឱ្យវាគ្របដណ្ដប់ដល់មនុស្សចាស់ និងសមាជិកផ្សេងៗទៀតក្នុងគ្រួសារ ។

ការស្រាវជ្រាវបានបង្ហាញភស្តុតាងច្បាស់ៗ ពីផលប្រយោជន៍នៃការដាក់បញ្ចូលមនុស្សវ័យចំណាស់ និងសមាជិកផ្សេងៗទៀតក្នុងគ្រួសារឲ្យបានកាន់តែច្រើន នៅក្នុងកម្មវិធីប្រើប្រាស់ ART ។ មនុស្សវ័យចំណាស់ជារឿយៗរស់នៅជាមួយ ឬនៅក្បែរអ្នកជម្ងឺប្រើ ART ហើយមានអារម្មណ៍ជ្រាលជ្រៅចង់ឱ្យអ្នកជម្ងឺមានសុខភាពល្អឡើងវិញ ។ ពួកគាត់មានឆន្ទៈខ្ពស់ក្នុងការមើលថែទាំ និងតែងមានវត្តមាននៅពេលអ្នកជម្ងឺត្រូវលេបថ្នាំ ។ ម្យ៉ាងទៀត ពួកគាត់ក៏មិនដែលទាមទារ ឬរំពឹងថាបានកម្រៃអ្វីពីការជួយរបស់ខ្លួនដែរ ។ សរុបមក មនុស្សវ័យចំណាស់គឺជាធនធានដែលមិនទាន់មានការទទួលស្គាល់ ក្នុងការឆ្លើយតបរួមគ្នារបស់កម្ពុជាទៅនឹងការរីករាលដាលនៃជម្ងឺអេដស៍ ។

នៅកម្ពុជា ការប្រើប្រាស់មិនទាន់ពេញលេញនូវមនុស្សវ័យចំណាស់នៅក្នុងកម្មវិធីប្រើប្រាស់ ART ប្រហែលមកពីអ្នកវិជ្ជាជីវៈផ្នែកសុខាភិបាលតែងយល់ថា អាយុដ៏ច្រើន និងកង្វះជាទូទៅនូវការអប់រំជាផ្លូវការ ធ្វើឱ្យពួកគាត់ពុំមានសមត្ថភាពនឹងផ្ដល់ជំនួយទ្រទ្រង់ដ៏មានប្រយោជន៍បាន ។ ប៉ុន្តែដូចបានបង្ហាញច្បាស់ក្នុងការសិក្សានេះ អាយុច្រើនក្ដី កម្រិតអប់រំទាបក្ដី ឬការមិនចេះអក្សរក្ដី មិនបានរារាំងមនុស្សចាស់ក្នុងការយល់ដឹងពីការចាំបាច់ត្រូវគោរពតាមវិធីព្យាបាលនោះទេ ។ ប្រាកដណាស់ ចំណេះដឹង ART មានទំនាក់ទំនងជិតស្និទ្ធជាមួយកម្រិតសិក្សាដែលទទួលបាន ដូច្នេះ ការបណ្ដុះបណ្ដាលបានពីប្រភពនៃកម្មវិធី វាបង្កើនចំណេះដឹងរបស់មនុស្សចាស់បានច្រើនណាស់ ។ រឿងនេះក៏បង្ហាញពីតម្រូវការឱ្យក្រុមគាំទ្រ PLHA ចូលរួមកាន់តែសកម្មក្នុងការអប់រំមនុស្សវ័យចំណាស់ និងសមាជិកផ្សេងៗទៀតក្នុងគ្រួសារដែរ ។ ដោយធ្វើការរួមគ្នា ក្រុមគាំទ្រ PLHA និងមនុស្សវ័យចំណាស់ក្លាយជាកម្លាំងមួយកាន់តែខ្លាំងក្លាឡើង អាចចូលរួមចំណែកកាន់តែច្រើន ក្នុងការឆ្លើយតបទៅនឹងការរីករាលដាលនៃជម្ងឺអេដស៍ដែលកម្ពុជាត្រូវប្រឈមមុខជាច្រើនឆ្នាំតទៅទៀត ៕

## ឯកសារយោង

សូមមើលក្នុងឯកសារជាភាសាអង់គ្លេស ។

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះបង្ហាញពី បម្រែបម្រួលសេដ្ឋកិច្ចនៃប្រទេសអភិវឌ្ឍន៍មួយចំនួនក្នុងពិភពលោក និងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅអាស៊ី នៅត្រីមាសទី១ ឆ្នាំ២០១០ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី១ ឆ្នាំ២០១០ ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំ នៅឥណ្ឌូនេស៊ី កើន ៥,៧% ដែលជាកំណើនលឿនបំផុត គិតចាប់ពីត្រីមាសទី៣ ឆ្នាំ២០០៨ មក ។ ឥណ្ឌូនេស៊ី ទទួលរងឥទ្ធិពលពីវិបត្តិសេដ្ឋកិច្ចសាកល តិចជាងប្រទេសជាច្រើនដែលនៅជិតខាងខ្លួន ដោយសារជាសំខាន់ ចំណែកដ៏តូចនៃការនាំចេញ នៅក្នុង ផសស ឥណ្ឌូនេស៊ី ។ ផសស នៅម៉ាឡេស៊ី កើន ១០,១% និងនៅសិង្ហបុរី វាកើន ១៦% ដែលជាកំណើនលឿនបំផុត គិតចាប់ពីពាក់កណ្ដាលទសវត្សរ៍១៩៧០ ដោយក្នុងនោះការនាំចេញសុទ្ធរួមចំណែកដល់ ១០,២% ។ ក្នុងពេលជាមួយគ្នា ការនាំចូលទំនិញ និងសេវារបស់សិង្ហបុរី ក៏កើនឡើងដែរ ហើយចំណាយប្រើប្រាស់ផ្ទាល់ខ្លួន កើន ៥,៧% ។ នៅប្រទេសថៃ ផសស គិតក្នុងរយៈពេល ១ឆ្នាំ កើន ១២,០% ដោយសារកំណើនតម្រូវការក្នុងស្រុក និងបម្រែបម្រួលកម្រិតសន្និធិ ដែលរួមចំណែក ៨,៧% នៃកំណើន ផសស ។

នៅប្រទេសចិន ផសស ពីមួយឆ្នាំទៅមួយឆ្នាំ កើនបាន ១១,៩% ស្របពេលនៅ ហុងកុង វាកើន ២,៨% ដោយសារការនាំចូលកើន ២៨,៨% ដល់ ២២៧,៥ពាន់លានដុល្លារហុងកុង និងការនាំចេញកើន ២១,៧% ដល់ ២៤២,២ពាន់លានដុល្លារហុងកុង ។ ផសស នៅកូរ៉េខាងត្បូង កើន ២,១% ដោយសារកំណើន ចំណាយប្រើប្រាស់ក្នុងស្រុក ការនាំចេញ វិនិយោគលើសម្ភារៈសម្រួលការ (facilities investment) និងចំណាយប្រើប្រាស់របស់រដ្ឋាភិបាល ។ ផសស នៅតៃវ៉ាន់ កើន ១៣,៣% ។ ការនាំចេញទំនិញ និងសេវា ពីតៃវ៉ាន់ កើន ៤២,២% ដែលរួមចំណែកបាន ២៤,៥ ឯកតាភាគរយ (percentage points) ក្នុងកំណើន ផសស ពិតសរុប ហើយការបង្កើតមូលធនជាប់លាប់ដុល នៅតៃវ៉ាន់ កើន ២៦,៣% ។ ផសស កើន ៤,២% នៅប្រទេសជប៉ុន និង ២,៥% នៅសហរដ្ឋអាមេរិក ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

នៅត្រីមាសទី១ឆ្នាំ២០១០សំពាធបរិត្តផរណានៅបន្តកើតមាននៅប្រទេសជប៉ុន ស្របពេលដែលប្រទេសជាច្រើនកំពុងមានកំណើនអតិផរណា ។ អតិផរណាពីមួយឆ្នាំទៅមួយឆ្នាំនៅកម្ពុជា មានកម្រិត ៧,០%ដោយសារសេដ្ឋកិច្ចទើបចាប់ផ្តើមរើបឡើងវិញហើយសាំង ម៉ាស៊ូត និងឥន្ធនៈដទៃទៀត បានឡើងថ្លៃទៅតាម ការឡើងថ្លៃប្រេងនៅលើពិភពលោក ។ ការចុះថ្លៃប្រាក់រៀលទល់នឹងប្រាក់ដុល្លារ ក៏បានរួមចំណែកបង្កើនអតិផរណាដែរ ព្រោះវាធ្វើឲ្យទំនិញ និងសេវានាំចូលឡើងថ្លៃ បើគិតជាប្រាក់រៀលកម្ពុជា ។ អតិផរណាមានអត្រា ៣,៦% នៅឥណ្ឌូនេស៊ី ១,៣% នៅម៉ាឡេស៊ី ០,៩% នៅសិង្ហបុរី ៣,៧% នៅថៃ និង ៧,៥% នៅវៀតណាម ។ ថ្លៃទំនិញប្រើប្រាស់នៅចិន កើន ២,២% ដោយសារប្រាក់យ៉ុនឡើងថ្លៃ ទល់នឹងដុល្លារអាមេរិក ។ ថ្លៃទំនិញប្រើប្រាស់ គិតក្នុងរយៈពេល១ឆ្នាំ នៅកូរ៉េខាងត្បូង កើន ២,៧% ធៀបនឹង ២,៤% កាលពីត្រីមាសមុន ។ អតិផរណានៅហុងកុង មានកម្រិត ១,៩% ហើយនៅតៃវ៉ាន់ ១១,២% ។ អតិផរណា នៅមានអត្រាអវិជ្ជមានដដែលនៅជប៉ុន គឺ -១,២% ប៉ុន្តែ វាមានអត្រាវិជ្ជមាននៅតំបន់អឺរ៉ូ (១,១%) និង នៅសហរដ្ឋអាមេរិក (២,៣%) ។

នៅត្រីមាសទី១ នេះដែរ ប្រាក់រៀលធ្លាក់ថ្លៃ ០,៤% ទល់នឹងប្រាក់ដុល្លារបើធៀបនឹងត្រីមាសមុន។ទល់នឹងប្រាក់ដុល្លារអាមេរិក ប្រាក់ដុល្លារសិង្ហបុរី ធ្លាក់ថ្លៃ ០,៧% ប្រាក់ដុងវៀតណាម ធ្លាក់ថ្លៃ ២,០% ប្រាក់ដុល្លារហុងកុង ធ្លាក់ថ្លៃ ០,១% ប្រាក់អឺរ៉ូ ធ្លាក់ថ្លៃ ៦,០% និងប្រាក់យេនជប៉ុន ធ្លាក់ថ្លៃ ១,០% ។ ប្រាក់យ៉ុនចិននៅថេរទល់នឹងប្រាក់ដុល្លារអាមេរិក ដោយប្តូរបាន ៦,៨៣យ៉ុន/ដុល្លារ ។ ទល់នឹងប្រាក់ដុល្លារអាមេរិក ប្រាក់រូពីយ៉ាឥណ្ឌូនេស៊ី ឡើងថ្លៃ ០,២% ប្រាក់រីងហ្គីតម៉ាឡេស៊ី ឡើងថ្លៃ ០,៩% ប្រាក់បាតថៃ ឡើងថ្លៃ ១,២% ប្រាក់វ៉ុនកូរ៉េ ឡើងថ្លៃ ២,០% ហើយដុល្លារតៃវ៉ាន់ ឡើងថ្លៃ ១,០% ។

## ថ្លៃទំនិញប្រើប្រាស់នៅលើទីផ្សារពិភពលោក

នៅត្រីមាសទី១ ឆ្នាំ២០១០ ពោត អង្ករ និងសណ្តែកសៀង ធ្លាក់ថ្លៃបន្តិច ធៀបនឹងត្រីមាសមុន ។ ពោត (US លេខ២) ធ្លាក់ថ្លៃ ៣,០% ដល់ត្រឹម ១៦២,៩ដុល្លារ/តោន ។ អង្ករ (ថៃ ១០០%) ធ្លាក់ថ្លៃ ០,៦% ដល់ ៥៦៦ដុល្លារ/តោន ហើយ សណ្តែកសៀង (US លេខ១) ធ្លាក់ថ្លៃ ៤,៥% ដល់ ៣៧៣ដុល្លារ/តោន ។ ប្រេងឆៅ ឡើងថ្លៃ ២,៥% ដល់ ៧៦ដុល្លារ/ធុង សាំង ឡើងថ្លៃ ៨,៥% ហើយ ម៉ាស៊ូត ឡើងថ្លៃ ៥,៦% ដល់ ០,៥៤ដុល្លារ/លីត្រ ៕

*រៀបរៀងដោយ ស្រ៊ី បុប្ផារ័ត្ន*

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០១០ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 | 2009 | | | | 2010 |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា | 7.7 | 13.4 | 10.6 | 10.2 | 6.8 | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.1 | 5.6 | 5.4 | 6.3 | 6.1 | 5.2 | 4.4 | 3.9 | 4.2 | 5.4 | 5.7 |
| ម៉ាឡេស៊ី | 7 | 5.2 | 5.9 | 6.3 | 4.6 | 0.1 | -6.2 | -3.9 | -1.2 | 4.5 | 10.1 |
| សិង្ហបុរី | 8.5 | 5.7 | 7.7 | 7.7 | 1.1 | -4.2 | -10.1 | -3.5 | 0.8 | 4.0 | 16.0 |
| ថៃ | 6 | 4.5 | 4.8 | 4.9 | 2.6 | -4.3 | -7.1 | -4.9 | -2.8 | 5.8 | 12.0 |
| វៀតណាម | 7.5 | 8.4 | 8.1 | 8.5 | 6.2 | - | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន | 9.5 | 9.6 | 10.5 | 11.9 | 9.0 | 6.8 | 6.1 | 7.9 | 8.9 | 10.7 | 11.9 |
| ហុងកុង | 8.3 | 6.5 | 6.6 | 6.4 | 2.4 | -2.5 | -7.8 | -3.8 | -2.2 | 2.6 | 2.8 |
| កូរ៉េខាងត្បូង | 4.7 | 4.7 | 5.0 | 4.9 | 2.2 | -3.6 | -4.4 | -2.2 | 0.4 | 6.1 | 2.1 |
| តៃវ៉ាន់ | 5.7 | 4.1 | 4.6 | 5.2 | 0.1 | -8.4 | -10.2 | -7.5 | -1.3 | 9.2 | 13.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ | 1.8 | 1.5 | 2.7 | 2.9 | 0.9 | -1.3 | -2.5 | -4.8 | -4.7 | 0.1 | - |
| ជប៉ុន | 3.4 | 2.5 | 2.1 | 2.0 | -0.7 | -4.6 | -9.1 | 0.6 | -4.7 | -1.4 | 4.2 |
| សហរដ្ឋអាមេរិក | 4.4 | 3.7 | 3.3 | 2.2 | 1.1 | -6.3 | -2.6 | -3.9 | -2.5 | 0.1 | 2.5 |

*Sources: International Monetary Fund, Economist and countries' statistic offices*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០១០ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 | 2009 | | | | 2010 |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា | 4.0 | 5.8 | 4.7 | 10.5 | 19.7 | 15.7 | 4.3 | -4.8 | -3.0 | 1.7 | 7.0 |
| ឥណ្ឌូនេស៊ី | 8.3 | 10.5 | 13.4 | 6.4 | 10.1 | 11.4 | 8.5 | 5.6 | 2.76 | 2.6 | 3.6 |
| ម៉ាឡេស៊ី | 1.6 | 3.1 | 3.7 | 2.0 | 5.3 | 5.9 | 3.7 | 1.3 | -2.26 | -0.2 | 1.3 |
| សិង្ហបុរី | 1.7 | 0.5 | 1.0 | 2.1 | 6.5 | 5.5 | 2.1 | -0.5 | -0.4 | -0.3 | 0.9 |
| ថៃ | 2.7 | 4.5 | 4.7 | 2.2 | 5.5 | 2.2 | -0.2 | -2.8 | -2.13 | 1.9 | 3.7 |
| វៀតណាម | 7.8 | 8.2 | 7.7 | 8.3 | 23.3 | 23.6 | 15.1 | 6.2 | 2.6 | 4.6 | 7.5 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន | 3.9 | 1.8 | 1.5 | 4.8 | 5.9 | 2.5 | -0.6 | 1.5 | -1.26 | 0.7 | 2.2 |
| ហុងកុង | -0.4 | 1.1 | 2.2 | 2.0 | 4.3 | 2.3 | 1.7 | -0.1 | -0.86 | 1.3 | 1.9 |
| កូរ៉េខាងត្បូង | 3.5 | 2.8 | 2.4 | 2.5 | 4.6 | 4.5 | 3.9 | 2.8 | 2.0 | 2.4 | 2.7 |
| តៃវ៉ាន់ | 1.6 | 2.3 | 0.6 | 1.8 | 3.2 | 1.9 | 0.0 | -0.8 | -1.33 | -1.8 | 11.2 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.2 | 2.2 | 2.1 | 2.1 | 3.3 | 2.3 | 1.0 | 0.9 | -0.36 | 0.4 | 1.1 |
| ជប៉ុន | Nil | -0.3 | 0.5 | 0.1 | 1.4 | 1.0 | -0.1 | -1.0 | -2.2 | -2.0 | -1.2 |
| សហរដ្ឋអាមេរិក | 2.7 | 3.4 | 3.2 | 2.9 | 3.8 | 1.5 | -0.2 | -0.9 | -1.63 | 1.4 | 2.3 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០១០ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 | 2009 | | | | 2010 |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា (រៀល) | 4016.30 | 4092.50 | 4103.20 | 4062.70 | 4054.20 | 4089.80 | 4108.00 | 4128.60 | 4164.40 | 4163.10 | 4180.109 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8938.00 | 9705.00 | 9134.00 | 9419.00 | 9699.00 | 11,060.00 | 11,630.80 | 10,225.00 | 9887.00 | 9472.44 | 9266.93 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.70 | 3.30 | 3.30 | 3.60 | 3.60 | 3.50 | 3.50 | 3.40 | 3.37 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.69 | 1.66 | 1.59 | 1.51 | 4.58 | 1.49 | 1.51 | 1.45 | 1.44 | 1.39 | 1.40 |
| ថៃ (បាត) | 40.20 | 40.20 | 37.9 | 32.22 | 33.36 | 34.83 | 35.29 | 33.98 | 33.96 | 33.30 | 32.90 |
| វៀតណាម (ដុង) | 15,777.00 | 15,859.00 | 15,994.00 | 16,030.00 | 16,382.00 | 16,537.00 | 16,954.00 | 17,801.00 | 17,841.00 | 18,472.00 | 18,825.67 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.19 | 7.97 | 8.03 | 6.94 | 6.83 | 6.84 | 6.83 | 6.83 | 6.83 | 6.83 |
| ហុងកុង (ដុល្លារហុងកុង) | 7.79 | 7.78 | 7.77 | 7.80 | 7.78 | 7.75 | 7.75 | 7.75 | 7.75 | 7.75 | 7.76 |
| កូរ៉េខាងត្បូង (វ៉ុន) | 1145.00 | 1024.00 | 955.00 | 929.04 | 1137.23 | 1367.20 | 1412.50 | 1273.90 | 1239.04 | 1167.77 | 1143.97 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.60 | 32.10 | 32.50 | 32.85 | 31.54 | 33.00 | 34.00 | 33.10 | 32.77 | 32.29 | 31.93 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.80 | 0.80 | 0.70 | 0.84 | 1.32 | 0.76 | 0.71 | 0.70 | 0.68 | 0.72 |
| ជប៉ុន (យ៉េន) | 108.20 | 110.20 | 116.40 | 117.80 | 102.46 | 96.10 | 93.72 | 95.95 | 93.58 | 89.78 | 90.73 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៤-២០១០(មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 | 2009 | | | | 2010 |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ពោត (US No. 2) - USA (USD/តោន) | 110.65 | 89.19 | 111.04 | 149.08 | 218.15 | 181.22 | 183.12 | 171.16 | 146.85 | 168.13 | 162.88 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 427.47 | 381.32 | 433.85 | 707.68 | 912.23 | 564.50 | 636.53 | 719.35 | 659.16 | 732.33 | N/A |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 221.67 | 262.88 | 282.00 | 305.36 | 615.32 | 519.41 | 522.13 | 499.45 | 307.31 | 569.00 | 565.67 |
| សណ្ដែកសៀង (US No. 1) - USA (USD/តោន) | 262.03 | 224.25 | 213.88 | 294.59 | 460.41 | 382.72 | 434.40 | 420.10 | 411.18 | 390.43 | 372.68 |
| ប្រេងឆៅ - OPEC spot (USD/តោន) | 33.50 | 50.14 | 61.58 | 69.25 | 95.44 | 55.23 | 42.34 | 57.46 | 68.32 | 73.86 | 75.73 |
| សាំង - US Gulf Coast (សេន/លីត្រ) | 30.90 | 42.19 | 47.70 | 53.58 | 62.22 | 34.52 | 31.97 | 43.11 | 46.92 | 49.64 | 53.87 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 29.48 | 44.35 | 51.35 | 55.51 | 76.20 | 46.98 | 34.17 | 40.51 | 46.46 | 51.03 | 53.87 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី១ ឆ្នាំ២០១០ អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ ថយចុះ ៩១% ធៀបនឹងត្រីមាសមុន ។ អនុមតិសំរាប់វិស័យកសិកម្ម ធ្លាក់ចុះ ៦២% មកត្រឹម ៣៦លានដុល្លារ ។ អនុមតិសំរាប់វិស័យឧស្សាហកម្ម ធ្លាក់ចុះ ៦៤% មកត្រឹម ២៤៧,៦លានដុល្លារ ដោយសារជាសំខាន់មកពី អនុមតិផ្នែកថាមពល ធ្លាក់ចុះ ៩៧% ពី ៥៤០លានដុល្លារ មកត្រឹម ១៧,០ លានដុល្លារ ហើយអនុមតិសំរាប់ការកែច្នៃស្បៀងអាហារ ធ្លាក់ចុះ ៨៨% ពី ២៣,០លានដុល្លារ មកត្រឹម ២,៨លានដុល្លារ ។ អនុមតិសំរាប់វិស័យសេវាកម្ម ធ្លាក់ចុះ ៩៧% មកត្រឹម ៨៩,៥លានដុល្លារ ដោយសារអនុមតិសំរាប់ផ្នែកសណ្ឋាគារ និងសេវាកម្មផ្សេងៗ ធ្លាក់ចុះពី ៣៤៧៥,៨លានដុល្លារ មកត្រឹម ៨៩,៥លានដុល្លារ ហើយគ្មានការអនុមតិគម្រោងសំរាប់វិស័យទេសចរណ៍ទេ ។

នៅត្រីមាសទី១ នេះដែរ អនុមតិគម្រោងសាងសង់សរុប ធ្លាក់ចុះ ២៣% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០០៩ ។ អនុមតិគម្រោងសាងសង់ផ្ទះនិងភូមិគ្រឹះ ធ្លាក់ចុះ ៤៨% មកត្រឹម ៥,១លានដុល្លារ ហើយអនុមតិគម្រោងសាងសង់ផ្ទះល្វែង ធ្លាក់ចុះ ៦០% មកត្រឹម ១១,០លានដុល្លារ រីឯអនុមតិសំរាប់សំណង់ផ្សេងៗទៀត កើន ២១% ដល់ ៣៥,០លានដុល្លារ ។

នៅត្រីមាសទី១ ឆ្នាំ២០១០ ចំនួនភ្ញៀវមកដល់កម្ពុជាសរុប កើន ១៦% ដល់ ៦៨៣.៦៩២នាក់ ។ ភ្ញៀវមកដល់តាមផ្លូវអាកាស មាន ៣៧១.៥០៦នាក់ ឬ កើន ២១% ធៀបនឹងត្រីមាសមុន ក្នុងនោះ ភ្ញៀវចូលមកតាមអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កើន ៧,៣% ដល់ ១៥៨.៩៧៩នាក់ ហើយតាមអាកាសយានដ្ឋានអន្តរជាតិសៀមរាប កើន ៣៣% ដល់ ២១២.៥២៧នាក់ ។ ភ្ញៀវចូលមកតាមផ្លូវគោក កើន ១២% ដល់ ២៤៦.៤៤២នាក់ និងតាមផ្លូវទឹក កើន ៣០% ដល់ ២៦.៨២៩នាក់ ។ ភ្ញៀវដើរកំសាន្តវិលល្ងាច កើន ២,៥% ដល់ ៣៨.៩១៥នាក់ ។ ក្នុងចំណោមភ្ញៀវមកពីប្រទេសអាស៊ាន ភ្ញៀវមកពីវៀតណាម មាន ៩២.៦០៥នាក់ ឬ កើន ៦% ធៀបនឹងត្រីមាសមុន ដែលជាអត្រាកំណើនខ្ពស់ជាងគេ ហើយបន្ទាប់មកមាន ភ្ញៀវមកពីមីយ៉ាន់ម៉ា (កើន ៤,០%) និង ភ្ញៀវមកពីហ្វីលីពីន (កើន ១,០%) ។

នៅត្រីមាសទី១ នេះដែរ ការនាំចេញសំលៀកបំពាក់ ធ្លាក់ចុះ ៥,៥% ធៀបនឹងត្រីមាសមុន ការនាំចេញកៅស៊ូ ធ្លាក់ចុះ ២៨% ហើយ ការនាំចេញត្រី ធ្លាក់ចុះ ៤២% ប៉ុន្តែការនាំចេញឈើ កើន ៨៣% ។ ការនាំចូលផលិតផលប្រេងកាតសរុប កើន ៣,៧% រីឯការនាំចូលសម្ភារៈសំណង់ ធ្លាក់ចុះ ៤,១% ហើយការនាំចូលផលិតផលផ្សេងៗ ធ្លាក់ចុះ ៥,២% ។ ជញ្ជីងពាណិជ្ជកម្មមានអតិរេក ៣០៥,២លានដុល្លារ នៅត្រីមាសទី១នេះ ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី១ ឆ្នាំ២០១០ ឱនភាពថវិកា មានចំនួន ៥៩២,៦ ពាន់លានរៀល ។ ការប្រមូលចំណូលសរុប កើន ១៤% ដល់ ១៥៣៦,៨ពាន់លានរៀល ។ ចំណូលចរន្ត ប្រមូលបាន ១៥២៦ ពាន់លានរៀល ឬ កើន ១៤% ធៀបនឹងត្រីមាសមុន ។ ចំណូលពន្ធ ធ្លាក់ចុះ ១១% មកត្រឹម ១០៩៤ពាន់លានរៀល ក្នុងនោះ ចំណូលពន្ធលើពាណិជ្ជកម្មអន្តរជាតិ ធ្លាក់ចុះ ៩,៨% មកត្រឹម ២៧៣,៧ពាន់លានរៀល រីឯចំណូលពន្ធក្នុងស្រុក កើន ១,៥% ដល់ ៨២០ពាន់លានរៀល ។ ចំណូលមិនមែនពន្ធ កើន ៩២% ក្នុងនោះ ចំណូលពន្ធលើទ្រព្យសម្បត្តិ កើនជិត ១៦ដង ដល់ ១០៨,៤ពាន់លានរៀល ចំណូលពីការលក់ទំនិញនិងសេវា ធ្លាក់ចុះ ១១% មកត្រឹម ១០៨ពាន់លានរៀល ហើយចំណូលមិនមែនពន្ធដទៃទៀត ធ្លាក់ចុះ ៦,០% មកត្រឹម ៨៤ពាន់លានរៀល ។ ចំណាយសរុប កើន ១៣% ប៉ុន្តែចំណាយចរន្ត ធ្លាក់ចុះ ៣៨% ។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី១ ឆ្នាំ២០១០ អតិផរណាពីមួយឆ្នាំទៅមួយឆ្នាំនៅក្រុងភ្នំពេញ មានកម្រិត ៧,០% ។ ថ្លៃស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើន ៧,៨% ថ្លៃសំលៀកបំពាក់ និងគ្រឿងសំរាប់ពាក់នៅជើង កើន ៣,៦% ថ្លៃស្នាក់នៅ និងទឹកភ្លើង កើន ៤,៦% ថ្លៃសង្ហារឹម និងប្រតិបត្តិការក្នុងផ្ទះ កើន ៥,១% ថ្លៃថែទាំសុខភាព កើន ៤,៣% ថ្លៃដឹកជញ្ជូន កើន ១២,៩% ថ្លៃលំហែកំសាន្ត និងវប្បធម៌ កើន ០,១% និង ថ្លៃអប់រំ កើន ៧,២% រីឯ ថ្លៃទូរគមនាគមន៍ ធ្លាក់ចុះ ៥,៧% ។

នៅត្រីមាសទី១នេះ ប្រាក់រៀល ធ្លាក់ថ្លៃ ០,៥% ទល់នឹងដុល្លារអាមេរិក ធៀបនឹងត្រីមាសមុន ។ ប្រាក់រៀល ធ្លាក់ថ្លៃ ០,៨% ទល់នឹងបាតថៃ ប៉ុន្តែឡើងថ្លៃ ៣,០% ទល់នឹងដុងវៀតណាម ។ មាសឡើងថ្លៃ០,០៧%ធៀបនឹងត្រីមាសមុនដោយលក់ថ្លៃ១៣៣,៩ ដុល្លារ/ជី ។ ម៉ាស៊ូតឡើងថ្លៃ ៦,៤% ហើយសាំងឡើងថ្លៃ ៥,៦% ។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទី១ ឆ្នាំ២០១០ សាច់ប្រាក់ងាយស្រួល (M2) កើនដល់ ១៧.២៣៥ពាន់លានរៀល ធៀបនឹង ១២.៤៤៨ពាន់លានរៀល កាលពីត្រីមាសមុន ។ ប្រាក់រៀលចរាចរ កើនដល់ ៣០២៨ពាន់លានរៀល ហើយបញ្ញើជាប្រាក់រៀល កើនដល់ ១២១ពាន់លានរៀល ។ បញ្ញើជារូបិយវត្ថុបរទេស មាន ១៣.៧៥៦ពាន់លានរៀល ឬ កើន ៦,៦% ធៀបនឹងត្រីមាសមុន ។ ទ្រព្យសកម្មបរទេសសុទ្ធ កើន ៦,០% ដល់ ១៥.៥១៥ពាន់លានរៀល ។ ទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ១០% ដល់

១៧២០ពាន់លានរៀល ដោយសារកំណើនផលិតផលក្នុងស្រុក ដល់ ៨៦៦២ពាន់លានរៀល និង កំណើនបំណុលផ្សេងទៀត ដល់ ៦៩៨២ពាន់លានរៀល ។

## ស្ថានភាពក្រីក្រ

ក្នុងអង្កេតលើពលករងាយរងគ្រោះ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានធ្វើសម្ភាសន៍ជាមួយពលករ ៤០នាក់ ក្នុងក្រុមនីមួយៗនៃ ៩ ក្រុមពលករ និង ១២០នាក់ក្នុងក្រុមកម្មករកាត់ដេរ ។ ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍ទាំង ៤៨០នាក់ មាន ៥៧% ធ្លាប់ចូលរៀនថ្នាក់បឋមសិក្សា ២៩% បានរៀនដល់មធ្យមសិក្សាបឋមភូមិ និង ៤,០% រៀនដល់មធ្យមសិក្សាទុតិយភូមិ ចំណែកឯ ១,០% ទៀត មិនធ្លាប់ចូលរៀនទេ ។ នៅខែឧសភា២០១០អង្កេតរកឃើញថាមានកំណើនប្រាក់ចំណូលប្រចាំថ្ងៃពិតសំរាប់ ៤ ក្រុមពលករៈ អ្នកជាក់ស៊ីក្លូ អ្នករើសអេតចាយ អ្នកបំរើភោជនីយដ្ឋាននិងកម្មករកាត់ដេររីឯពលករ៦ក្រុមផ្សេងទៀតរកចំណូលបានទាបជាងមុន បើធៀបនឹងខែឧសភា ២០០៩ ។

នៅខែឧសភា ២០១០ ចំណូលប្រចាំថ្ងៃជាមធ្យមរបស់អ្នកជាក់ស៊ីក្លូ គឺ ៩៥៧០រៀល ឬ កើន ៧,៦% ធៀបនឹងខែឧសភា ឆ្នាំមុន ។ អ្នកជាក់ស៊ីក្លូគ្រប់គ្នាដែលបានឆ្លើយសម្ភាសន៍សុទ្ធតែជាប្រភពចំណូលចំបងសំរាប់ក្រុមគ្រួសារ ។ ពួកគាត់ធ្វើការជាមធ្យម ២៥ថ្ងៃ/ខែ និង ១១ម៉ោង/ថ្ងៃ ។ ទោះបីខំធ្វើការស្ទើរគ្មានឈប់សម្រាកក្តី ក៏មានអ្នកជាក់ស៊ីក្លូតែ ៣,០% ប៉ុណ្ណោះដែលប្រាប់ថា ប្រាក់ចំណូលរបស់ខ្លួន គ្រប់គ្រាន់សំរាប់តម្រូវការក្នុងគ្រួសារ រីឯ ៩៧% ទៀត រកបានត្រឹមតែមួយរស់ប៉ុណ្ណោះ ។ កំណើនប្រាក់ចំណូល មិនបានជួយទប់ចំណាយប្រចាំថ្ងៃរបស់ពួកគាត់ទេ ដោយវាបានថយចុះអស់ ១០% មកត្រឹម ៥៣៣៦រៀល ។ អ្នកជាក់ស៊ីក្លូ ៨៧% មិនអាចសន្សំប្រាក់ទុកសំរាប់ថ្ងៃខាងមុខទេ ហើយមានតែ ២,៥% ប៉ុណ្ណោះ ដែលរស់នៅក្រុងភ្នំពេញតាំងពីដើមមក ឯក្រៅពីនោះសុទ្ធតែមកពីខេត្តផ្សេងៗ ហើយអ្នកមកពីខេត្តព្រៃវែង មានច្រើនជាងគេដល់ ៤២% ។ ក្នុងចំណោមអ្នកមកពីខេត្ត មាន ៥៦% ស្នាក់នៅតាមផ្លូវ ឬនៅក្នុងវត្ត ២៨% ស្នាក់នៅតាមផ្ទះរបស់ម្ចាស់ស៊ីក្លូដែលខ្លួនជួល ៨,០% ស្នាក់នៅជាមួយសាច់ញាតិ និង ៥,០% ស្នាក់នៅផ្ទះជួល ។

ចំណូលប្រចាំថ្ងៃពិតរបស់អ្នករើសអេតចាយ កើន ១២% ដល់ ៧៤០៧រៀល ដោយសាររបស់អេតចាយ ឡើងថ្លៃ ទោះជាចំនួនអ្នករើសអេតចាយកើនឡើងក្តី ។ កំណើនប្រាក់ចំណូលនេះជួយឲ្យចំណាយប្រចាំថ្ងៃពិតរបស់ពួកគេ អាចកើនឡើងយ៉ាងខ្លាំងដល់ ៤២២៦រៀល ធៀបនឹង ៣១៨២រៀល កាលពីខែឧសភាឆ្នាំមុន ។ អ្នករើសអេតចាយមួយចំនួនធំ មកពីខេត្តព្រៃវែង (៣៨%) និងស្វាយរៀង (២០%) ។ ក្នុងចំណោមអ្នករើសអេតចាយមកពីតាមខេត្ត មាន ៦៥% ជាអ្នកគ្មានដីធ្លី ។ ៧៥% នៃអ្នករើសអេតចាយមកពីខេត្ត បានមកក្រុងភ្នំពេញជាមួយគ្រួសារទាំងមូលរបស់ខ្លួន ។

នៅខែឧសភា ២០១០ ចំណូលប្រចាំថ្ងៃរបស់កម្មករកាត់ដេរគឺ ៧៤៩១រៀល ឬ កើន ១២% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ អ្នកឆ្លើយសម្ភាសន៍លើកនេះសុទ្ធតែមកពីតាមខេត្ត ហើយភាគច្រើនមកពីខេត្តស្វាយរៀង (២០%) ខេត្តកំពង់ចាម (១៩%) និងខេត្តព្រៃវែង (១៨%) ។ ពួកគេធ្វើការជាមធ្យម ៦ថ្ងៃ ឬ ៦០ម៉ោង/សប្តាហ៍ ហើយចំណាយជាមធ្យម ៤៨៥៣រៀល/ថ្ងៃ ក្នុងនោះ ៣៥% សំរាប់អាហារ និង ២៨% សំរាប់ថ្លៃស្នាក់នៅ និងចំណាយប្រើប្រាស់ផ្សេងៗទៀត ។ ពួកគេសន្សំបាន ១១៦.៨០០រៀល/ខែ សំរាប់ផ្ញើទៅផ្ទះ ក្នុងនេះ ៦៣% ប្រាប់ថា ខ្លួនបានផ្ញើប្រាក់សន្សំទៅផ្ទះជាក់ស្តែង រីឯអ្នកផ្សេងទៀត សន្សំប្រាក់ទុកសំរាប់តម្រូវការទៅថ្ងៃមុខ ។

នៅខែឧសភានេះដែរ ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់មានជំនាញ ធ្លាក់ចុះ ១៣% ធៀបនឹងខែឧសភា ២០០៩ មកត្រឹម ១១.៩២៨រៀល ។ ៧០% នៃអ្នកឆ្លើយសម្ភាសន៍និយាយថា សកម្មភាពសាងសង់បានកើនឡើងពិតមែន ប៉ុន្តែចំនួនកម្មករក៏កើនឡើងដែរ ។ មានតែ ២,៥% នៃកម្មករសំណង់មានជំនាញប៉ុណ្ណោះ ដែលមានផ្ទះនៅក្រុងភ្នំពេញ ហើយក្រៅពីនេះសុទ្ធតែមកពីតាមខេត្ត ដែលភាគច្រើនមកពី ខេត្តកំពង់ស្ពឺ (៣៣%) និង តាកែវ (២០%) ។ ៩៣% នៃកម្មករក្រុមនេះ គឺជាប្រភពចំណូលចំបងសំរាប់គ្រួសាររបស់ពួកគេ ។ ចំណាយប្រចាំថ្ងៃពិតរបស់កម្មករសំណង់មានជំនាញ ធ្លាក់ចុះ ២៣% ធៀបនឹងឆ្នាំមុន មកត្រឹម ៤២៩០រៀល ហើយជាមធ្យមនៅខែឧសភានេះពួកគេសន្សំប្រាក់បាន ១៣៤.៥០០រៀល សំរាប់ផ្ញើទៅផ្ទះ ដែលជាតួលេខខ្ពស់បំផុត បើធៀបនឹងក្រុមកម្មករដទៃទៀត ។ ៥៨% នៃកម្មករក្រុមនេះនិយាយថា ជីវភាពរស់នៅរបស់គ្រួសារខ្លួនប្រែប្រួលល្អប្រសើរឡើង ក្រោយពេលបានចាប់យកមុខរបរនេះ ។ ៣២% នៃអ្នកឆ្លើយសម្ភាសន៍ រំពឹងថា អាចសន្សំប្រាក់បានខ្លះទុកសំរាប់ប្រើប្រាស់នៅថ្ងៃខាងមុខ ។

អ្នកលក់បន្លែតូចតាចភាគច្រើនមកពីតាមខេត្តពិសេសខេត្តកណ្តាល (៣០%) និងស្វាយរៀង (២៥%) ហើយមានតែ ១៧% ប៉ុណ្ណោះជាអ្នកក្រុងភ្នំពេញ ។ នៅខែឧសភា ២០១០ ចំណូលប្រចាំថ្ងៃរបស់ពួកគាត់គឺ ៨០៦២រៀល ឬ ធ្លាក់ចុះ ១៧% ធៀបនឹងខែឧសភាឆ្នាំមុន ។ ៧៥% នៃអ្នកផ្តល់សម្ភាសន៍ រាយការណ៍ពីកំណើនការប្រកួតប្រជែង និងការវិនិយោគទុនតិចជាងមុន ព្រោះចំណូលរបស់ខ្លួនបានធ្លាក់ចុះ ។ ៨២% ភាគរយ នៃអ្នកលក់បន្លែតូចតាចប្រាប់ថាពួកគេជាប្រភពចំណូលសំខាន់សំរាប់គ្រួសារ ក្រៅពីនោះ គ្រាន់តែជាប្រភពចំណូលបន្ទាប់បន្សំ ។ ៨២% នៃអ្នកផ្តល់សម្ភាសន៍ មិនមានប្រាក់សន្សំសំរាប់ប្រើក្នុងគ្រាអាសន្នទេ ៕

*រៀបរៀងដោយ ស្រ៊ី បុប្ផារ័ត្ន និង ប៊ុន ដូរីណា*

## តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០២-១០

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 40.3 | 3.7 | 12.3 | 26.8 | 498.0 | 135.6 | 92 | 175.3 | 0.0 | 176.1 | 94.4 | 36.1 |
| ឧស្សាហកម្ម | 67.7 | 137.2 | 187.9 | 914.6 | 365.3 | 709.1 | 724.9 | 257.7 | 39.4 | 60.6 | 685.5 | 247.7 |
| *កាត់ដេរ* | *27.2* | *68.1* | *132.6* | *174.4* | *89.4* | *170.7* | *142.8* | *16.4* | *35.0* | *21.9* | *14.2* | 13.1 |
| សេវាកម្ម | 145.3 | 168.4 | 91.8 | 155.5 | 2939.1 | 1742.5 | 10003.2 | 495.6 | 0.0 | 150.2 | 3475.8 | 89.5 |
| *សណ្ឋាគារ និងទេសចរណ៍* | *47.1* | *124.1* | *55.9* | *102.6* | *345.0* | *1048.3* | *8758.1* | *254.1* | *0.0* | *150.2* | *0.0* | 3.78 |
| សរុប | 253.3 | 309.3 | 292.0 | 1096.9 | 3802.4 | 2587.2 | 10570.9 | 928.6 | 39.4 | 386.3 | 4255.7 | 373.3 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | -41.2 | -95.7 | 882.0 | 1001.7 | -91.2 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 13.1 | 22.1 | -5.6 | 275.6 | 246.6 | -32.0 | 308.6 | 266.5 | -99.0 | -91.5 | 169.3 | -59.8 |

*Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០២-១០

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 23.4 | 20.0 | 30.3 | 45.5 | 33.1 | 79.1 | 154.7 | 32.1 | 6.7 | 2.2 | 9.8 | 5.1 |
| ផ្ទះល្វែង | 179.9 | 91.6 | 167.6 | 204.2 | 213.3 | 297.2 | 221.6 | 95.2 | 18.9 | 6.3 | 28.0 | 11.1 |
| ផ្សេងៗ | 16.6 | 87.3 | 65.6 | 109.1 | 76.8 | 259.6 | 740.9 | 53.7 | 36.7 | 12.2 | 29.0 | 35.2 |
| សរុប | 219.9 | 198.9 | 263.5 | 358.8 | 323.3 | 635.8 | 1117 | 181.1 | 62.3 | 20.7 | 66.8 | 51.4 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | -48.5 | -65.6 | -66.8 | 222.7 | -23.1 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 12.0 | -9.5 | 32.5 | 36.2 | -9.9 | 96.7 | 75.7 | 31.9 | -55.8 | -95.7 | -81.0 | -71.6 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ចំនួនអ្នកដំណើរមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០២-១០

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 523.0 | 456.0 | 626.1 | 856.5 | 1029.0 | 1296.5 | 1239.4 | 335.2 | 221.2 | 247.2 | 308.1 | 371.5 |
| តាមផ្លូវគោក និងទឹក | 263.5 | 245.0 | 428.9 | 565.1 | 672.9 | 718.6 | 881.9 | 287.1 | 243.0 | 240.2 | 279.5 | 312.2 |
| សរុប | 786.5 | 701.1 | 1055.0 | 1421.6 | 1701.9 | 2015.1 | 2121.3 | 622.3 | 464.2 | 487.4 | 587.6 | 683.7 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | 7.7 | -25.4 | 5.0 | 20.6 | 16.4 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 30.0 | -10.9 | 50.5 | 34.7 | 19.7 | 28.4 | 5.3 | -3.4 | 2.2 | 9.4 | 1.7 | 9.9 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០២-១០

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 1453.2 | 1708.1 | 2108.1 | 2352.8 | 2799.9 | 3097.0 | 3000.0 | 619.7* | 433.5 | 245.3 | 671.5* | 631.3 |
| ក្នុងនេះ: សំលៀកបំពាក់ | 1355.8 | 1628.4 | 2027.0 | 2253.3 | 2698.9 | 2938.9 | 2784.8 | 606.9 | 377.3 | 240.0 | 652.9 | 616.7 |
| កៅស៊ូ | 29.7 | 35.1 | 38.3 | 36.7 | 41.4 | 41.6 | 36.1 | 11.8 | 8.2 | 4.9 | 16.2 | 11.7 |
| ឈើ | 16.0 | 10.2 | 11.1 | 10.3 | 8.6 | 4.1 | 0.0 | 0.1 | 0.1 | 0.0 | 1.2 | 2.2 |
| ត្រី | 4.3 | 2.8 | 10.6 | 10.1 | 5.9 | 3.2 | 2.2 | 0.9 | 0.7 | 0.4 | 1.2* | 0.7 |
| ការនាំចូលសរុប | 1707.8 | 1824.9 | 2149.0 | 2513.0 | 3057.0 | 3609.7 | 4105.7 | 987.7 | 1060.8 | 336.4 | 336.3* | 326.1 |
| ក្នុងនេះ: ផលិតផលប្រេងកាត | 157.5 | 191.6 | 187.0 | 184.8 | 238.5 | 264.9 | 255.8 | 67.3 | 72.2 | 89.0 | 82.0* | 85.0 |
| សំភារ:សំណង់ | 12.9 | 80.8 | 95.3 | 134.7 | 154.4 | 143.1 | 145.9 | 41.4 | 30.9 | 9.9 | 9.8* | 9.4 |
| ផ្សេងៗ | 1568.2 | 1601.3 | 1914.0 | 2245.0 | 2731.0 | 3216.6 | 3704 | 879.0 | 957.7 | 237.5 | 244.5* | 231.7 |
| ជញ្ជីងពាណិជ្ជកម្ម | -254.6 | -116.8 | -40.9 | -160.1 | -257.1 | -511.2 | -1105.7 | -368.0* | -627.3 | -91.1 | 335.2* | 305.2 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | - | - | -10.6 | -37.8 | -36.4 | 172.0 | -5.5 |
| ការនាំចេញសរុប | - | - | - | - | - | - | - | -9.5 | -37.7 | -36.5 | 173.7 | -6.3 |
| ការនាំចូលសរុប | - | - | - | - | - | - | - | 7.8 | 7.4 | -68.3 | 0.0 | -3.0 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 9.2 | 20.1 | 24.5 | 11.2 | 19.8 | 8.9 | -5.2 | -21.5 | -18.6 | -72.4 | -3.8 | 1.6 |
| ការនាំចេញសរុប | 14.6 | 17.5 | 23.4 | 11.6 | 19.0 | 10.6 | -3.1 | -10.2 | -28.4 | -73.6 | -1.9 | 1.5 |
| ការនាំចូលសរុប | 13.7 | 6.9 | 17.8 | 16.9 | 21.6 | 18.1 | 13.7 | 0.4 | -10.0 | -67.2 | -63.3 | -67.0 |

*Import data include tax-exempt imports. Source:  Customs and Excise Department, cited by National Bank of Cambodia*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០២-១០ (ពាន់លានរៀល)

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ចំណូលសរុប | 1744.0 | 1764.0 | 2126.0 | 2625.0 | 3259.2 | 1146.1 | 5290.0 | 1101.7 | 1252.7 | 1184.7 | 1346.1 | 1536.8 |
| ចំណូលចរន្ត | 1728.0 | 1733.0 | 2107.0 | 2474.0 | 2881.8 | 1141.6 | 5210.7 | 1097.7 | 1245.7 | 1174.9 | 1337.7 | 1526.4 |
| ចំណូលពន្ធ | 1227.0 | 1220.0 | 1577.0 | 1911.0 | 2270.9 | 965.2 | 4409.9 | 947.4 | 1096.5 | 999.5 | 1224.1 | 1094.1 |
| ពន្ធក្នុងស្រុក | - | - | - | - | - | 661.8 | 3248.4 | 712.0 | 838.7 | 731.8 | 808.5 | 820.3 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | - | 303.5 | 1161.5 | 235.4 | 257.8 | 268.0 | 303.4 | 273.7 |
| ចំណូលមិនមែនពន្ធ | 501.0 | 513.0 | 530.0 | 563.0 | 610.9 | 176.4 | 800.8 | 150.3 | 149.2 | 176.1 | 225.7 | 432.4 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | - | - | - | 13.6 | 78.0 | 13.1 | 9.7 | 27.5 | 14.3 | 237.0 |
| លក់ទំនិញ និងសេវា | - | - | - | - | - | 124.3 | 424.7 | 93.5 | 100.9 | 91.7 | 121.9 | 108.4 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | - | - | - | 38.5 | 298.2 | 43.7 | 38.6 | 56.5 | 89.5 | 84.0 |
| ចំណូលជាមូលធន | 16.0 | 31.0 | 19.0 | 152.0 | 377.4 | 4.5 | 79.3 | 4.0 | 7.0 | 9.8 | 8.4 | 10.4 |
| ចំណាយសរុប | 2948.0 | 2757.0 | 2932.0 | 3295.0 | 4174.7 | 1689.7 | 6297.8 | 1650.6 | 1766.1 | 2089.5 | 1877.1 | 2129.4 |
| ចំណាយជាមូលធន | 1388.0 | 1171.0 | 1163.0 | 1328.0 | 1638.1 | 807.4 | 2574.4 | 693.6 | 607.1 | 759.2 | 634.9 | - |
| ចំណាយចរន្ត | 1560.0 | 1586.0 | 1769.0 | 1967.0 | 2536.8 | 882.3 | 3809.0 | 752.4 | 1064.7 | 1290.4 | 1332.3 | 831.8 |
| បៀវត្សរ៍ | 587.0 | 615.0 | 640.0 | 711.0 | 822.0 | 362.6 | 1397.0 | 327.4 | 515.5 | 526.6 | 642.5 | - |
| ឧបត្ថមធន និងជំនួយសង្គមកិច្ច | - | - | - | - | - | 194.2 | 927.1 | 217.3 | 185.9 | 272.6 | 195.6 | 213.3 |
| ចំណាយចរន្តផ្សេងទៀត | - | - | - | - | - | 325.5 | 1384.9 | 207.7 | 363.2 | 491.2 | 494.3 | 449.6 |
| សមតុល្យជាទូទៅ | -1204.0 | -993.0 | -806.0 | -706.0 | -915.6 | -543.6 | -1007.8 | -548.9 | -513.4 | -904.8 | 90.2 | -592.6 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1249.0 | 886.0 | 864.0 | 1127.0 | 1360.7 | 741.5 | 2055.1 | 507.8 | 326.7 | 484.5 | -531.0 | 270.8 |
| ហិរញ្ញប្បទានក្នុងស្រុក | -45.0 | 106.0 | 148.0 | -396.0 | -445.1 | -185.8 | -127 | -310.3 | 236.5 | 316.4 | 406.4 | 422.8 |

*Source: MEF web site*

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០២-១០

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| (ខែតុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 3.3 | 1.1 | 3.9 | 5.8 | 4.7 | 5.8 | 19.7 | 4.3 | -4.8 | -3.0 | 1.7 | 7.0 |
| - ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 1.8 | 1.5 | 6.4 | 8.6 | 6.4 | 9.9 | 33.1 | 6.1 | -5.2 | -2.7 | 1.8 | 7.8 |
| - ដឹកជញ្ជូន | 0.3 | 4.9 | 9.7 | 11.4 | 9.1 | 5.8 | 19.4 | -13.0 | -16.5 | -13.8 | 2.4 | 12.9 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 3912.1 | 3973.3 | 4016.3 | 4119.7 | 4119.0 | 4062.7 | 4058.2 | 4111.6 | 4128.6 | 4164.4 | 4157.3 | 4180.1 |
| រៀលក្នុង ១ បាតថៃ | 91.1 | 95.8 | 99.9 | 102.6 | 108.7 | 122.8 | 123.5 | 116.6 | 119.2 | 122.9 | 126.0 | 127.0 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.6 | 25.6 | 25.5 | 25.8 | 25.1 | 25.0 | 24.8 | 23.6 | 23.3 | 23.5 | 23.0 | 22.3 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 36.8 | 41.4 | 46.3 | 54.0 | 70.6 | 83.2 | 105.9 | 105.6 | 110.7 | 123.2 | 133.8 | 133.9 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1521.0 | 1508.0 | 2088.0 | 2633.0 | 3140.0 | 3262.3 | 4555.2 | 2873.7 | 3056.9 | 3867.0 | 3381.9 | 3599.5 |
| ថ្លៃសាំង (រៀល/លីត្រ) | 2084.0 | 2150.0 | 2833.0 | 3442.0 | 4004.0 | 4005.0 | 4750.8 | 3112.6 | 3452.4 | 3371.1 | 3940.2 | 4163.0 |

*Sources: NIS, NBC and CDRI*

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០២-១០ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 3737.0 | 4027.0 | 4,797.0 | 5,475.0 | 7,224.0 | 10735.0 | 10345.0 | 11,222.0 | 12,611.0 | 13,869.0 | 14,655.0 | 15,514.6.0 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -849.0 | -698.0 | -467.0 | -450.0 | -282.0 | 576.0 | 1513.3 | 1,266.0 | 1,249.0 | 1,042.0 | 1,573.0 | 1,720.0 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -119.0 | -128.0 | -209.0 | -421.0 | -953.0 | -1816.0 | -2987.0 | -3,048.0 | -2,889.0 | -2,463.0 | -2,252.0 | -2,484.8 |
| ឥណទានដល់ផ្នែកឯកជន | 1059.0 | 1337.0 | 1,817.0 | 2,394.0 | 3,630.0 | 6386.0 | 9894.0 | 9,814.0 | 10,129.0 | 10,127.0 | 10,532.0 | 11,146.7 |
| រូបិយវត្ថុទូទៅ M2 | 2888.0 | 3329.0 | 4,330.0 | 5,025.0 | 6,942.0 | 11311.0 | 11858.0 | 12,488.0 | 13,859.0 | 14,912.0 | 16,228.0 | 17,234.5 |
| រូបិយវត្ថុ M1 | 813.0 | 937.0 | 1,153.0 | 1,323.0 | 1,658.0 | 2052.0 | 2399.0 | 2,545.0 | 2,695.0 | 2,773.0 | 3,120.0 | 3,148.5 |
| រូបិយវត្ថុផ្សេងៗ | 2075.0 | 2392.0 | 3,177.0 | 3,702.0 | 5,285.0 | 9259.0 | 9459.0 | 9,942.0 | 11,164.0 | 12,139.0 | 13,108.0 | 14,086.0 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 31.0 | 15.2 | 30.0 | 16.1 | 38.1 | 62.9 | 4.8 | 3.7 | 9.1 | 18.7 | 36.9 | 38.0 |
| រូបិយវត្ថុ M1 | 33.5 | 15.3 | 23.0 | 14.7 | 25.3 | 23.8 | 16.9 | 6.5 | 9.2 | 18.7 | 30.1 | 23.7 |
| រូបិយវត្ថុផ្សេងៗ | 30.0 | 15.2 | 32.8 | 16.6 | 42.8 | 75.2 | 2.2 | 2.9 | 9.1 | 18.7 | 38.6 | 41.7 |

*Source: National Bank of Cambodia*

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2007 | 2007 | 2008 | 2009 | | | | 2010 | | ២០០៩ | ២០១០ | |
| | | វិច្ឆិកា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | វិច្ឆិកា | កុម្ភៈ | ឧសភា |
| អ្នកធាក់ស៊ីក្លូ | 8075 | 9675 | 12628 | 8534 | 8896 | 7738 | 7446 | 9413 | 9570 | -41.0 | 10.3 | 7.6 |
| អ្នកលីសែង | 8588 | 9119 | 9005 | 10,476 | 10,319 | 8159 | 9566 | 9953 | 9340 | 6.2 | -5.0 | -9.5 |
| អ្នកលក់បន្លែតូចតាច | 8220 | 8552 | 9926 | 7614 | 9764 | 8323 | 7647 | 7826 | 8062 | -23.0 | 2.8 | -17.5 |
| អ្នករើសអេតចាយ | 5422 | 5727 | 4652 | 5170 | 6637 | 7087 | 4693 | 6238 | 7407 | 0.9 | 21.7 | 11.6 |
| អ្នកបំរើភោជនីយដ្ឋាន * | 4482 | 4643 | 4327 | 4283 | 4346 | 4574 | 5568 | 5131 | 5380 | 28.7 | 19.8 | 23.8 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5516 | 6426 | 8697 | 7044 | 7126 | 5785 | 5003 | 5358 | 6260 | -42.5 | -23.9 | -12.2 |
| កម្មកររោងចក្រកាត់ដេរ | 7568 | 7240 | 6554 | 6754 | 6691 | 7410 | 7745 | 7557 | 7491 | 18.2 | 11.9 | 12.0 |
| អ្នករត់ម៉ូតូឌុប | 10,634 | 11,872 | 15,691 | 11,655 | 12,148 | 9569 | 9696 | 11,302 | 10,274 | -38.2 | -3.0 | -15.9 |
| កម្មករសំណង់គ្មានជំនាញ | 6155 | 7777 | 8779 | 6115 | 9956 | 9444 | 8132 | 7699 | 9013 | -7.4 | 25.9 | -9.5 |
| កម្មករសំណង់មានជំនាញ | 11,154 | 11,286 | 12,710 | 11,771 | 13,688 | 11,918 | 13,011 | 11,924 | 11,928 | 2.4 | 1.3 | -12.9 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice -field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

*តពីទំព័រ ២៤* **ព័ត៌មានថ្មីៗ...**

នៃសាកលវិទ្យាល័យមែលប៊ិន (អូស្ត្រាលី) ដោយបានអញ្ជើញថ្នាក់ដឹកនាំចំនួន ៤០រូប ដោយផ្ទាល់ មកពីបណ្តាប្រទេសជាសមាជិកអាស៊ាន និងអូស្ត្រាលី មកជួបជុំធ្វើការពិភាក្សាកម្រិត ២ (second track) លើបញ្ហា និងនិន្នាការនៅក្នុងតំបន់ និងនៅក្នុងទំនាក់ទំនងអាស៊ាន-អូស្ត្រាលី ។ នៅថ្ងៃទី ៤ កញ្ញា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចូលរួមជាអធិបតី និងថ្លែងសុន្ទរកថាគន្លឹះបើកកម្មវិធី ទៅកាន់ភ្ញៀវអញ្ជើញចូលរួមចំនួន ២០០នាក់ រួមទាំងសាស្ត្រាចារ្យភ្ញៀវកិត្តិយស ហ្គារិថ អ៊ីវ៉ាន់ស៍ (Gareth Evans) សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិអូស្ត្រាលី និងអតីតរដ្ឋមន្ត្រីការបរទេសនៃប្រទេសអូស្ត្រាលី ដែលធ្លាប់បានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការបង្រួបបង្រួម និងកសាងសន្តិភាពនៅកម្ពុជា ។

## ផ្នែកស្រាវជ្រាវ

វិទ្យាស្ថាន CDRI បានធ្វើការស្រាវជ្រាវ និងសកម្មភាពជាប់ទាក់ទិននានាដូចតទៅ ក្នុងរយៈពេលពីខែកក្កដា ដល់ កញ្ញា ២០១០ ។

**កម្មវិធីអភិបាលកិច្ចបែបប្រជាធិបតេយ្យ និងកំណែទម្រង់សាធារណៈ** បានអនុវត្តគម្រោងស្រាវជ្រាវចំនួន ៦ និងបានដំណើរការសិក្ខាសាលាមួយ ក្នុងអំឡុងពេលបីខែនេះ ។ សំរាប់គម្រោង "វិភាគពីរដ្ឋកម្ពុជា៖ ការស្វែងរកមាគ៌ានៃការអភិវឌ្ឍបានជោគជ័យ" ក្រុមស្រាវជ្រាវបានបញ្ចប់ការសិក្សាឯកសារយោងថ្នាក់តំបន់ និងអន្តរជាតិ ហើយកំពុងសិក្សាឯកសារយោងស្តីពីកម្ពុជា ។ គម្រោង "ការវាយតម្លៃបែបគុណភាព លើផលប៉ះពាល់នៃសេវាកម្មច្រកចេញចូលតែមួយ" ដែលទទួលហិរញ្ញប្បទានពីធនាគារពិភពលោក បានចប់រួចរាល់ រីឯរបាយការណ៍ក៏បានបញ្ជូនទៅឲ្យធនាគារពិភពលោករួចរាល់ដែរ ហើយសព្វថ្ងៃក្រុមស្រាវជ្រាវកំពុងរៀបចំវាឲ្យទៅជាឯកសារពិភាក្សាមួយ ។

សំរាប់គម្រោង "យេនឌ័រ និងអភិបាលកិច្ចមូលដ្ឋាន" ដែលទទួលហិរញ្ញប្បទានពី មជ្ឈមណ្ឌលអន្តរជាតិដើម្បីរបបប្រជាធិបតេយ្យនៅមូលដ្ឋាន (នៃប្រទេសស៊ុយអ៊ែត) ក្រុមស្រាវជ្រាវកំពុងសរសេររបាយការណ៍ ដោយគ្រោងបញ្ចប់នៅចុងខែតុលា។ក្រុមស្រាវជ្រាវអំពី"កំណែទម្រង់វិស័យសាធារណៈដើម្បីកសាងអភិបាលកិច្ចល្អលើទឹកស្រោចស្រពនៅកម្ពុជា៖ គំលាតរវាងគោលនយោបាយ និងការអនុវត្ត" កំពុងបន្តការសិក្សាឯកសារយោង និងសរសេររបាយការណ៍ ។ ចំពោះគម្រោង "វិសហមជ្ឈការ និងវិមជ្ឈការនៅកម្ពុជា៖ ភាពខុសប្លែកគ្នារវាងមជ្ឈការ និងវិមជ្ឈការ" ក្រុមស្រាវជ្រាវ បានបង្ហើយរបាយការណ៍លើការសិក្សាឯកសារយោង និងកំពុងចាប់ផ្តើមសរសេរជំពូកស្តីពីវិសហមជ្ឈការ និងវិមជ្ឈការ ។

ក្រោមកិច្ចសហការណ៍ជាមួយកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ គម្រោង "ចំណាកស្រុកមិនទៀងទាត់នៅកម្ពុជា៖ បញ្ហាប្រឈម និងគោលនយោបាយឆ្លើយតប" បានបញ្ចប់ការពិនិត្យបូកសរុបឡើងវិញ និងកំពុងធ្វើសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ ។ ក្រុមសិក្សារំពឹងថា នឹងបង្ហើយរបាយការណ៍ព្រាងនៅចុងឆ្នាំនេះ ។

ម៉្យាងទៀត មានការរៀបចំសិក្ខាសាលាផ្សព្វផ្សាយព័ត៌មានរយៈពេលពីរថ្ងៃមួយនៅខេត្តសៀមរាប កាលពីថ្ងៃទី ២២-២៣ កញ្ញា ដើម្បីចែករំលែកលទ្ធផលស្រាវជ្រាវនៃការងារពីមុនៗរបស់កម្មវិធីនេះ និងស្វែងរកអនុសាសន៍ពីអ្នកពាក់ព័ន្ធនានា ដើម្បីធ្វើផែនការយុទ្ធសាស្ត្រសំរាប់ការស្រាវជ្រាវទៅថ្ងៃខាងមុខ ។

**កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ** បានអនុវត្តគម្រោងស្រាវជ្រាវចំនួន ៥ ។ របាយការណ៍ព្រាងចុងក្រោយនៃការសិក្សាពីគម្រោងឌីណាមិកនៃភាពក្រីក្រ បានចប់រួចរាល់ ។ លទ្ធផលនៃ "ការវាយតម្លៃរហ័ស ពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចទៅលើក្រុមគ្រួសារកម្ពុជា" ត្រូវបានចងក្រងជាអត្ថបទសំរាប់ចុះផ្សាយក្នុងទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា ។

របាយការណ៍សំយោគនៃគម្រោង "ការកសាងភាពធន់ទ្រាំនៃសហគមន៍នេសាទនៅបឹងទន្លេសាប៖ សកម្មភាពរួមគ្នា និងសមត្ថភាពគ្រប់គ្រងធនធាន" បានចប់សព្វគ្រប់ ហើយឯកសារពិភាក្សាក៏បានរៀបចំរួចរាល់សំរាប់ការបោះពុម្ព ។ របាយការណ៍ព្រាងចុងក្រោយនៃ "ការវាយតម្លៃពីផលប៉ះពាល់ខាងសេដ្ឋកិច្ច-សង្គមកិច្ច នៃច្រករបៀងនៅតំបន់ឆ្នេរភាគខាងត្បូងនៃមហាអនុតំបន់មេគង្គ (GMS-SCC និងអនុគម្រោង GMS-CDC) បានចប់រួចរាល់ និងបញ្ជូនទៅឲ្យធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ហើយ ។

គម្រោងថ្មីមួយរបស់ CDRI និង វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអាហារអន្តរជាតិ (IFPRI) គឺ "ការបូកសរុបពីសន្តិសុខស្បៀង អាហារូបត្ថម្ភ និងគោលនយោបាយអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា" បានចាប់ដំណើរការជាផ្លូវការនៅខែសីហា ហើយរបាយការណ៍ខ្លីៗពីរ បានសរសេររួចរាល់ ។ គម្រោងថ្មីមួយទៀតគឺ"ការកសាងវិធីសាស្ត្រវាយតម្លៃផលប៉ះពាល់សំរាប់សកម្មភាពបោសសំអាតមីននៅកម្ពុជា" បានទទួលការយល់ព្រមជួយទ្រទ្រង់ពី UNDP ហើយគ្រោងចាប់ផ្តើមជាផ្លូវការនៅពាក់កណ្តាលខែតុលា ។

**កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់** (ETRC) បានអនុវត្តគម្រោងស្រាវជ្រាវចំនួន ៨ ។ គម្រោង "អង្កេតកម្មករងាយរងគ្រោះ" និង "អង្កេតថ្លៃទំនិញនៅតាមខេត្ត" កំពុងលូតលាស់ទៅមុខយ៉ាងល្អ ។ គម្រោង "ភាពក្រីក្រ និងចំណងទាក់ទងជាមួយបរិស្ថាន៖ ករណីសិក្សានៅជនបទកម្ពុជា" ដែលជាសមាសភាគទីពីរ នៃ "គម្រោងបណ្តាញភាពក្រីក្ររបស់ ADB" នឹងបង្ហើយរបាយការណ៍ព្រាងទីមួយនៅខែតុលា សំរាប់ផ្ញើចែកចាយស្វែងរកការជួយជាមតិផ្សេងៗ ។ ក្រុមសិក្សាស្រាវជ្រាវបានទទួលការអញ្ជើញឲ្យធ្វើបទបង្ហាញពីលទ្ធផលស្រាវជ្រាវបឋម នៅថ្ងៃទី

២៤-២៦ កញ្ញា ក្នុងសន្និសីទ "បរិស្ថានរបស់ជនក្រីក្រ" នៅទីក្រុង New Delhi ។

ការចុះសិក្សាដល់កន្លែងសំរាប់គម្រោង "ចរន្តពលករខុសៗគ្នា តម្រូវការ និងផលប៉ះពាល់ខុសៗគ្នា៖ ការគ្រប់គ្រងចំណាកស្រុកកម្លាំងពលកម្មអន្តរជាតិនៅអាស៊ាន" បានចប់រួចរាល់ ហើយក្រុមស្រាវជ្រាវ កំពុងធ្វើការលើកំណត់ត្រាអង្កេត និងវិភាគលើទិន្នន័យបឋមបែបគុណភាព និងទិន្នន័យប្រភពទីពីរបែបបរិមាណ ។ គម្រោង "ការវាយតម្លៃពីផលប៉ះពាល់ខាងសេដ្ឋកិច្ច-សង្គមកិច្ច នៃគំរោងរបស់មហាអនុតំបន់មេគង្គ (GSM)" បានកែសម្រួល និងបញ្ចប់បន្ទាប់ពីបានទទួលការជួយមតិពី ADB ។ បន្ទាប់ពីសិក្ខាសាលានៅទីក្រុងហាណូយ កាលពីខែមិថុនា មានសិក្ខាសាលាផ្សព្វផ្សាយ និងពិគ្រោះយោបល់មួយ ស្តីពី "ការវាយតម្លៃពីផលប៉ះពាល់របស់ចិន ទៅលើការកាត់បន្ថយភាពក្រីក្រនៅGMS(DAN8)"បានធ្វើឡើងនៅទីក្រុងប៉េកាំងកាលពីថ្ងៃទី២៦ សីហា ហើយ CDRI ដែលជាអ្នកសម្របសម្រួលគម្រោង កំពុងរៀបចំបង្កើយ និងធ្វើសំយោគលើរបាយការណ៍ពី ៦ ប្រទេស ដើម្បីបោះពុម្ពផ្សាយ ។

កម្មវិធីផ្លាស់ប្តូរបុគ្គលិកគ្នារយៈពេលបីខែ រវាងវិទ្យាស្ថានសិក្សាពីអាស៊ីប៉ាស៊ីហ្វិក នៃបណ្ឌិតសភាវិទ្យាសាស្ត្រសង្គមចិន ជាមួយនឹង CDRI បានបញ្ចប់ប្រកបដោយជោគជ័យ ។ ក្នុងអំឡុងខែកក្កដា-កញ្ញា កម្មវិធី ETRC បានទទួលគម្រោងថ្មី ៤ គឺ៖ (១) ការធ្វើរោគវិនិច្ឆ័យលើកំណើន (២) ការវិភាគពីវិនិយោគអន្តរជាតិក្នុងវិស័យកសិកម្មនៅកម្ពុជា (៣) បញ្ហាប្រឈមចំបងៗលើមាគ៌ាលូតលាស់សេដ្ឋកិច្ច៖ ការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរដ្ឋាភិបាល (៤) ការស្វែងរកសក្តានុពលកំណើន និងការវាយតម្លៃពីសក្តានុពលកំណើននៅកម្ពុជា ក្រោមជំនួយឧបត្ថម្ភពីវិទ្យាស្ថានជើង-ត្បូង (ប្រទេសកាណាដា) អង្គការស្បៀងអាហារ និងកសិកម្ម និងវិទ្យាស្ថានអភិវឌ្ឍន៍ប្រទេសកូរ៉េ (សំរាប់គម្រោង ២ ចុងក្រោយ) ។ គម្រោងទាំងបួន នឹងដំណើរការរហូតដល់ខែធ្នូ ២០១០ ។

**កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន** បានអនុវត្តគម្រោងស្រាវជ្រាវធំៗ ចំនួន ៣ ។ គម្រោង "កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវលើការគ្រប់គ្រងធនធានទឹក" ចែកចេញជាសមាសភាគ អភិបាលកិច្ច រូបវ័ន្ត និងសេដ្ឋកិច្ច ។ ឯកសារពិភាក្សាពីការវាយតម្លៃខាងសង្គមមានចំណងជើងថា "ការវិភាគតាមការពិនិត្យឃើញជាក់ស្តែងលើការគ្រប់គ្រងទឹកស្រោចស្រពនៅតំបន់អាងទន្លេសាប៖ ឧបសគ្គ និងបញ្ហាប្រឈម" បានបោះពុម្ពផ្សាយរួចហើយ ។ សំរាប់សមាសភាគអភិបាលកិច្ច ឯកសារពិភាក្សាមួយស្តីពី ការវិភាគអ្នកពាក់ព័ន្ធ បានបញ្ចប់ និងកំពុងពិនិត្យផ្ទៀងផ្ទាត់ ។ ឯកសារពិភាក្សាទី២ ស្តីពីអភិបាលកិច្ចលើការស្រោចស្រព ក្រុមស្រាវជ្រាវបានប្រមូលទិន្នន័យរួចរាល់ និងបានសរសេរ សេចក្តីផ្តើម របាយការណ៍សិក្សាឯកសារយោង និងវិធីសាស្ត្រស្រាវជ្រាវ រួចហើយដែរ ។ ក្នុងសមាសភាគរូបវ័ន្ត ឯកសារពិភាក្សាមួយ ស្តីពី ការវិភាគខាងធារាសាស្ត្រ បានបញ្ចប់និងកំពុងពិនិត្យកែសម្រួល ។ ឯកសារពិភាក្សាមួយ ស្តីពីបម្រែបម្រួលការប្រើប្រាស់ដី និងការវិភាគដំណើរការដែនរងទឹកភ្លៀង កំពុងតាក់តែងឡើង ។ ក្រុមស្រាវជ្រាវកំពុងប្រមូលទិន្នន័យ សំរាប់ឯកសារពិភាក្សាទីបី ស្តីពីការលៃចែកទឹក ។ សំរាប់សមាសភាគសេដ្ឋកិច្ច ឯកសារពិភាក្សាទីមួយ កំពុងតាក់តែងឡើង ហើយឯកសារពីរផ្សេងទៀតគ្រោងសរសេរជាបន្ត ។

សេចក្តីព្រាងទីមួយ នៃឯកសារពិភាក្សាស្តីពី "ព្រៃតំបន់ត្រូពិចសំរាប់ការកាត់បន្ថយភាពក្រីក្រ - ការវិភាគទិន្នន័យតាំងពីកំរិតគ្រួសារដល់កំរិតសាកល" រំពឹងថានឹងបញ្ចប់នៅដើមខែតុលា ។ ក្រុមស្រាវជ្រាវពី "ការកសាងសមត្ថភាពសហគមន៍សំរាប់ការផ្តួចផ្តើមគំនិតកាត់បន្ថយភាពក្រីក្រ នៅតំបន់អាងទន្លេសាប" បានបញ្ចប់អង្កេតពីការត្រៀមខ្លួន និងសមត្ថភាពសហគមន៍ ហើយពួកគេកំពុងបន្តកិច្ចប្រឹងប្រែងប្រមូលឯកសារស្រាវជ្រាវ សម្រាប់មជ្ឈមណ្ឌលធនធានទន្លេសាប នៅក្នុងបណ្ណាល័យ CDRI និងរៀបចំឯកសារទាំងនោះឲ្យកាន់តែងាយស្រួលប្រើប្រាស់ ។

**កម្មវិធីអភិវឌ្ឍន៍សង្គម** បានអនុវត្តគម្រោង ២ ។ ទីមួយ ឯកសារសន្និសីទស្តីពីផ្នែកសុខាភិបាល បានចប់រួចរាល់ ហើយការបោះពុម្ពផ្សាយដែលទទួលបានមូលនិធិពី សាកលវិទ្យាល័យស្រាវជ្រាវ (University Research Co., LLC—URC) គ្រោងចាប់ដំណើរការក្នុងខែតុលា ។ ទីពីរ គម្រោង "Equitap" ដែលទទួលបានហិរញ្ញប្បទានពី AusAID នោះ ក្រុមស្រាវជ្រាវកំពុងសំអាតទិន្នន័យ និងពិនិត្យឡើងវិញលើការវិភាគពិធីសារ ។

សំរាប់កម្មវិធីការកសាងសន្តិភាព ក្រុមបណ្តុះបណ្តាលបានដំណើរការវគ្គបណ្តុះបណ្តាលចំនួន ៥ ដែលរួមមាន "ការងារកសាងសន្តិភាព" (កម្មវិធីបណ្តុះបណ្តាលស្នូលសម្រាប់មន្ត្រីរាជការ បុគ្គលិកអង្គការសង្គមស៊ីវិល សហជីពពលករ និងអង្គការមិនស្វែងរកចំណេញផ្សេងៗ) "តួនាទីនៃប្រព័ន្ធផ្សព្វផ្សាយក្នុងការកសាងសន្តិភាព" (សម្រាប់អ្នកសារព័ត៌មានមកពីប្រព័ន្ធផ្សព្វផ្សាយ និងសមាគមសារព័ត៌មានតាមមូលដ្ឋាន) និង "វគ្គបណ្តុះបណ្តាលជំនាញដោះស្រាយទំនាស់" ដែលផ្តល់សំរាប់អ្នកអនុវត្តផ្ទាល់នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ តាមការស្នើសុំពីអភិបាលស្រុក ។ សិក្ខាសាលាពិគ្រោះយោបល់ដ៏មានផ្លែផ្កាមួយក៏បានធ្វើឡើង ដើម្បីពង្រឹងទំនាក់ទំនងល្អជាមួយអង្គការនានាដែលធ្វើការក្នុងវិស័យដូចគ្នា ។ លទ្ធផលបានពីសិក្ខាសាលា នឹងយកមកចងក្រងសំរាប់បង្កើតជាកម្មវិធីបណ្តុះបណ្តាលទៅអនាគតទៀត ។

ចាប់តាំងឆ្នាំ២០០៧ មក CDRI បានធ្វើសិក្ខាសាលាស្រាវជ្រាវរៀងរាល់ពីរខែម្តង ទាក់ទងនឹងការអភិវឌ្ឍ ដើម្បីចែករំលែកលទ្ធផលស្រាវជ្រាវ និងពង្រឹងគុណភាពស្រាវជ្រាវ ។ អ្នកធ្វើបទបង្ហាញក្នុងសិក្ខាសាលាទាំងនេះ ជាអ្នកស្រាវជ្រាវនៅ CDRI និងអ្នកស្រាវជ្រាវ និងអ្នកអនុវត្តផ្ទាល់ មកពីស្ថាប័នផ្សេងៗ និង NGOs នៅទីក្រុងភ្នំពេញ ។ ក្នុងអំឡុងពេលនេះ សាស្ត្រាចារ្យ Guo Jiguang ជាជំនាញការមកពី វិទ្យាស្ថានសិក្សាពីអាស៊ីប៉ាស៊ីហ្វិក នៃបណ្ឌិតសភាវិទ្យាសាស្ត្រសង្គមចិន បានធ្វើបទបង្ហាញពីគម្រោងស្រាវជ្រាវរបស់គាត់ ស្តីពី "វិនិយោគចិននៅកម្ពុជា" ៕

## ឯកសារចេញផ្សាយថ្មីៗពីវិទ្យាស្ថាន CDRI




### ឯកសារពិភាក្សាលេខ ៣៦៖ ចំណាកស្រុករបស់យុវជន និងនគរូបនីយកម្ម នៅប្រទេសកម្ពុជា

ការសិក្សាមានគោលដៅបំពេញនូវកង្វះខាតចំណេះដឹងនានា តាមរយៈគោលបំណងជាក់លាក់ចំនួន ៥ (ក) ស្វែងយល់ពីសាវតារខាងសេដ្ឋកិច្ច-សង្គមកិច្ចរបស់គ្រួសារយុវជនចំណាកស្រុក (ខ) កំណត់ពីកត្តា និងកាលៈទេសៈ ដែលជំរុញអោយមានចំណាកស្រុក និងស្វែងយល់ពីបែបបទដែលយុវជនធ្វើការសម្រេចចិត្តធ្វើចំណាកស្រុក (គ) ពិនិត្យមើលពីតួនាទីនៃបណ្ដាញសង្គមនៅក្នុង ការជួយសម្រួលដល់ការធ្វើចំណាកស្រុក (ឃ) កំណត់ពីប្រភេទការងារផ្សេងៗនៅទីក្រុងសម្រាប់យុវជនចំណាកស្រុក និងការបញ្ចូលខ្លួនពួកគេទៅក្នុងការរស់នៅក្នុងទីក្រុង (ង) ស្វែងយល់ពីទំនាក់ទំនងរបស់ពួកគេជាមួយគ្រួសារដែលបញ្ជូនពួកគេមក និងផលប៉ះពាល់លើភាពក្រីក្រក្នុងគ្រួសារ និងសហគមន៍ពួកគេ ។ ការសិក្សាបង្ហាញថា យុវជនចំណាកស្រុកភាគច្រើន ចេញមកពីគ្រួសារមធ្យម និងក្រីក្រ ។ អ្នកក្រីក្រខ្លាំង ខ្វះខាតមូលធនសង្គម និងហិរញ្ញវត្ថុ សម្រាប់ធ្វើចំណាកស្រុក រីឯអ្នកធូរធារសម្រេចចិត្តរស់នៅក្នុងភូមិដដែល ដើម្បីជៀសវាងពីហានិភ័យពាក់ព័ន្ធនឹងចំណាកស្រុក ។ ពលករវ័យក្មេង ច្រើនធ្វើចំណាកស្រុកពីតំបន់ជនបទមកទីក្រុងតាមរយៈច្រក និងបណ្ដាញក្រៅផ្លូវការ ហើយបណ្ដាញផ្លូវការមិនមានច្រើនទេ ។ ការសិក្សាក៏បានរកឃើញដែរថា ពលករចំណាកស្រុកវ័យក្មេងជួបប្រទះការលំបាកជាច្រើន ទាំងក្នុងការរស់នៅ និងក្នុងការងារ ។



### ឯកសារពិភាក្សាលេខ ៤១៖ ផលប៉ះពាល់នៃ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាស៊ាន-ចិន ចំពោះបរិស្ថាននៅតាម បណ្ដាប្រទេសក្នុងមហាអនុតំបន់មេគង្គ

មហាអនុតំបន់មេគង្គ (GMS) មានប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម និងខេត្តយូណាននៃប្រទេសចិន បានឆ្លងកាត់បម្លាស់ប្ដូរខាងសេដ្ឋកិច្ច និងសង្គមកិច្ចយ៉ាងលឿន ជាពិសេសនៅក្នុងសេរីភាវូបនីយកម្មពាណិជ្ជកម្ម តាមរយៈកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចដ៏ជិតស្និទ្ធ ។ នៅឆ្នាំ២០០៤ ក្នុងលក្ខណៈជាសមាជិកអាស៊ាន បណ្ដាប្រទេសក្នុង GMS5 (ប្រទេសទាំងអស់ក្នុង GMS លើកលែងខេត្តយូណានចេញ) និងប្រទេសចិន បានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA) ។ ACFTA តំរូវឱ្យប្រទេសនីមួយៗកាត់បន្ថយពន្ធគយជាបណ្ដើរៗ លើទំនិញដែលនាំចេញមកពីប្រទេសជាដៃគូនៅក្នុងកិច្ចព្រមព្រៀងនេះ ។

ការសិក្សា បានបង្ហាញច្បាស់ពីបញ្ហាបរិស្ថានជាច្រើន ដែលអាចផុសចេញពី សេរីភាវូបនីយកម្មពាណិជ្ជកម្ម ពោលគឺជាក្បាលម៉ាស៊ីនដ៏សំខាន់នៃកំណើនសេដ្ឋកិច្ច ។ ប្រទេសនៅ GMS ត្រូវបន្តពង្រីកពង្រឹង សេរីភាវូបនីយកម្មពាណិជ្ជកម្ម និងសមាហរណកម្មសេដ្ឋកិច្ច ប៉ុន្តែត្រូវគិតគូរដល់ បញ្ហាបរិស្ថាននិងដាក់បញ្ចូល វាទៅក្នុងការចរចា និង កិច្ចព្រមព្រៀងពាណិជ្ជកម្ម ដើម្បីកាត់បន្ថយ ផលប៉ះពាល់អវិជ្ជមានផ្សេងៗ ដែលកើតមានដល់បរិស្ថាន ។ ធ្វើបែបនេះ ទើបពាណិជ្ជកម្ម អាចជួយជំរុញកំណើនសេដ្ឋកិច្ច និងរួមចំណែកដល់ការអភិវឌ្ឍ ។


**Cambodia Development Review—2010 Subscription Rates**

**Domestic Subscription (Individual)**

❐ English edition ($14) ❐ Khmer edition (5,000 riels) Payment by ❐ cash or ❐ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❐ English edition ($60 for five copies) ❐ Khmer edition (20,000 riels for five copies) Payment by ❐ cash or ❐ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

| | | |
|---|---|---|
| ❐ Thailand, Laos, Vietnam | ❐ English edition ($25)* | ❐ Khmer edition ($15)* |
| ❐ Asia and Europe | ❐ English edition ($30)* | ❐ Khmer edition ($20)* |
| ❐ Americas and Africa | ❐ English edition ($35)* | ❐ Khmer edition ($25)* |

* Subscription includes postage. **Payment options:**

**1.** By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
Transfer to: Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank
Bank Address: Phnom Penh, Cambodia
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
Swift Code: CHASUS33
CHIP UID 004966

**2.** By Cheque - Please add (overseas) $50 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications.

Title: ❐Mr ❐Ms ❐Dr ❐Other ..........
First name: .......... Last name: .......... Position: ..........
Organisation / Company: ..........
Address (CCC Box if applicable): ..........
City / Province: .......... Country: ..........
Telephone: .......... Fax: ..........
e-mail: .......... ❐ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Department at CDRI if your contact details change.

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ផ្នែកគ្រប់គ្រង

ការប្រជុំពាក់កណ្តាលឆ្នាំ របស់ក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន CDRI បានធ្វើឡើងនៅថ្ងៃទី ២០ សីហា ២០១០ ។ ក្រុមប្រឹក្សាភិបាលបានអនុម័តយល់ព្រម លើការពន្យារអាណត្តិរបស់លោក ឡារី ស្ត្រេន្ធែ នាយកប្រតិបត្តិនៃ CDRI រហូតដល់ចុងឆ្នាំ២០១២ និងផែនការដ៏ម៉ត់ចត់ សម្រាប់ជ្រើសរើសអ្នកបន្តតំណែងប្រធានក្រុមប្រឹក្សាភិបាល ។

នៅកំឡុងខែកក្កដា - សីហា វិទ្យាស្ថាន CDRI បានចាប់ធ្វើការពិគ្រោះយោបល់ ជាមួយមន្ត្រីជាន់ខ្ពស់នៅតាមក្រសួងនានានៃរាជរដ្ឋាភិបាលកម្ពុជា ដែលមានការងារពាក់ព័ន្ធដល់វិស័យទាំងប្រាំក្នុងកម្មវិធីស្រាវជ្រាវខាងគោលនយោបាយរបស់ CDRI ។ ការពិគ្រោះយោបល់នេះសំខាន់ខ្លាំងណាស់សម្រាប់ឲ្យ CDRI កំណត់នូវអាទិភាពស្រាវជ្រាវខាងគោលនយោបាយ និងបន្តកសាងឯកសារយុទ្ធសាស្ត្រស្រាវជ្រាវប្រទេសកម្ពុជា របស់ខ្លួន ។ យុទ្ធសាស្ត្រនេះ ដែលគ្រោងរៀបចំឱ្យស្រេចបាច់នៅមុនដំណាច់ឆ្នាំ ២០១០ នឹងក្លាយជាមូលដ្ឋានសម្រាប់ការធ្វើផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-២០១៥ របស់ CDRI ព្រមទាំងជួយជំរុញការគាំទ្ររយៈពេលវែង ដែលមានការសម្របសម្រួលកាន់តែល្អ សម្រាប់ CDRI និងកម្មវិធីស្រាវជ្រាវរបស់វិទ្យាស្ថាន ។

វេទិកាសិក្សាស្រាវជ្រាវការអភិវឌ្ឍន៍ (DRF) ដែលទទួលបានការឧបត្ថម្ភគាំទ្រពី មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា (IDRC) និងសហការរៀបចំដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និង វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល (LI) បានឆ្លងកាត់ ការពិនិត្យឡើងវិញលើការរៀបចំផ្នែកអភិបាលកិច្ចដើម្បីពង្រឹង សកម្មភាពសម្រាប់រយៈពេលដែលនៅសល់ក្នុងដំណាក់កាលទីមួយ គឺរហូតដល់ខែកញ្ញា ២០១១ ។ IDRC បានប្រកាសពីគោលបំណងផ្តល់ជំនួយគាំទ្រ សម្រាប់ដំណាក់កាលទីពីរដែលមានរយៈពេលបីឆ្នាំ គិតចាប់ពីឆ្នាំ២០១១ ។ សន្និសីទប្រចាំឆ្នាំ DRF ក្រោមប្រធានបទ "ការស្រាវជ្រាវ និងគោលនយោបាយជម្រុញការរើបសេដ្ឋកិច្ច និងការអភិវឌ្ឍប្រទេសកម្ពុជា" បានធ្វើឡើងនៅថ្ងៃទី៩-១០ កញ្ញា ២០១០ នៅរាជធានីភ្នំពេញ ដោយមានអ្នកចូលរួមប្រមាណ ២០០ នាក់មកពីសហគមន៍ស្រាវជ្រាវនៅកម្ពុជា ។

មុខដំណែងនាយកផ្នែកស្រាវជ្រាវនៃ CDRI ដែលត្រូវបំពេញបន្ទាប់ការចប់អាណត្តិរបស់បណ្ឌិត ហូសេន ចេលីលាន នៅថ្ងៃទី ៣០ កញ្ញា ២០១០ គឺបានធ្វើការផ្សព្វផ្សាយ និងជូនព័ត៌មានតាមរយៈបណ្តាញរបស់ CDRI ទាំងនៅក្នុងប្រទេស ក្នុងតំបន់ និងនៅអន្តរជាតិ ។ ក្នុងកិច្ចប្រជុំកាលពីខែសីហា ក្រុមប្រឹក្សាភិបាលរបស់ CDRI បានថ្លែងអំណរគុណដល់បណ្ឌិត ហូសេន ចំពោះការរួមចំណែកយ៉ាងច្រើនរបស់លោក ក្នុងការអភិវឌ្ឍកម្មវិធីស្រាវជ្រាវ ការកសាងសមិទ្ធផល និងការលើកកម្ពស់សមត្ថភាពអ្នកស្រាវជ្រាវ របស់ CDRI ។

នៅថ្ងៃទី ៣-៥ កញ្ញា វិទ្យាស្ថាន CDRI បានសហការរៀបចំវេទិកាសន្ទនានៃបណ្តាញទំនាក់ទំនងអាស៊ី ឆ្នាំ២០១០ នៅរាជធានីភ្នំពេញ ជាមួយមជ្ឈមណ្ឌលបណ្តាញទំនាក់ទំនងអាស៊ី

(តទៅទំព័រ ២១)

ទស្សនាវដ្តី
អភិវឌ្ឍន៍កម្ពុជា
ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ឆ្នាំទី១៤ លេខ៣ ខែកក្កដា~កញ្ញា ឆ្នាំ២០១០

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅ នៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខា ប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☞ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@wicam.com.kh
website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយៈ វបសអ
គ្រប់គ្រងកែសំរួលៈ យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្មៈ អ៊ុំ ចាន់ថា និង ម៉េន ច័ន្ទធីតា
ជំនួយការកែសំរួលៈ ខេង សេង និង អ៊ឹង សុជាតិ
រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខៈ រូបភាព វបសអ

© រក្សាសិទ្ធិ ២០១០ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជាៈ អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

គំនិត ការលើកពីហេតុការណ៍ និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។